**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)**

# ផែនការអនុវត្តគណនេយ្យភាពសង្គម

## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
## ដំណាក់កាលទី២ (២០១៩-២០២៥)

អនុម័តៈ ខែវិច្ឆិកា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ៖ ០៧៣ [illegible] /គ.ជ.អ.ប

ថ្ងៃសុក្រ ១៤ កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សៀវភៅផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ ឆ្នាំ (២០១៩-២០២៣)

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

- យោងប្រកាសលេខ ៤២៧៥ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងសេចក្តីណែនាំលេខ០៨២ សណន/គ.ជ.វ.វ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ ការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស
- យោងប្រកាសលេខ ១៦៥ ប្រ.ក/គ.ជ.អ.ប ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- យោងសេចក្តីសម្រេចលេខ ០៤៨ សសរ/គ.ជ.អ.ប ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ
- យោងផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣
- យោងផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦-២០១៨ ដែលដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦។
- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ចុះថ្ងៃទី ២៧ ខែ ៦ ១ ឆ្នាំ ២០២០ ស្តីពីគម្រោងមាហរណកម្មគណនេយ្យភាពសង្គមនៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- តាមចាំបាច់របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

**ប្រការ ១.**

ដាក់ឱ្យប្រើប្រាស់នូវសៀវភៅផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស) ដំណាក់កាលទី២ (២០១៩-២០២៣) អក្សរកាត់ I-SAF II សម្រាប់ប្រើប្រាស់ក្នុងការរៀបចំ និងអនុវត្តសកម្មភាព នៃផែនការអនុវត្ត គណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ប្រការ ២.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ី

វិល ដៃគូអនុវត្ត និងអ្នកពាក់ព័ន្ធដែលមានភារកិច្ចអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ត្រូវអនុវត្តតាម គោលការណ៍ បែបបទ និងនីតិវិធីនានា ដែលបានកំណត់នៅក្នុងសៀវភៅនេះ ក្នុងការរៀបចំ និងអនុវត្តសកម្មភាព នៃផែនការអនុវត្តគណនេយ្យភាពសង្គមនេះ។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

***ចម្លងជូន÷***

-ក្រសួងជាសមាជិក គ.ជ.អ.ប

-ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-លេខាធិការដ្ឋាន គ.ជ.អ.ប

-អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

( ដើម្បីជូនជ្រាប )

-រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរពាក់ព័ន្ធ រាជធានី ខេត្ត

-រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង រដ្ឋបាលឃុំ សង្កាត់

-ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដៃគូអនុវត្ត

( ដើម្បីសហការអនុវត្ត )

-ឯកសារ កាលប្បវត្តិ

# អារម្ភកថា

គណនេយ្យភាពសង្គមគឺជាឧបករណ៍ដ៏មានសារៈសំខាន់ ក្នុងការរួមចំណែកដល់ការពង្រឹងអភិបាលកិច្ចនៅមូលដ្ឋាន។ ដោយយល់ឃើញពីសារៈសំខាន់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានអនុម័តកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវដល់តួអង្គអនុវត្តទាំងអស់ (ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ) ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ក្នុងក្របខ័ណ្ឌ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស) ដំណាក់កាលទី១ (២០១៦-២០១៨) ត្រូវបានបញ្ចប់ការអនុវត្តនៅដំណាច់ឆ្នាំ២០១៨ កន្លងមកនេះ។ ជាមួយគ្នានេះដែរ ផ.អ.គ.ស ដំណាក់កាលទី២ នៅតែបន្តលើកកម្ពស់ ការពង្រឹងសកម្មភាពដែលបានអនុវត្តនៅដំណាក់កាលទី១ និងពង្រីកតំបន់គោលដៅនៃរដ្ឋបាលឃុំ សាលាបឋមសិក្សា មណ្ឌលសុខភាពនៅទូទាំងប្រទេស ព្រមទាំងពង្រីកវិសាលភាពភូមិសាស្ត្រ តំបន់គោលដៅ និងសេវាផ្សេងៗទៀត នៃការអនុវត្តនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលសង្កាត់ ព្រមទាំងកែលម្អនូវវិធីសាស្ត្រអនុវត្ត ផ.អ.គ.ស ដើម្បីទទួលបាននូវគុណភាព ប្រសិទ្ធភាព និងសមិទ្ធផលថ្មីនៃ ផ.អ.គ.ស ដំណាក់កាលទី២។

ផ.អ.គ.ស ដំណាក់កាលទី២ មានសមាសភាគសំខាន់ៗចំនួន៥ រួមមាន៖ ១) តម្លាភាព និងភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា ២) ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ៣) ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ៤) ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង និង ៥) ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ក្នុងដំណាក់កាលទី២ ទោះបីក្រសួង ស្ថាប័នសាមី នឹងមានការទទួលខុសត្រូវកាន់តែច្រើនលើសកម្មភាព ផ.អ.គ.ស ក្នុងវិស័យរបស់ខ្លួនក៏ដោយ លេខាធិការដ្ឋាន គ.ជ.អ.ប នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលសកម្មភាពផ្នែកផ្គត់ផ្គង់ និងការទំនាក់ទំនងជាក្រុមសម្របសម្រួលផ្នែកតម្រូវការ ដើម្បីត្រួតពិនិត្យការផលិតកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) ប្រចាំឆ្នាំ គ្រប់គ្រងប្រព័ន្ធទិន្នន័យ និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ផ្តល់គោលការណ៍ណែនាំពាក់ព័ន្ធនឹង ផ.អ.គ.ស និងធានាថារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសដើម្បីចូលរួមក្នុងសកម្មភាព ផ.អ.គ.ស ប្រកបដោយគុណភាព ប្រសិទ្ធភាព។ ក្រៅពីនេះ លេខាធិកាដ្ឋាន គ.ជ.អ.ប នឹងគាំទ្រក្រសួង ស្ថាប័នសាមីទាំងអស់ដែលចង់បញ្ជ្រាប ផ.អ.គ.ស ក្នុងរចនាសម្ព័ន្ធ ការរៀបចំកម្មវិធី គោលនយោបាយ និងការរៀបចំផែនការសកម្មភាព និងថវិការបស់ខ្លួន។

ដោយឡែកចំពោះតំណាងសង្គមស៊ីវិលវិញសម្របសម្រួលសកម្មភាព របស់ផ្នែកតម្រូវការក្នុងការអនុវត្ត ផ.អ.គ.ស ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទំនាក់ទំនងជា

មួយ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមមូលនិធិបរធនបាលកិច្ច ព្រមទាំងគាំទ្រ និងសម្របសម្រួលសកម្មភាពរបស់អង្គការសង្គមស៊ីវិល ដៃគូអនុវត្តនានា។

ក្នុងនាមរាជរដ្ឋាភិបាល និង គ.ជ.អ.ប ខ្ញុំសូមសម្តែងនូវអំណរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងជាពិសេស លេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែងចូលរួមចំណែកក្នុងការរៀបចំតាក់តែង ផ.អ.គ.ស ដំណាក់កាលទី២ដ៏មានសារសំខាន់នេះ។

ថ្ងៃ សុក្រ ១២កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


មាតិកា ---------- I

បញ្ជីតារាង ---------- III

បញ្ជីរូបភាព ---------- III

បញ្ជីឧបសម្ព័ន្ធ ---------- III

បញ្ជីអក្សរកាត់ ---------- IV

ជំពូកទី១ ៖ ទិដ្ឋភាពទូទៅផែនការអនុវត្តគណនេយ្យភាពសង្គមជំណាក់កាលទី២ .......... 2

១. សេចក្តីផ្តើម .......... 2

២. ចក្ខុវិស័យនៃ ផ.អ.គ.ស ជំណាក់កាលទី២ .......... 2

៣. គោលបំណង និងគោលដៅ .......... 3

៤. វិសាលភាព និងអ្នកទទួលផល .......... 4

ក. វិសាលភាពតំបន់គោលដៅ ---------- 4

ខ. វិសាលភាពសេវា ---------- 4

គ. អ្នកទទួលផល ---------- 5

៥. កិច្ចដំណើរការរៀបចំតាក់តែង ផ.អ.គ.ស ជំណាក់កាលទី ២.......... 5

៦. វដ្តនៃសកម្មភាព ផ.អ.គ.ស ជំណាក់កាលទី២ ប្រចាំឆ្នាំ.......... 7

៧. សមាសភាគ និងលទ្ធផលរំពឹងទុក .......... 8

៨. ថវិកាប៉ាន់ស្មានរបស់ ផ.អ.គ.ស ជំណាក់កាលទី២ .......... 12

ជំពូកទី២ ៖ សមាសភាគផែនការអនុវត្តគណនេយ្យភាពសង្គមជំណាក់កាលទី២.......... 14

សមាសភាគទី១៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា.......... 15

ក. សេចក្តីផ្តើម ---------- 15

ខ. វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ---------- 15

គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក ---------- 18

ឃ. ថវិកាប៉ាន់ស្មាន---------- 22

សមាសភាគទី២៖ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ.......... 23

ក. សេចក្តីផ្តើម ---------- 23

ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ 23
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក 25
ឃ. ថវិកាប៉ាន់ស្មាន 28
**សមាសភាគទី៣÷ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការខារគណនេយ្យភាពសង្គម** 29
ក. សេចក្តីផ្តើម 29
ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ 29
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក 32
ឃ. ថវិការប៉ាន់ស្មាន 34
**សមាសភាគទី៤÷ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង** 35
ក. សេចក្តីផ្តើម 35
ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ 35
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក 37
ឃ. ថវិកាប៉ាន់ស្មាន 42
**សមាសភាគទី៥ ÷ ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** 43
ក. សេចក្តីផ្តើម 43
ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ 43
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក 45
ឃ. ថវិកាប៉ាន់ស្មាន 49
**ជំពូកទី៣ ÷ ការគ្រប់គ្រងផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២** 51
**១. ការរៀបចំស្ថាប័ន** 51
**២. តួអង្គ និងការទទួលខុសត្រូវក្នុង ផ.អ.គ.ស** 52
**៣. និរន្តរភាព** 57
**៤. ការផ្តល់ហិរញ្ញប្បទាន** 58
**៥. ការគ្រប់គ្រង និងវិធានការកាត់បន្ថយហានិភ័យ** 62

# បញ្ជីតារាង


តារាងទី១៖ សង្ខេបគោលដៅលម្អិតតាមសមាសភាគនីមួយៗ នៃ ផ.អ.គ.ស ....3

តារាងទី២៖ ការរៀបចំយុទ្ធសាស្ត្រទៅជាសមាសភាគសម្រាប់អនុវត្ត ....9

តារាងទី៣៖ សង្ខេបសមាសភាគ សមិទ្ធផល និងលទ្ធផលរំពឹងទុក នៃ ផ.អ.គ.ស ដំណាក់កាលទី២ ..10

តារាងទី៤៖ ថវិកាប៉ាន់ស្មានសម្រាប់ ផ.អ.គ .ស ដំណាក់កាលទី២ (គិតជាដុល្លារអាមេរិក) ....60


# បញ្ជីរូបភាព


រូបភាពទី១៖ វដ្ត នៃសកម្មភាព ផែនការអនុវត្តគណនេយ្យភាពសង្គម ប្រចាំឆ្នាំ ដំណាក់កាលទី២ ....8

រូបភាពទី២៖ រចនាសម្ព័ន្ធ នៃការរៀបចំផ្នែកស្ថាប័នអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ ....52


# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១÷ ឯកសារយោង ....64

ឧបសម្ព័ន្ធទី២÷ ឈ្មោះអ្នកពាក់ព័ន្ធដែលបានជួបសម្ភាសន៍ និងពិគ្រោះយោបល់ ....67

ឧបសម្ព័ន្ធទី៣÷ ក្របខ័ណ្ឌលទ្ធផលក្នុងការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ ....70

ឧបសម្ព័ន្ធទី៤÷ វិសាលភាពតំបន់គោលដៅអនុវត្ត នៃផ.អ.គ.ស ដំណាក់កាលទី១ និងទី២ ....76

ឧបសម្ព័ន្ធទី៥÷ វិសាលភាពសេវា នៃ ផ.អ.គ.ស ដំណាក់កាលទី១ និងទី២ ....77

ឧបសម្ព័ន្ធទី៦÷ ការផ្លាស់ប្តូរការទទួលខុសត្រូវក្នុងការអនុវត្ត ផ.អ.គ.ស ក្នុងសហគមន៍ ដែលបានអនុវត្ត រយៈពេល៣ឆ្នាំ ឬចាប់ពី៤ឆ្នាំ ....78

ឧបសម្ព័ន្ធទី៧÷ សកម្មភាពលម្អិតទៅតាមសមិទ្ធផល និងលទ្ធផលរំពឹងទុក ....80

ឧបសម្ព័ន្ធទី៨÷ វដ្ត នៃសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី១ (២០១៦-២០១៨) ....89

ឧបសម្ព័ន្ធទី៩÷ វដ្ត នៃសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី២ (២០១៩-២០២៣) ....90

ឧបសម្ព័ន្ធទី១០÷ សន្ទានុក្រម ....91

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.គ.អ.ស (I-SAF-PSC) | គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (I-SAF Partnership Steering Committee) |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផ.ស.គ.ស | ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផ.ស.រ.គ (JAAP) | ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (Joint Accountability Action Plan) |
| ផ.អ.គ.ស (I-SAF) | ផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (Implementation of Social Accountability Framework) |
| API | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (Advocacy and Policy Institute) |
| CAF | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (Community Accountability Facilitator) |
| CSO | អង្គការសង្គមស៊ីវិល ( Civil Society Organization) |
| EU | សហភាពអឺរ៉ុប (European Union) |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (Information for Citizens) |
| ICT | បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (Information Communication Technology) |
| LGBT | ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ស្រឡាញ់ទាំងពីរភេទ ក្រុមប្តូរយេនឌ័រ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-Government Organization) |
| Post-On | ទិន្នន័យលទ្ធផលការងារ |
| RACHA | អង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (Reproductive and Child Health Alliance) |
| SDC | ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍ប្រទេសស្វីស (Swiss Development Cooperation) |
| SIDA | ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Swedish International Development Agency) |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (United States Agency for International Development) |

# ជំពូកទី១

# ទិដ្ឋភាពទូទៅផែនការអនុវត្ត

# គណនេយ្យភាពសង្គមដំណាក់កាលទី២

# ជំពូកទី១ ÷ ទិដ្ឋភាពទូទៅផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២

## ១. សេចក្តីផ្តើម

ផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស) ដំណាក់កាលទី២ (២០១៩-២០២៣) បានបង្ហាញអំពីវិសាលភាព ខ្លឹមសារ និងអភិក្រមសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានអនុម័តជាឯកសារគោលនយោបាយដោយ គ.ជ.អ.ប. នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។ ឯកសារផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២នេះបានពិភាក្សា និងឯកភាពជាមួយតំណាងក្រសួងនានាដែលពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ជាមូលដ្ឋានរួមមួយសម្រាប់យកទៅអនុវត្តបន្តពី ផ.អ.គ.ស ដំណាក់កាលទី១ ។

ជាទិដ្ឋភាពរួម ផ.អ.គ.ស ដំណាក់កាលទី២ មានបង្ហាញអំពីសកម្មភាព និងការរៀបចំនានាដែលនឹងយកទៅអនុវត្តដោយក្រសួង ស្ថាប័ន អង្គភាពនានា (ហៅថាផ្នែកផ្គត់ផ្គង់) និងដោយអង្គការសង្គមស៊ីវិល (ហៅថាផ្នែកតម្រូវការ)។ ឯកសារនេះ មានរៀបរាប់អំពីវិសាលភាពតំបន់គ្របដណ្តប់ វិសាលភាពសេវា អ្នកទទួលផល និងខ្លឹមសារសមាសភាគ ការរៀបចំស្ថាប័ន តួអង្គ និងការទទួលខុសត្រូវក្នុងផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ និរន្តរភាព ថវិកា លទ្ធផលរំពឹងទុក និងហានិភ័យដែលអាចកើតឡើង។

គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សីគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ចដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រកាន់យកតាមកិច្ចដំណើរការនេះ។ កិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (អ្នកផ្តល់សេវា) និងប្រជាពលរដ្ឋ (អ្នកប្រើប្រាស់សេវា) គឺសំដៅគាំទ្រដល់អ្នកផ្តល់សេវាសាធារណៈឱ្យបំពេញការងាររបស់ខ្លួនបានប្រសើរជាងមុន។ បទពិសោធន៍កន្លងមកដំណាក់កាលទី១ បានបង្ហាញថា ឧបករណ៍គណនេយ្យភាពសង្គមនានា (ដូចជាប័ណ្ណដាក់ពិន្ទុដោយសហគមន៍) ជួយជំរុញឱ្យមានការគោរពគ្នា និងការចូលរួមរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិសំដៅការអភិវឌ្ឍនៅមូលដ្ឋានឱ្យមានភាពប្រសើរឡើង។

## ២. ចក្ខុវិស័យនៃ ផ.អ.គ.ស ដំណាក់កាលទី២

ចក្ខុវិស័យនៃ ផ.អ.គ.ស ដំណាក់កាលទី២ (២០១៩-២០២៣) គឺពង្រឹងយន្តការសម្រាប់អនុវត្តការងារគណនេយ្យសង្គមទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការនៅទូទាំងប្រទេសប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព សំដៅលើកកម្ពស់នូវសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣. គោលបំណង និងគោលដៅ

គោលបំណងនៃ ផ.អ.គ.ស ដំណាក់កាលទី២ គឺបង្កើនការអនុវត្ត ផ.អ.គ.ស ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងក្នុងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព តាមរយៈការលើកកម្ពស់តម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ផ.អ.គ.ស ដំណាក់កាលទី២ មានគោលដៅដូចខាងក្រោម៖

- ពង្រឹងការបំពេញការងាររបស់អង្គភាពផ្តល់សេវាឱ្យកាន់តែប្រសើរឡើង
- ធ្វើឱ្យប្រសើរឡើងនូវការឆ្លើយតបរបស់អង្គភាពផ្តល់សេវាទៅនឹងតម្រូវការចាំបាច់នានា របស់ប្រជាពលរដ្ឋ
- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងដំណើរការត្រួតពិនិត្យតាមដាន ផ.អ.គ.ស
- លើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមជាមួយអង្គភាពផ្តល់សេវា

ចំពោះគោលដៅលម្អិតនៃសមាសភាគនីមួយៗនៃ ផ.អ.គ.ស មានបរិយាយដោយសង្ខេបក្នុងតារាងដូចខាងក្រោម៖

**តារាងទី១៖ សង្ខេបគោលដៅលម្អិតតាមសមាសភាគនីមួយៗ នៃ ផ.អ.គ.ស**

| |
|---|
| **សមាសភាគទី ១ ៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា** |
| • លើកកម្ពស់តម្លាភាព គុណភាព ប្រសិទ្ធភាពឱ្យកាន់តែប្រសើរឡើងរបស់អង្គភាពផ្តល់សេវា<br>• ប្រជាពលរដ្ឋទទួលបានព័ត៌មានកាន់តែទូលំទូលាយស្តីពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងថវិកា |
| **សមាសភាគទី ២ ៖ ការត្រួតពិនិត្យ តាមដានដោយប្រជាពលរដ្ឋ** |
| • រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាទទួលបានព័ត៌មានកាន់តែទូលំទូលាយស្តីពីតម្រូវការជាអាទិភាព និងទស្សនៈនានារបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ។<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកផ្តល់សេវា និងប្រជាពលរដ្ឋកំណត់បាននូវសកម្មភាពជាអាទិភាពដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព។ |
| **សមាសភាគទី ៣ ៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)** |
| • ពង្រឹងការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីរួមចំណែកក្នុងការកែលម្អគុណភាព ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។ |
| **សមាសភាគទី ៤ ៖ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង** |
| • ពង្រឹងសមត្ថភាពប្រជាពលរដ្ឋក្នុងការចូលរួមយ៉ាងសកម្ម ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ |

| |
|---|
| ដើម្បីរួមចំណែកលើកកម្ពស់គុណភាព ប្រសិទ្ធភាព ក្នុងការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាព។ |
| • ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មជាមួយប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព ក្នុងការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាព។ |
| • អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការសង្គមស៊ីវិលមានឆន្ទៈ និងអាចដឹកនាំ សម្របសម្រួល ដំណើរការផ្សព្វផ្សាយ ត្រួតពិនិត្យ តាមដាន និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងគណនេយ្យភាពសង្គមប្រកបដោយគុណភាព និងប្រសិទ្ធភាព។ |
| • បង្កើត និងប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (ICT) តាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបទំនើប និងបែបប្រពៃណី ដើម្បីពង្រីកការគ្របដណ្តប់ ការផ្តល់ព័ត៌មានឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ។ |
| **សមាសភាគទី ៥ ៖ ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** |
| • កែសម្រួល និងរៀបចំគោលនយោបាយ គោលការណ៍ណែនាំ និងការអនុវត្តទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការតាមរយៈការរៀនសូត្រពីសកម្មភាពអនុវត្តការងារគណនេយ្យភាពសង្គម។ |

## ៤. វិសាលភាព និងអ្នកទទួលផល

### ក. វិសាលភាពតំបន់គោលដៅ

ផ.អ.គ.ស ដំណាក់កាលទី១ បានអនុវត្តលើរដ្ឋបាលឃុំចំនួន៨២៧ នៃឃុំសរុបចំនួន១.៤១០ ទូទាំងប្រទេស។ ក្នុងចំណោមឃុំទាំងនេះមានឃុំមួយចំនួនបានអនុវត្ត ផ.អ.គ.ស ចំនួន២ឆ្នាំ ចំណែកឃុំមួយចំនួនទៀតបានអនុវត្ត ផ.អ.គ.ស ចំនួន៣ឆ្នាំ។

ផ.អ.គ.ស ដំណាក់កាលទី២ មានគោលដៅអនុវត្តក្នុងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេសនៅត្រឹមឆ្នាំ២០២១។ វិសាលភាពតំបន់គោលដៅនៅក្នុងដំណាក់កាលទី២ នឹងត្រូវបានពង្រីកដល់តំបន់ទីប្រជុំជន (សូមមើល តារាងស្តីពីការបែងចែកចំនួនឃុំ សង្កាត់ដែលបានអនុវត្ត ផ.អ.គ.ស បានរយៈពេល ០ ១ ២ និង៣ឆ្នាំនៅដំណាក់កាលទី១ ព្រមទាំងការព្យាករណ៍ពីចំនួនឃុំ និងសង្កាត់ដែលនឹងត្រូវអនុវត្តនៅដំណាក់កាលទី២ សូមមើលឧបសម្ព័ន្ធ៤) ។ ប្រសិនបើពុំមានមូលនិធិគ្រប់គ្រាន់ដើម្បីសម្រេចគោលដៅនេះទេ ការពង្រីកតំបន់គ្របដណ្តប់ ផ.អ.គ.ស នឹងត្រូវផ្តោតអាទិភាពលើគោលដៅដែលបានអនុវត្តរយៈពេល៣ឆ្នាំរួចហើយ។

### ខ. វិសាលភាពសេវា

ផ.អ.គ.ស ដំណាក់កាលទី១ ផ្តោតតែលើសេវារដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាពនៅជនបទតែប៉ុណ្ណោះ។

ផ.អ.គ.ស ដំណាក់កាលទី២ នឹងបន្តការលើកកម្ពស់ ពង្រឹងគុណភាព ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព លើសេវាសំខាន់ៗទាំង៣ ដែលបានអនុវត្តនៅដំណាក់កាលទី១។ ចំណែកសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី២ នឹងត្រូវបានពង្រីកឱ្យគ្របដណ្តប់លើសេវានៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។ លើសពីនេះទៅទៀត ផ.អ.គ.ស ដំណាក់កាលទី២នេះ នឹងពង្រីកវិសាលភាពគ្រប ដណ្តប់លើសេវាមន្ទីរពេទ្យបង្អែក អនុវិទ្យាល័យ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ សេវាគ្រប់គ្រងសំរាម និងកាកសំណល់រឹងទីប្រជុំជន និងសេវាផ្សេងៗទៀត។ ការពង្រីកសេវាទាំងនេះនឹងត្រូវការធនធានថវិកាយ៉ាងច្រើន ហើយនឹងត្រូវចាប់ផ្តើមអនុវត្តសកម្មភាពសាកល្បងទៅតាមលទ្ធភាពធនធានដែលមាន។ ខ្លឹមសារសង្ខេបនៃវិសាលភាពសេវាក្នុង ផ.អ.គ.ស ដំណាក់កាលទី ១ និងការព្យាករណ៍ពីវិសាលភាពសេវាថ្មីៗក្នុង ផ.អ.គ.ស ដំណាក់កាលទី ២ (បង្ហាញក្នុងឧបសម្ព័ន្ធទី៥)។

សេវាផ្សេងៗទៀតដូចជា៖ ការគ្រប់គ្រងតំបន់ការពារធនធានធម្មជាតិ ការគ្រប់គ្រងព្រៃឈើ ការគ្រប់គ្រងជលផល ប័ណ្ណកម្មសិទ្ធិដីធ្លី កិច្ចគាំពារកុមារ មត្តេយ្យសិក្សា ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន កសិកម្ម ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ និងកិច្ចគាំពារសង្គមជាដើមគួរពិចារណាក្នុងការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២នេះផងដែរ។

### គ. អ្នកទទួលផល

ផ.អ.គ.ស ដំណាក់កាលទី១ (២០១៦-២០១៨) បានកំណត់យកស្ត្រី យុវជន និងក្រុមជនងាយរងគ្រោះនានាជាក្រុមគោលដៅ។ ផ.អ.គ.ស ដំណាក់កាលទី២ ក៏នៅតែផ្តោតលើក្រុមគោលដៅទាំងនោះ ព្រមទាំងលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្នដែលរួមមាន៖ ជនជាតិដើមភាគតិច មនុស្សចាស់ ជនពិការ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ស្រឡាញ់ទាំង២ភេទ ក្រុមប្តូរយេនឌ័រ (LGBT) និងសិស្សានុសិស្ស។

ការរៀបចំលម្អិត ផ.អ.គ.ស ដំណាក់កាលទី២ នឹងរួមបញ្ចូលការលើកកម្ពស់សមធម៌សង្គម និង បរិយាប័ន្នដោយជ្រើសរើសក្រុមជនងាយរងគ្រោះនានាធ្វើជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ផងដែរ។

## ៥. កិច្ចដំណើរការរៀបចំតាក់តែង ផ.អ.គ.ស ដំណាក់កាលទី ២

កិច្ចដំណើរការនៃការរៀបចំ ផ.អ.គ.ស ដំណាក់កាលទី២ (២០១៩-២០២៣) ត្រូវបានផ្តួចផ្តើមរៀបចំតាក់តែងឡើងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងផ្តល់ការគាំទ្រជំនួយបច្ចេកទេសពីធនាគារពិភពលោក ដោយផ្អែកលើចំណុចខ្លាំង ចំណុចខ្សោយ សមិទ្ធផល បញ្ហាប្រឈម និងមេរៀនបទពិសោធន៍ពីការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី ១។ វិធីសាស្ត្រសម្រាប់ការរៀបចំ ផ.អ.គ.ស នេះរួមមាន៖

- ការពិនិត្យឡើងវិញលើឯកសារមានស្រាប់ (ផ.អ.គ.ស ដំណាក់កាលទី១ របាយការណ៍វឌ្ឍនភាព និងការវាយតម្លៃផ្សេងៗ) (មាននៅក្នុងឧបសម្ព័ន្ធទី១ ឯកសារយោង)។
- ការសម្ភាសន៍ ការពិគ្រោះយោបល់ និងកិច្ចពិភាក្សាក្រុមគោលដៅជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងអ្នកពាក់ព័ន្ធ (មានបង្ហាញក្នុងឧបសម្ព័ន្ធទី២)។

ជារួម កិច្ចដំណើរការនៃការរៀបចំតាក់តែងឯកសារ ផ.អ.គ.ស ដំណាក់កាលទី២ ត្រូវបានចាប់ផ្ដើមពីខែមករាដល់ ខែធ្នូ ឆ្នាំ២០១៨ និងបែងចែកជា៤ជំហានសំខាន់ៗគឺ ៖

## ជំហានទី១៖

- ការរៀបចំឯកសារទស្សនទានដំបូងពាក់ព័ន្ធនឹង ផ.អ.គ.ស ដំណាក់កាលទី២និងផ្សព្វផ្សាយសម្រាប់ការពិនិត្យឡើងវិញ និងផ្ដល់មតិយោបល់ នៅខែ មករា ឆ្នាំ ២០១៨។
- រៀបចំពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន ដៃគូអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ និងអ្នកពាក់ព័ន្ធនឹង ផ.អ.គ.ស ដំណាក់កាលទី២ នៅខែកុម្ភៈ ឆ្នាំ ២០១៨។
- ផ្អែកតាមការផ្ដល់ព័ត៌មានត្រឡប់ដែលទទួលបានពីអ្នកពាក់ព័ន្ធខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនិងធនាគារពិភពលោក បានរៀបចំផែនការលម្អិតសម្រាប់រៀបចំ ផ.អ.គ.ស ដំណាក់កាលទី ២ នៅខែមីនា ឆ្នាំ ២០១៨។

## ជំហានទី២៖

- កិច្ចសម្ភាសន៍ និងពិភាក្សាជាមួយក្រុមគោលដៅ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀតក្នុងអំឡុងខែមេសា-មិថុនា ឆ្នាំ២០១៨។

## ជំហានទី៣៖

- ផ្អែកលើឯកសារដែលបានរៀបចំនៅជំហានទី២ លេខាធិការដ្ឋាន គ.ជ.អ.ប. និងធនាគារពិភពលោក បានរៀបចំជាសេចក្ដីព្រាងបឋមនៃឯកសារ ផ.អ.គ.ស ដំណាក់កាលទី២ ក្នុងអំឡុង ខែកក្កដា-សីហា ឆ្នាំ២០១៨ និងបានចែករំលែកដល់ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីផ្ដល់យោបល់ផងដែរ។
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ព្រមទាំងភាគីពាក់ព័ន្ធផ្សេងៗទៀត នៅខែកញ្ញា ឆ្នាំ ២០១៨ ដើម្បីប្រមូលបាននូវធាតុចូលសំខាន់ៗ។

## ជំហានទី៤៖

- សេចក្ដីព្រាងចុងក្រោយនៃឯកសារ ផ.អ.គ.ស ដំណាក់កាលទី២ ត្រូវបានដាក់ជូនកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស) ដើម្បីពិនិត្យ ពិភាក្សា និងអនុម័ត នៅខែមករា ឆ្នាំ២០១៩។
- ផ.អ.គ.ស ដំណាក់កាលទី២ ដែលបានអនុម័តដោយ គ.គ.អ.ស ត្រូវបានដាក់ជូន គ.ជ.អ.ប. ដើម្បីពិនិត្យ និងសម្រេចដាក់ឱ្យអនុវត្ត នៅខែវិច្ឆិកា ឆ្នាំ២០១៩។

ផ្អែកលើ ផ.អ.គ.ស ដំណាក់កាលទី២ ដែលបានអនុម័តដោយ គ.គ.អ.ស និង គ.ជ.អ.ប. លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តសម្របសម្រួលរៀបចំជាផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនីមួយៗជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ សម្រាប់ការអនុវត្តនូវ

សកម្មភាពជាគន្លឹះៗនានា ដោយមានការកំណត់ពីពេលវេលាជាក់លាក់ និងស្ថាប័នទទួលខុសត្រូវច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពទាំងនោះ ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកនានា និងគោលដៅជាគន្លឹះនៃផ.អ.គ.ស ដំណាក់កាលទី២។ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនីមួយៗនឹងក្លាយទៅជាមូលដ្ឋានក្នុងការរៀបចំអនុស្សារណៈយោគយល់គ្នារវាង លេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនិងអង្គការសង្គមស៊ីវិលដៃគូអនុវត្តនានា។

## ៦. វដ្តនៃសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី២ ប្រចាំឆ្នាំ

ផ.អ.គ.ស ត្រូវបានអនុវត្តតាមរយៈវដ្តនៃសកម្មភាពប្រចាំឆ្នាំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពនៅកម្រិតសហគមន៍មានដូចជាៈ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និង ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម។ សកម្មភាពទាំងនេះគាំទ្រតាមរយៈការអនុវត្តជាបន្តបន្ទាប់នូវ ការបណ្តុះបណ្តាល ការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រង ត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

ការកំណត់ពេលវេលាសម្រាប់អនុវត្តសកម្មភាពនានានៅក្នុងសមាសភាគនីមួយៗមានសារៈសំខាន់ណាស់ដើម្បីឱ្យសកម្មភាពទាំងនោះដើរស្របគ្នាជាមួយក្របខ័ណ្ឌពេលវេលានៃដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីទទួលបានអត្ថប្រយោជន៍ ជាអតិបរមា សកម្មភាពទាំងឡាយត្រូវបញ្ចូលនូវការពង្រឹងសមត្ថភាព ការផ្តល់យោបល់ត្រឡប់ និងការផ្តល់ធាតុចូលក្នុងប្រព័ន្ធអភិបាលកិច្ចនានានៅថ្នាក់មូលដ្ឋាន។

## រូបភាពទី១៖ វដ្តនៃសកម្មភាពផែនការអនុវត្តគណនេយ្យភាពសង្គម ប្រចាំឆ្នាំ ដំណាក់កាលទី២




## ៧. សមាសភាគ និងលទ្ធផលរំពឹងទុក

ផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានអនុម័តដាក់ចេញឱ្យអនុវត្តនូវយុទ្ធសាស្ត្រចំនួន៥ ដើម្បីសម្រេចបានគោលបំណងរួម គឺលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ពង្រឹងគុណភាព ប្រសិទ្ធភាព នៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

យុទ្ធសាស្ត្រទាំង៥ នៃផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមត្រូវបានរៀបចំទៅជាសមាសភាគចំនួន៥នៅក្នុង ផ.អ.គ.ស ដំណាក់កាលទី២ (២០១៩-២០២៣) មានដូចខាងក្រោម៖

## តារាងទី២៖ ការរៀបចំយុទ្ធសាស្ត្រទៅជាសមាសភាគសម្រាប់អនុវត្ត

| ផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គម | សមាសភាគនៃផែនការអនុវត្តរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ដំណាក់កាលទី២ |
|---|---|
| **យុទ្ធសាស្ត្រទី១ ៖ ព័ត៌មាន**<br>ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មានអំពីស្តង់ដា ថវិកា និងការបំពេញការងារ | **សមាសភាគទី១ ៖**<br>តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា |
| **យុទ្ធសាស្ត្រទី២ ៖ ការត្រួតពិនិត្យតាមដាន**<br>ការសម្របសម្រួល ឱ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ ទៅលើសកម្មភាពបំពេញការងារ និងការផ្តល់សេវាកម្មមូលដ្ឋាន របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **សមាសភាគទី២ ៖**<br>ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ<br>**សមាសភាគទី៣ ៖**<br>ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) |
| **យុទ្ធសាស្ត្រទី៣ ៖ ការងារថវិកា**<br>ការលើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកា | **បញ្ចូលទៅក្នុងសមាសភាគទី១ ៖**<br>តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា |
| **យុទ្ធសាស្ត្រទី៤ ៖ ការសម្របសម្រួលការចូលរួម**<br>ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាពដល់តួអង្គទាំងនោះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម។ | **សមាសភាគទី៤ ៖**<br>ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង |
| **យុទ្ធសាស្ត្រទី៥ ៖ ការសិក្សារៀនសូត្រស្វែងយល់**<br>ការប្រមូលមេរៀនបទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន ដើម្បីប្រែក្លាយបទពិសោធន៍ទាំងនេះដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងពង្រឹងការបំពេញការងារអង្គការសង្គមស៊ីវិលនានា។ | **សមាសភាគទី៥ ៖**<br>ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ |

សមាសភាគទាំង៥មានទំនាក់ទំនង និងបំពេញគ្នាទៅវិញទៅមក ហើយសមាសភាគនីមួយៗមានការចូលរួមអនុវត្តដោយតួអង្គទាំងពីរ (រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ)។ សមាសភាគទាំង៥មានពន្យល់លម្អិតដូចខាងក្រោម៖

១) **តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា៖** មានគោលបំណងពង្រឹងភាពងាយទទួលបានព័ត៌មានសាធារណៈរបស់ប្រជាពលរដ្ឋ (រួមមានព័ត៌មានការបំពេញការងារ និងព័ត៌មានថវិកា) និងការបង្កើនសមត្ថភាពរបស់ប្រជាពលរដ្ឋឱ្យបានយល់ដឹង និងប្រើប្រាស់ព័ត៌មានទាំងនោះ។

**២) ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ៖** មានគោលបំណងឱ្យប្រជាពលរដ្ឋអាចធ្វើការត្រួតពិនិត្យ វាយតម្លៃលើការផ្តល់សេវាសាធារណៈ ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិភាគលើព័ត៌មានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលនៃការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ នឹងត្រូវចែករំលែកជាមួយអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយនិងប្រើប្រាស់សម្រាប់រៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមតាមរយៈកិច្ចប្រជុំរួម។

**៣) ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម៖** មានគោលបំណងគាំទ្រការអនុវត្ត និងតាមដានការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់គុណភាព ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ។ ភាគីទាំងអស់ត្រូវធានាឱ្យមានការបញ្ចូលសកម្មភាព ផ.ស.រ.គ ទៅក្នុងដំណើរការកសាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការធ្វើសេចក្តីសម្រេចនានារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

**៤) ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង៖** មានគោលបំណងផ្តល់ការបណ្តុះបណ្តាល ផ្តល់ការប្រឹក្សាយោបល់ និងផ្តល់ការហ្វឹកហ្វឺននានាដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសង្គមស៊ីវិល បុគ្គលិក សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងអ្នកផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង សំដៅគាំទ្រដល់សកម្មភាពសំខាន់ៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព និងការផ្តល់ព័ត៌មានឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធ និងសាធារណៈជន។

**៥) ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖** មានគោលបំណងបង្កើតឱ្យមានយន្តការរៀនបណ្តើរ អនុវត្តបណ្តើរ។ លទ្ធផលនៃការត្រួតពិនិត្យតាមដានដែលរកឃើញនៅសហគមន៍មូលដ្ឋាន នឹងប្រែក្លាយជាធាតុចូលសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការកែលម្អគោលនយោបាយ គោលការណ៍ណែនាំនានា និងការអនុវត្តការងារជាក់ស្តែង។

**តារាងទី៣៖ សង្ខេបសមាសភាគ សមិទ្ធផល និងលទ្ធផលរំពឹងទុក នៃ ផ.អ.គ.ស ដំណាក់កាលទី២**

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក |
|---|---|
| **សមាសភាគទី១ ÷ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា** | |
| ១.១. តម្លាភាពអំពីថវិកា និងការបំពេញការងាររបស់អង្គភាពផ្តល់សេវាកាន់តែល្អប្រសើរ | ១.១.១.ការបើកចំហព័ត៌មាននានា និងព័ត៌មានថវិកា<br>១.១.២.ការប្រើប្រាស់ព័ត៌មានឱ្យបានទូលំទូលាយនិងស៊ីជម្រៅ |
| ១.២. ប្រជាពលរដ្ឋទទួលបានព័ត៌មាន កាន់តែទូលំទូលាយស្តីពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងថវិកា | ១.២.១.ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ ស្តីពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងថវិកា។ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក |
|---|---|
| **សមាសភាគទី២ ÷ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ** | |
| ២.១. រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាទទួលបានព័ត៌មានកាន់តែទូលំទូលាយស្តីពីអាទិភាពរបស់ប្រជាពលរដ្ឋ និងទស្សនៈនានាដែលពាក់ព័ន្ធទៅនឹងអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈនានា | ២.១.១.ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ<br>២.១.២.ការរៀបចំលិខិតបទដ្ឋាននានា ដើម្បីគាំទ្រការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ |
| ២.២. រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋកំណត់បានជារួមស្តីពីសកម្មភាពជាអាទិភាពចាំបាច់ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈនៅមូលដ្ឋានប្រកបដោយគុណភាព និងប្រសិទ្ធភាព | ២.២.១.កិច្ចប្រជុំរួម |
| **សមាសភាគទី៣ ÷ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** | |
| ៣.១. ការអនុវត្ត និងការតាមដានផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីកែលម្អគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ | ៣.១.១.ការអនុវត្តផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម<br>៣.១.២.ការតាមដានការអនុវត្តផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម |
| ៣.២. ទិន្នន័យស្តីពីសកម្មភាពជាអាទិភាពសម្រាប់កែលម្អក្នុងវិស័យនីមួយៗ ត្រូវបានធ្វើការវិភាគ និងប្រើប្រាស់ដើម្បីតាក់តែងគោលនយោបាយ | ៣.២.១.ទិន្នន័យផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គមត្រូវបានវិភាគ និងប្រើប្រាស់យ៉ាងទូលំទូលាយ |
| **សមាសភាគទី៤ ÷ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង** | |
| ៤.១.សមត្ថភាពរបស់ផ្នែកតម្រូវការ(អង្គការសង្គមស៊ីវិល) ក្នុងការចូលរួមយ៉ាងសកម្មដើម្បីរួមចំណែកពង្រឹងគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាពត្រូវបានលើកកម្ពស់ | ៤.១.១.ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាពអង្គការសង្គមស៊ីវិល |
| ៤.២.សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មជាមួយប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាពត្រូវបានពង្រឹង | ៤.២.១.ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាពរបស់អង្គភាពផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.២.២.ការបណ្តុះបណ្តាលដល់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក |
|---|---|
| ៤.៣.អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មានឆន្ទៈ និងអាចដឹកនាំដំណើរការផ្សព្វផ្សាយព័ត៌មាននានា ពិនិត្យតាមដាន និងជំរុញការចូលរួមពីសំណាក់ប្រជាពលរដ្ឋដែលពាក់ព័ន្ធទៅនឹងគណនេយ្យភាពសង្គមប្រកបដោយគុណភាព ប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន | ៤.៣.១.ការបណ្តុះបណ្តាល ណែនាំ និងហ្វឹកហ្វឺនអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍<br>៤.៣.២.តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានបង្កើត និងដំណើរការ |
| ៤.៤.ការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ ស្តីពី ផ.អ.គ.ស | ៤.៤.១.ផែនការអនុវត្តគណនេយ្យភាពសង្គម ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងក្រសួង ស្ថាប័ន អង្គភាពសាមី និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| **សមាសភាគទី៥ ÷ ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | |
| ៥.១. ធានាការអនុវត្ត ផ.អ.គ.ស ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | ៥.១.១. ការគ្រប់គ្រង និងគាំទ្រការអនុវត្ត ផ.អ.គ.ស នឹងត្រូវបានរៀបចំឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីធានាការអនុវត្តប្រកបដោយលទ្ធផលល្អប្រសើរ |
| ៥.២.ការកែសម្រួលមួយចំនួនលើគោលនយោបាយ គោលការណ៍ណែនាំ ដោយផ្អែកលើមេរៀនបទពិសោធន៍ នៃការអនុវត្តសកម្មភាព ផ.អ.គ.ស | ៥.២.១. ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់<br>៥.២.២. ការតាមដាន ត្រួតពិនិត្យ និងការចងក្រងមេរៀនបទពិសោធន៍ |

## ៨. ថវិកាប៉ាន់ស្មានរបស់ ផ.អ.គ.ស ដំណាក់កាលទី២

ក្នុងរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ថវិកាដែលនឹងគ្រោងចំណាយក្នុងការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ មានចំនួនប្រមាណ ៣២.៥២២.៦២៣ ដុល្លារអាមេរិក ដែលក្នុងនោះថវិកាចំនួន ១២.៣៦០.៨៨១ ដុល្លារអាមេរិក (៤១%) សម្រាប់ផ្នែកផ្គត់ផ្គង់ និងថវិកាចំនួន ១៧.៦១៣.០៤៦ ដុល្លារអាមេរិក (៥៩%) សម្រាប់ផ្នែកតម្រូវការ រីឯថវិកាចំនួន ១.០០០.០០០ដុល្លារអាមេរិកទៀត សម្រាប់ការងាររដ្ឋបាលក្នុងការប្រតិបត្តិការមូលនិធិបរធនបាលកិច្ច (Trust Fund) និងថវិកាចំនួន ១.៥៤៨.៦៩៥ ដុល្លារអាមេរិកសម្រាប់ការចំណាយផ្សេងៗទៀតលើប្រតិបត្តិការមូលនិធិបរធនបាលកិច្ច។

# ជំពូកទី២

# សមាសភាគផែនការអនុវត្ត

# គណនេយ្យភាពសង្គមដំណាក់កាលទី២

## ជំពូកទី២ ÷ សមាសភាគផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២

ជំពូកនេះ គឺជាជំពូកមួយដ៏សំខាន់នៃឯកសារ ផ.អ.គ.ស ដំណាក់កាលទី ២ ដែលរៀបរាប់អំពីសមាសភាគទាំង៥នៃ ផ.អ.គ.ស ព្រមទាំងសមិទ្ធផល និងលទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេចឱ្យបានក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ សមាសភាគទាំង៥រួមមាន ៖

**១. តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា**

**២. ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ**

**៣. ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)**

**៤. ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង**

**៥. ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។**

ក្នុងសមាសភាគនីមួយៗ រួមមានសេចក្តីផ្តើម ការបរិយាយអំពីវឌ្ឍនភាព បញ្ហាប្រឈម សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក និងថវិកាប៉ាន់ស្មាន។

ក្នុងលទ្ធផលរំពឹងទុកនីមួយៗមានសង្ខេបអំពីគោលដៅ សកម្មភាពជាចម្បងៗ និងស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត ដើម្បីធានាឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនោះ។

## សមាសភាគទី១

## តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា

## ក. សេចក្ដីផ្ដើម

**សមាសភាគទី១** មានគោលបំណងលើកកម្ពស់តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកាដែលជាសមាសធាតុដ៏សំខាន់ នៃដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម។ ប្រសិនបើពុំមានព័ត៌មានអំពីស្តង់ដានៃសេវាប្រជាពលរដ្ឋមិនអាចដឹងបានថាតើមានសេវាអ្វីខ្លះដែលត្រូវផ្តល់ ឬសេវាអ្វីខ្លះដែលត្រូវស្នើសុំ ដែលទាក់ទងនឹងសុខភាព ការអប់រំ និងសេវានានាពីអ្នកផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការចែករំលែកនូវព័ត៌មានទៅវិញទៅមក នឹងនាំឱ្យមានការយោគយល់គ្នា ការទំនាក់ទំនងល្អ និងធ្វើសកម្មភាពរួមគ្នាកាន់តែប្រសើរឡើង។ ប្រសិនបើប្រជាពលរដ្ឋមិនបានទទួលព័ត៌មានច្បាស់លាស់ មិនមានលក្ខណៈជាប្រព័ន្ធ និងមិនទាន់ពេលវេលានោះ ប្រជាពលរដ្ឋក៏ពុំអាចចូលរួមក្នុងដំណើរការអនុវត្តគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាពបានទេ។

សកម្មភាពនានាដែលមានក្នុងសមាសភាគទី១នេះ ត្រូវអនុវត្តចាប់ផ្តើមពីខែមករា រហូតដល់ខែមីនា នៃឆ្នាំនីមួយៗ។

## ខ. វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ

ការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ ក្នុងក្របខ័ណ្ឌនៃសមាសភាគទី១ ទាក់ទងនឹងភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកានេះបានទទួលនូវលទ្ធផលល្អប្រសើរជាវិជ្ជមានសំខាន់ៗដូចខាងក្រោម៖

- កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ I4Cs (ដែលផ្តល់ព័ត៌មានពីសិទ្ធិ ស្តង់ដា ថវិកា និងការបំពេញការងារពាក់ព័ន្ធនឹងសេវានៅរដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) ត្រូវបានរៀបចំ ចងក្រងឡើង និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ។
- ការណែនាំផ្លូវការពាក់ព័ន្ធនឹងការប្រមូលទិន្នន័យប្រចាំឆ្នាំ និងការដាក់បង្ហាញទិន្នន័យលទ្ធផលបំពេញការងារ និងថវិការបស់អង្គភាពផ្តល់សេវាត្រូវបានរៀបចំឡើង និងផ្សព្វផ្សាយទូលំទូលាយជូនដល់ប្រជាពលរដ្ឋជាសាធារណៈ។
- មន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ខេត្ត ស្រុក ឃុំ និងមូលដ្ឋានចំនួន ៧.២០០ នាក់បានទទួលការបណ្តុះបណ្តាលស្តីពីការបំពេញទម្រង់ ប្រមូល បញ្ចូលទិន្នន័យលទ្ធផលបំពេញការងារ I4Cs និងដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម។
- ទិន្នន័យ I4Cs ត្រូវបានប្រមូល បិទផ្សព្វផ្សាយ និងចែកចាយជារៀងរាល់ឆ្នាំដល់រដ្ឋបាលឃុំសរុបចំនួន៨២៧ សាលាបឋមសិក្សាចំនួន៤.១០៧ និងមណ្ឌលសុខភាពចំនួន៦០៥។

- ការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងការបើកចំហព័ត៌មានថវិកា តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ ត្រូវបានរៀបចំឡើងក្នុងឃុំគោលដៅទាំងអស់៨២៧ ដោយមានប្រជាពលរដ្ឋចូលរួមសរុបជាង៥៥៤.០០០ នាក់ (ស្ត្រី ៧២%)។

ទន្ទឹមនឹងទទួលបានលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ ក៏នូវមាននៅបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរៀបចំកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) នៅមានចំណុចមួយចំនួនគួរកែលម្អ ដើម្បីឱ្យ I4Cs កាន់តែមានភាពសាមញ្ញ និងងាយយល់ (ឧ. ខ្លឹមសារមួយចំនួននៃI4Cs ដែលទាក់ទងនឹងព័ត៌មានថវិកា)។ ព័ត៌មានបន្ថែមមួយចំនួន ដូចជាព័ត៌មានលម្អិតអំពីសេវា ព័ត៌មានលម្អិតអំពីទំនាក់ទំនង ក៏អាចពង្រឹងអត្ថប្រយោជន៍ I4Cs ផងដែរ។
- ដំណើរការប្រមូលទិន្នន័យលទ្ធផលការងារ (Post-On) ត្រូវចំណាយពេលយូរ ដែលធ្វើឱ្យមានការយឺតយ៉ាវក្នុងការបិទផ្សាយ I4Cs ក្នុងដំណាក់កាលទី១។ ដូច្នេះចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងរៀបចំដំណើរការនៃការប្រមូល និងបញ្ចូលទិន្នន័យ។ ក្រសួងសាមីត្រូវទទួលខុសត្រូវលើការប្រមូលទិន្នន័យលទ្ធផលការងារ (Post-On) សម្រាប់ផ្នែករបស់ខ្លួន និងប្រើប្រាស់របៀបបញ្ចូលទិន្នន័យអេឡិចត្រូនិកដោយផ្ទាល់ ដើម្បីធានាឱ្យមានភាពត្រឹមត្រូវនៃទិន្នន័យ I4Cs ត្រូវពង្រឹងដំណើរការពិនិត្យឡើងវិញ។
- ការផ្សព្វផ្សាយ I4Cs មានចំណុចត្រូវកែលម្អមួយចំនួនដើម្បីបង្កើនគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ទោះបីជាមានប្រជាពលរដ្ឋជាង ៥៥៤.០០០ នាក់ បានចូលរួមក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងអំពី I4Cs នៅដំណាក់កាលទី១ក្តី ក៏ប៉ុន្តែតួលេខនេះនៅតែបង្ហាញថាមានប្រជាពលរដ្ឋក្នុងឃុំគោលដៅតិចតួចប៉ុណ្ណោះដែលបានចូលរួម។ ដូច្នេះត្រូវពង្រឹងប្រសិទ្ធភាពសកម្មភាពលើកកម្ពស់ការយល់ដឹង និងពង្រីកការផ្សព្វផ្សាយទិន្នន័យ I4Cs តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន។
- ការប្រើប្រាស់បណ្តុំទិន្នន័យ I4Cs ទិន្នន័យលទ្ធផលការងារ (Post-On) បង្ហាញពីបណ្តុំព័ត៌មានទាំងសម្រាប់ប្រជាពលរដ្ឋ និងតួអង្គរដ្ឋ។ ក្រៅពីការបិទផ្សាយ និងការផ្សព្វផ្សាយលទ្ធផលរកឃើញពី I4Cs នៅថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវប្រើប្រាស់ប្រព័ន្ធ និងអនុវត្តសកម្មភាពប្រកបដោយនិរន្តរភាពដើម្បីធានាបានថា លទ្ធផល I4Cs ត្រូវបានកត់ត្រាទុក និងវិភាគដើម្បីដកស្រង់ខ្លឹមសារសំខាន់ៗ និងផ្តល់ព័ត៌មានដល់ការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវា និងកំណែទម្រង់គោលនយោបាយ។

ផ្អែកតាមមេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនៃការអនុវត្ត ផ.អ.គ.ស នៅដំណាក់កាលទី ១ ដូចបានរៀបរាប់ខាងលើ បានជួយកំណត់រកចំណុចកែលម្អនានា ហើយការកែសម្រួល និងចំណុចថ្មីៗសម្រាប់សមាសភាគទី១ ក្នុង ផ.អ.គ.ស ដំណាក់កាលទី ២ នឹងរួមបញ្ចូលចំណុចសំខាន់ៗមានដូចខាងក្រោម៖

- ***បញ្ជ្រាបដំណើរការប្រមូលទិន្នន័យលទ្ធផលបំពេញការងារសម្រាប់កញ្ចប់ព័ត៌មានប្រជាពលរដ្ឋ៖*** ដើម្បីបង្កើនស័ក្តិសិទ្ធភាព និងនិរន្តរភាពនៃការប្រមូលទិន្នន័យ និងបញ្ចៀសការពន្យារពេលផ្សព្វផ្សាយទិន្នន័យលទ្ធផលបំពេញការងារ ផ.អ.គ.ស ដំណាក់កាលទី២ នឹងប្រើប្រាស់ប្រព័ន្ធផ្អែកតាមបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (ICT) សម្រាប់ការដាក់បញ្ជូនទិន្នន័យលទ្ធផលបំពេញការងារប្រចាំឆ្នាំដោយអ្នកផ្តល់សេវាមូលដ្ឋាន (ដោយប្រើប្រាស់កុំព្យូទ័រ ឬទូរស័ព្ទសម្រាប់បញ្ជូនទិន្នន័យ)។
- ***ការពិនិត្យតាមដាន និងការរាយការណ៍ពីលទ្ធផលបំពេញការងារដោយក្រសួងសាមីមានលក្ខណៈផ្លូវការ៖*** ខណៈដែលលទ្ធផលបំពេញការងារធៀបនឹងស្តង់ដាសេវា និងការប្រើប្រាស់ហិរញ្ញវត្ថុត្រូវបានពិនិត្យតាមដាននៅកម្រិតមួយដោយក្រសួងសាមីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងថ្នាក់ជាតិ ព័ត៌មានទាំងនេះមិនត្រូវបានប្រើប្រាស់ជាប្រព័ន្ធដោយក្រសួងនានាដើម្បីឆ្លើយតបនឹងចំណុចខ្វះខាតក្នុងលទ្ធផលការងារនៅថ្នាក់មូលដ្ឋាន ឱ្យបានទូលំទូលាយឡើយ។ យន្តការពិនិត្យឡើងវិញ នឹងត្រូវបានពង្រឹង បូករួមនឹងការពិនិត្យតាមដានការប្រមូល បញ្ចូល ការចែករំលែក និងការបិទផ្សាយព័ត៌មានបានទាន់ពេលវេលានៅទីតាំងអង្គភាពផ្តល់សេវា ដោយមានការគាំទ្រពីមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុង ផ.អ.គ.ស ដំណាក់កាលទី២ ក្រសួង ស្ថាប័នសាមីនឹងទទួលខុសត្រូវលើការផលិត និងចែកចាយផ្ទាំង I4Cs ដោយមានការគាំទ្រ និងការត្រួតពិនិត្យពីលេខាធិការដ្ឋាន គ.ជ.អ.ប.។
- ***ការពិនិត្យឡើងវិញ និងកែសម្រួលខ្លឹមសារ I4Cs ៖*** ដើម្បីធានាថា I4Cs ងាយស្រួលយល់ និងបន្សុីគ្នានឹងស្តង់ដាសេវាសំខាន់ៗ ហើយទិន្នន័យជួយដល់ការប៉ាន់ប្រមាណលទ្ធផលបំពេញការងារដោយប្រសិទ្ធភាព ក្រសួងសាមីនឹងធ្វើការកែសម្រួល និងដាក់បញ្ចូលចំណុចថ្មីៗក្នុង ផ.អ.គ.ស ដំណាក់កាលទី២។ ការកែសម្រួលបន្ថែមរួមមាន ១) ការធ្វើឱ្យព័ត៌មានថវិកាចំណូល និងចំណាយមានភាពសាមញ្ញ ២) ការដាក់បញ្ចូលព័ត៌មានសង្ខេបស្តីពីការវិភាជថវិកាជាតិដល់វិស័យគោលដៅ ៣) ការដាក់បញ្ចូលឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់សមាជិកក្រុមប្រឹក្សាឃុំ ប្រធានមណ្ឌលសុខភាព នាយកសាលាបឋមសិក្សា និងអ្នកផ្តល់សេវានានា និង ៤) រួមបញ្ចូលព័ត៌មានស្តីពីសូចនាករសំខាន់ៗផ្សេងទៀត។ រាល់ការកែប្រែខ្លឹមសារ I4Cs នឹងត្រូវបានពិនិត្យឡើងវិញ និងអនុម័តដោយ គ.គ.អ.ស ។
- ***ការបង្កើត I4Cs សម្រាប់អនុវត្តលើសេវាថ្មីៗ ៖*** ក្នុងដំណាក់កាលទី២ ផ.អ.គ.ស នឹងត្រូវបានពង្រីកឱ្យគ្របដណ្តប់លើសេវាថ្មីៗ ដូចជា រដ្ឋបាលសង្កាត់ ក្រុង ស្រុក ខណ្ឌ ទឹកស្អាត អនាម័យ សាលាមធ្យមសិក្សា និងមន្ទីរពេទ្យបង្អែក។ ការបង្កើត I4Cs សម្រាប់សេវាថ្មីៗទាំងនេះនឹងពាក់ព័ន្ធ ១) ការប្រមូលព័ត៌មាន I4Cs ស្តីពីការទទួលខុសត្រូវ ស្តង់ដាសេវា និងថវិកាសម្រាប់សេវានីមួយៗ និង ២) ការបង្កើតផ្ទាំង I4Cs និងទម្រង់ទិន្នន័យលទ្ធផលបំពេញការងារសម្រាប់សេវានីមួយៗ។

- ***ធានាសុក្រឹតភាពនៃទិន្នន័យលទ្ធផលបំពេញការងារ (Post-On)៖*** ដើម្បីធានាសុក្រឹតភាពនៃទិន្នន័យលទ្ធផលបំពេញការងារ (Post-On) ដំណាក់កាលទី២ ត្រូវធានា ១) អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ឬអង្គការសង្គមស៊ីវិលចូលរួមពិនិត្យឡើងវិញលើទិន្នន័យលទ្ធផលបំពេញការងារ (Post-On) និង ២) បង្កើតយន្តការច្បាស់លាស់ដើម្បីរួមគ្នាដោះស្រាយ នៅពេលមានបញ្ហាពាក់ព័ន្ធនឹងសុក្រឹតភាពនៃទិន្នន័យលទ្ធផលការងារ។
- ***កែលម្អ និងពង្រីកការផ្សព្វផ្សាយពី I4Cs ឱ្យកាន់តែទូលំទូលាយ៖*** ដើម្បីបង្កើន និងពង្រីកការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងសារធារណជន ផ.អ.គ.ស ដំណាក់កាលទី២ រួមមាន៖ ១) ផ្សព្វផ្សាយពី I4Cs តាមរយៈទូរស័ព្ទ ប្រព័ន្ធផ្សព្វផ្សាយសង្គម ២) ផ្សព្វផ្សាយ I4Cs តាមរយៈប្រធានភូមិ អង្គការសហគមន៍មូលដ្ឋាន និងវេទិកាផ្សេងៗនៅតាមសហគមន៍ ៣) កែសម្រួលសៀវភៅណែនាំស្ដីពីកិច្ចប្រតិបត្តិការសម្រាប់បង្កើនការយល់ដឹងអំពី I4Cs ផ្អែកលើមេរៀនបទពិសោធន៍ដែលបានអនុវត្តក្នុងដំណាក់កាលទី១ ៤) បង្កើនការយកចិត្តទុកដាក់លើការយល់ដឹងអំពីថវិកា និង ៥) លើកកម្ពស់ការចូលរួមឱ្យមានតុល្យភាពរវាងស្ត្រី និងបុរស និងបង្កើនការចូលរួមរបស់ក្រុមងាយរងគ្រោះ (ឧ. ជនក្រីក្រ ជនពិការ មនុស្សចាស់ ជនជាតិដើមភាគតិច អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ស្រឡាញ់ទាំង២ភេទ ក្រុមប្តូរយេនឌ័រ)។
- ***បង្កើនជាអតិបរមានូវការប្រើប្រាស់ទិន្នន័យ I4Cs ៖*** នៅដំណាក់កាលទី២ ផ.អ.គ.ស មានគោលបំណងប្រើប្រាស់បណ្តុំទិន្នន័យ I4Cs ឱ្យកាន់តែទូលំទូលាយ និងប្រកបដោយយុទ្ធសាស្ត្រ។ ទិន្នន័យ I4Cs ត្រូវបានវិភាគ ចែករំលែក និងប្រើប្រាស់ដោយប្រសិទ្ធភាព ដូចជា៖ ១) មានប្រព័ន្ធអេឡិចត្រូនិកដ៏ល្អសម្រាប់ការផ្ទៀងផ្ទាត់លទ្ធផល I4Cs ២) ការវិភាគទិន្នន័យ I4Cs រាល់ឆ្នាំ និងការរៀបចំរបាយការណ៍សម្រាប់ដាក់ជូន គ.គ.អ.ស គ.ជ.អ.ប. ក្រសួង ស្ថាប័នសាមី និងសាធារណជន និង ៣) ការបង្ហាញ និងពិភាក្សាអំពីលទ្ធផល I4Cs ក្នុងកិច្ចប្រជុំថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងវេទិកាសាធារណៈ។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបចំពោះចំណុចដែលត្រូវកែលម្អឆ្លងតាមមេរៀនបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមកក្នុងដំណាក់កាលទី១ សមិទ្ធផល និងលទ្ធផលរំពឹងទុកពាក់ព័ន្ធទៅនឹងសមាសភាគទី១ត្រូវបានកំណត់ និងបរិយាយមានដូចខាងក្រោម៖

## សមិទ្ធផលរំពឹងទុកទី១.១÷ តម្លាភាពអំពីថវិកានិងការបំពេញការងាររបស់អង្គភាពផ្តល់សេវាកាន់តែប្រសើរ

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន០២ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ១.១.១ ការបើកចំហព័ត៌មាននានា និងព័ត៌មានថវិកា**

**សកម្មភាពជាចម្បង**

- រៀបចំឡើងកិច្ចប្រជុំតម្រង់ទិសដើម្បីអនុវត្តការងារគណនេយ្យភាពសង្គម
- ផលិត និងចែកចាយផ្ទាំង I4Cs ដល់អង្គភាពផ្តល់សេវាដែលពាក់ព័ន្ធ
- បោះពុម្ព ចែក បំពេញ ប្រមូល ទម្រង់ទិន្នន័យលទ្ធផលបំពេញការងារ និងថវិកា និងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្ម (online)។
- បង្កើតឡើងនូវគោលការណ៍ណែនាំ និងចូលរួមពិនិត្យ ទិន្នន័យលទ្ធផលបំពេញការងារ និងថវិកា ដែលបានបោះពុម្ព ដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការសង្គមស៊ីវិល។
- បង្កើតឡើង សាកល្បង និងអនុវត្តប្រព័ន្ធសម្រាប់ប្រមូលទិន្នន័យលទ្ធផលបំពេញការងារដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរស័ព្ទ និងប្រព័ន្ធអេឡិចត្រូនិក។
- ក្រសួងសាមីប្រើប្រាស់ប្រព័ន្ធនានា និងគោលការណ៍ណែនាំ និងបែងចែកថវិកាសម្រាប់ការផលិត និងចែកចាយផ្ទាំង I4Cs និងការប្រមូល ការបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ និងការបិទផ្សាយទិន្នន័យលទ្ធផលបំពេញការងារជាសាធារណៈ។
- ក្រសួងសាមី និង គ.គ.អ.ស ពិនិត្យឡើងវិញនូវខ្លឹមសារ និងទម្រង់ថវិកា ហើយកែសម្រួល និងបន្ថែមចំណុចថ្មីៗទៅតាមភាពសមស្រប។
- បិទផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងទិន្នន័យលទ្ធផលបំពេញការងារ និងថវិកាជាសាធារណៈនៅតាមទីតាំងអង្គភាពផ្តល់សេវាទាំងអស់។
- បង្កើតឡើង សាកល្បង និងអនុវត្តប្រព័ន្ធសម្រាប់ផ្សព្វផ្សាយសារ I4Cs សំខាន់ៗតាមអេឡិចត្រូនិក (សារខ្លីៗ អ៊ីម៉ែល អ៊ីនធើណែត រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម)។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយ នៃសាលាបឋមសិក្សាដែលបិទផ្សាយ និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំអំពីព័ត៌មាន I4Cs | ៥០% | ៦០% | ៧០% | ៨០% | ៩០% |
| ភាគរយ នៃមណ្ឌលសុខភាព ដែលបិទផ្សាយ និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំអំពីព័ត៌មាន I4Cs | ៥០% | ៦០% | ៧០% | ៨០% | ៩០% |

| | | | | | |
|---|---|---|---|---|---|
| ភាគរយ នៃឃុំ សង្កាត់ ដែលបិទផ្សាយ និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំអំពីព័ត៌មាន I4Cs | ៦៥% | ៧៥% | ៨០% | ៨៥% | ៩០% |

## ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រ និងសម្របសម្រួលរបស់ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល និងក្រុមការងារមូលនិធិបរធនបាលកិច្ច។

## លទ្ធផលរំពឹងទុក ១.១.២៖ ការប្រើប្រាស់ព័ត៌មានឱ្យបានទូលំទូលាយ និងស៊ីជម្រៅ

## សកម្មភាពជាចម្បង

- រៀបចំជារៀងរាល់ឆ្នាំសម្រាប់ការពិនិត្យឡើងវិញ ឬពិភាក្សាក្នុងក្រសួង ស្ថាប័នសាមី គ.គ.អ.ស គ.ជ.អ.ប. និងអង្គភាពសាមីនូវរបាយការណ៍វិភាគស្តីពីបណ្តុំទិន្នន័យ I4Cs។
- បង្ហាញ និងពិភាក្សាអំពីលទ្ធផល I4Cs ក្នុងកិច្ចប្រជុំថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងវេទិកាសាធារណៈដោយមានវត្តមានអ្នកឯកទេសតាមវិស័យ។

## ចំណុចដៅ

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការរៀបចំរបាយការណ៍វិភាគប្រចាំឆ្នាំ ស្តីពីបណ្តុំទិន្នន័យ I4Cs សម្រាប់ដាក់ជូន គ.គ.អ.ស គ.ជ.អ.ប. និងក្រសួងស្ថាប័នសាមី | ✓ | ✓ | ✓ | ✓ | ✓ |

## ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល អង្គការសង្គមស៊ីវិល និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.គ.អ.ស។

## សមិទ្ធផលរំពឹងទុកទី១.២៖ ប្រជាពលរដ្ឋទទួលបានព័ត៌មានកាន់តែទូលំទូលាយស្តីពីសិទ្ធិ ស្តង់ដារ ការបំពេញការងារ និងថវិកា

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន០១ ដូចខាងក្រោម៖

## លទ្ធផលរំពឹងទុក ១.២.១៖ ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពីសិទ្ធិ ស្តង់ដាការបំពេញការងារ និងថវិកា

**សកម្មភាពជាចម្បង**

- រៀបចំកិច្ចប្រជុំ និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ។
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីទិន្នន័យលទ្ធផលបំពេញការងារ និងថវិការួមបញ្ចូលការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបទំនើប និងប្រពៃណី។
- បង្កើតឡើង សាកល្បង និងអនុវត្តវិធីសាស្ត្រសម្រាប់ជួយឱ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្រើនអំពីថវិកាសាធារណៈ។
- រៀបចំលិខិតបទដ្ឋាននានា ដើម្បីធានាដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយ នៃប្រជាពលរដ្ឋ (ប្រុស/ស្រី) ដែលចូលរួមក្នុងដំណើរការ ផ.អ.គ.ស នឹងយល់ដឹងយ៉ាងតិចស្តង់ដារ ចំនួន២ក្នុងចំណោម៦ សម្រាប់សេវានីមួយៗ (រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព )។ | ៥០% | ៥៥% | ៦០% | ៦៥% | ៧០% |
| ភាគរយ នៃប្រជាពលរដ្ឋ (ប្រុស/ស្រី) ដែលចូលរួមក្នុងដំណើរការ ផ.អ.គ.ស នឹងយល់ដឹងអំពីកំណើន ឬការថយចុះនៃថវិកាពីមួយឆ្នាំ ទៅមួយឆ្នាំសម្រាប់សេវាយ៉ាងតិច២ (ក្នុងចំណោម៣) | ៥០% | ៥៥% | ៦០% | ៦៥% | ៧០% |
| ការរៀបចំ និងអនុម័តលិខិតបទដ្ឋានស្តីពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន | | ✓ | | | |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដោយមានការគាំទ្រពីអង្គការសង្គមស៊ីវិល និងសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាជាអ្នកអនុវត្តលទ្ធផលរំពឹងទុកនេះ។

## ឃ. ថវិកាប៉ាន់ស្មាន

| សមាសភាគទី១ | អ្នកអនុវត្ត | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|
| តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា | ផ្នែកផ្គត់ផ្គង់ | 121,449$ | 95,000 $ | 130,000 $ | 100,000 $ | 100,000 $ | 546,449 $ |
| | ផ្នែកតម្រូវការ | 612,379$ | 601,211$ | 682,574 $ | 796,527 $ | 910,495 $ | 3,603,185 $ |
| | សរុប | 733,828$ | 696,211$ | 812,574$ | 896,527$ | 1,010,495$ | 4,149,634$ |

# សមាសភាគទី២
# ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ

## ក. សេចក្តីផ្តើម

**សមាសភាគទី២** មានគោលបំណងពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមត្រួតពិនិត្យតាមដាន និងទទួលបានសេវាសាធារណៈ និងលើកជាសកម្មភាពកែលម្អ ដោយប្រើប្រាស់វិធីសាស្ត្របណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋ តំណាងប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ សហការជាមួយអង្គការដៃគូអនុវត្ត ឬអង្គការដៃគូនៅមូលដ្ឋាន ដើម្បីរៀបចំកិច្ចប្រជុំវាយតម្លៃដោយឡែកជាមួយអ្នកផ្តល់សេវា នៃអង្គភាពផ្តល់សេវានិង អ្នកទទួលសេវានីមួយៗ។ ក្នុងកិច្ចប្រជុំទាំងនេះ អ្នកចូលរួមនឹងកំណត់លក្ខណៈវិនិច្ឆ័យជាអាទិភាព ដាក់ពិន្ទុលក្ខណៈវិនិច្ឆ័យនីមួយៗ រៀបរាប់ពីចំណុចខ្លាំង ចំណុចខ្សោយ និងកំណត់រកសកម្មភាពអាទិភាពដើម្បីធ្វើការកែលម្អសេវា។ ក្រោយកិច្ចប្រជុំវាយតម្លៃដោយឡែកទាំងនេះ តំណាងអ្នកប្រើប្រាស់សេវា និងអ្នកផ្តល់សេវានីមួយៗនឹងចូលរួមក្នុងកិច្ចប្រជុំរួម ដើម្បីពិភាក្សា និងបង្កើតផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)។ សមាសភាគទី២នេះ ត្រូវបានរៀបចំឡើងដើម្បីជំរុញកិច្ចសន្ទនាដោយបើកចំហ រវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា។

សកម្មភាពនានាដែលមានក្នុងសមាសភាគទី២នេះ ត្រូវបានចាប់ផ្តើមអនុវត្តពីខែមេសា រហូតដល់ខែកក្កដា នៃឆ្នាំនីមួយៗ។

## ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ

ការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ (២០១៦-២០១៨) ក្នុងក្របខ័ណ្ឌនៃសមាសភាគទី២ ទាក់ទងនឹងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋនេះ បានទទួលនូវលទ្ធផលល្អប្រសើរជាវិជ្ជមានសំខាន់ៗដូចខាងក្រោម៖

- វិធីសាស្ត្រលម្អិតស្តីពីការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋត្រូវបានបង្កើតឡើង ដើម្បីអនុវត្តសាកល្បង ធ្វើការកែសម្រួល និងដាក់ឱ្យអនុវត្តជាផ្លូវការ។
- បណ្ណដាក់ពិន្ទុដោយសហគមន៍ និងការវាយតម្លៃដោយខ្លួនឯងរបស់អ្នកផ្តល់សេវា ត្រូវបានអនុវត្តដោយជោគជ័យក្នុងឃុំចំនួន៧៥៨ នៃរដ្ឋបាលឃុំសរុប៨២៧ ដោយមានការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋជាង ២៧០.០០០ នាក់ ដែលក្នុងនោះស្ត្រីមានចំនួន ៧៥% និងអ្នកផ្តល់សេវាចំនួន ៣៧.៤២១ ដែលក្នុងនោះស្ត្រីមានចំនួន ៣៥%។
- កិច្ចប្រជុំរួមត្រូវបានរៀបចំឡើង ហើយ ផ.ស.រ.គ ត្រូវបានបង្កើតឡើងដោយជោគជ័យក្នុងឃុំគោលដៅចំនួន ៧៥៨ នៃរដ្ឋបាលឃុំសរុប៨២៧។

- អ្នកទទួលសេវា និងអ្នកផ្តល់សេវា បានពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាក្នុងន័យស្ថាបនា និងប្រកបដោយបរិយាកាសស្និទ្ធស្នាល អធ្យាស្រ័យគ្នាទៅវិញទៅមក និងមានការទំនាក់ទំនងកាន់តែល្អប្រសើរ បន្ទាប់ពីមានកិច្ចដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ។
- គណៈកម្មាធិការ ផ.ស.រ.គ ត្រូវបានបង្កើតឡើងក្នុងឃុំគោលដៅចំនួន ៧៥៨ នៃរដ្ឋបាលឃុំសរុប៨២៧ដើម្បីគាំទ្រ ត្រួតពិនិត្យតាមដានដំណើរការអនុវត្ត ផ.ស.រ.គ។

ទន្ទឹមនឹងទទួលបានលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ក៏នូវមាននៅបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាក្នុងការវាយតម្លៃដោយខ្លួនឯង និងកិច្ចប្រជុំរួមពុំទាន់បានពេញលេញនៅឡើយនៅតាមតំបន់គោលដៅអនុវត្តមួយចំនួន។
- ការចូលរួមរបស់ស្ត្រី និងបុរសនៅក្នុងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ពុំទាន់មានតុល្យភាពល្អប្រសើរនៅឡើយ ហើយការចូលរួមរបស់ក្រុមជនងាយរងគ្រោះ ដូចជាជនក្រីក្រ ជនពិការ មនុស្សចាស់ជរា ជនជាតិដើមភាគតិច នៅមានកម្រិតនៅឡើយ។
- ការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពីការប្រើប្រាស់ថវិការបស់អង្គភាពផ្តល់សេវា និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយ។

ផ្អែកតាមមេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនៃការអនុវត្ត ផ.អ.គ.ស នៅដំណាក់កាលទី ១ ដូចបានរៀបរាប់ខាងលើ បានជួយកំណត់រកចំណុចកែលម្អនានា ហើយការកែសម្រួល និងចំណុចថ្មីៗសម្រាប់សមាសភាគទី២ ក្នុង ផ.អ.គ.ស ដំណាក់កាលទី ២ នឹងរួមបញ្ចូលចំណុចសំខាន់ៗមានដូចខាងក្រោម៖

- ***ការគាំទ្ររបស់ក្រសួង ស្ថាប័នសាមីលើដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋលើ ផ.អ.គ.ស មានលក្ខណៈផ្លូវការ៖*** នៅដំណាក់កាលទី២ ក្រសួង ស្ថាប័នសាមីនឹងត្រូវបានជំរុញ និងគាំទ្រ៖ ១)ចេញគោលការណ៍ណែនាំច្បាស់លាស់ ស្តីពីកាតព្វកិច្ចឱ្យមានការចូលរួមយ៉ាងសកម្មរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាក្នុងការចូលរួមវាយតម្លៃដោយខ្លួនឯង កិច្ចប្រជុំរួម និងការបង្កើត ផ.ស.រ.គ ២)មានវិធានការផ្តួចផ្តើមជាមុនដើម្បីធានាថា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាយល់ច្បាស់ពីគោលការណ៍ណែនាំទាំងនោះ។

- ***បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ និងការពិភាក្សាពីការប្រើប្រាស់ធនធានហិរញ្ញវត្ថុ៖*** ផ.អ.គ.ស ក្នុងដំណាក់កាលទី២ ប័ណ្ណដាក់ពិន្ទុសហគមន៍ និងកិច្ចប្រជុំរួម នឹងត្រូវបានកែសម្រួលដោយរួមបញ្ចូលកិច្ចពិភាក្សាស៊ីជម្រៅស្តីពីការរៀបចំថវិកា និងការប្រើប្រាស់មូលនិធិដោយអ្នកផ្តល់សេវា ដើម្បីបង្កើនការផ្តល់មតិយោបល់ដោយប្រជាពលរដ្ឋ ស្តីពីការប្រើប្រាស់មូលនិធិរបស់រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា មណ្ឌលសុខភាព និងរដ្ឋបាលក្រុង ស្រុក ខណ្ឌដើម្បីឆ្លើយតបទៅនឹងសកម្មភាពអាទិភាពក្នុង ផ.ស.រ.គ។

- ***ការត្រួតពិនិត្យ តាមដានដោយប្រជាពលរដ្ឋឱ្យគ្របដណ្តប់លើសេវាសាធារណៈបន្ថែម៖*** ផ.អ.គ.ស ដំណាក់កាលទី២ នឹងបង្កើត ដើម្បីអនុវត្តសាកល្បង និងអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋសម្រាប់សេវាថ្មីៗដូចជា៖ រដ្ឋបាលក្រុង ស្រុក ខណ្ឌ សង្កាត់ ការគ្រប់គ្រងទឹកស្អាត និងអនាម័យ មន្ទីរពេទ្យបង្អែក ការគ្រប់គ្រងសំរាម និងកាកសំណល់រឹង ទីប្រជុំជន និងកសិកម្មជាដើម ហើយលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងផ្តល់ការណែនាំ និងជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នផ្សេងៗ។
- ***កែសម្រួលវិធីសាស្ត្រត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋដល់តំបន់ទីប្រជុំជន៖*** ផ.អ.គ.ស ដំណាក់កាលទី២ នឹងបង្កើត និងអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ដើម្បីពិចារណាពីលក្ខណៈពិសេសនៅទីប្រជុំជនដូចជា៖ ក្រុង ស្រុក ខណ្ឌ សង្កាត់ (ឧ. ដង់ស៊ីតេប្រជាជនខ្ពស់ ការរស់នៅ និងបញ្ហាផ្តល់សេវាដែលកើតមានឡើងនៅទីប្រជុំជនខុសប្លែកពីទីជនបទ)។ សកម្មភាពនេះពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្តសាកល្បង និងការអនុវត្តវិធីសាស្ត្រថ្មីៗនៃការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ដែលកែសម្រួលទៅតាមបរិបទនៅទីប្រជុំជន (ឧ.ដែលប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (ICT) ថែមទាំងកិច្ចប្រជុំផ្ទាល់ជាមួយប្រជាពលរដ្ឋ ដើម្បីធ្វើឱ្យប្រជាជនភាគច្រើនបានចូលរួមក្នុងកិច្ចដំណើរការនេះ)។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបចំពោះចំណុចដែលត្រូវកែលម្អឆ្លងតាមមេរៀនបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមកក្នុងដំណាក់កាលទី១ សមិទ្ធផល និងលទ្ធផលរំពឹងទុកពាក់ព័ន្ធទៅនឹងសមាសភាគទី២ត្រូវបានកំណត់ និងបរិយាយមានដូចខាងក្រោម៖

**សមិទ្ធផលរំពឹងទុកទី២.១៖ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាទទួលបានព័ត៌មានកាន់តែទូលំទូលាយ ស្តីពីអាទិភាពរបស់ប្រជាពលរដ្ឋ និងទស្សនៈនានាដែលពាក់ព័ន្ធទៅនឹងអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈនានា**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ២ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ២.១.១. ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ**

**សកម្មភាពជាចម្បងៗ**

- បង្កើត អនុវត្តសាកល្បង និងអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (កិច្ចប្រជុំប័ណ្ណដាក់ពិន្ទុដោយសហគមន៍ និងការវាយតម្លៃខ្លួនឯងដោយអ្នកផ្តល់សេវា) ដែលត្រូវបានកែសម្រួល និងប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (ICT)។

- អនុវត្តដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (កិច្ចប្រជុំប័ណ្ណដាក់ពិន្ទុដោយសហគមន៍ និងការវាយតម្លៃខ្លួនឯងដោយអ្នកផ្តល់សេវា) ក្នុង ផ.អ.គ.ស ជាប្រចាំឆ្នាំនៅតាមតំបន់គោលដៅអនុវត្ត និងលើសេវានីមួយៗ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយមន្ត្រី ឬអ្នកផ្តល់សេវាក្នុងតំបន់គោលដៅអនុវត្តបានយល់ច្បាស់ពីតម្រូវការអាទិភាព និងបញ្ហាកង្វល់របស់ប្រជាពលរដ្ឋ។ | ៥០% | ៥៥% | ៦០% | ៦៥% | ៧០% |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាពាក់ព័ន្ធ ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

**លទ្ធផលរំពឹងទុក ២.១.២. ការរៀបចំលិខិតបទដ្ឋាននានា ដើម្បីគាំទ្រការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ**

**សកម្មភាពជាចម្បងៗ**

- រៀបចំ និងចេញគោលការណ៍ណែនាំដោយក្រសួង ស្ថាប័នសាមី ដើម្បីគាំទ្រដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងកំណត់ពីការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ។
- ពិនិត្យតាមដាន និងលើកទឹកចិត្តតាមរយៈប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់ក្រសួង ស្ថាប័ន សាមី ក្នុងការអនុវត្តដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋក្នុង ផ.អ.គ.ស។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| រៀបចំសេចក្តីណែនាំដោយក្រសួង ស្ថាប័នសាមី ដើម្បីកំណត់ពីការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

ក្រសួង ស្ថាប័នពាក់ព័ន្ធ សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលថ្នាក់ក្រោមជាតិ និង អង្គភាពផ្តល់សេវាពាក់ព័ន្ធជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស)។

**សមិទ្ធផលរំពឹងទុកទី២.២៖ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋកំណត់បានជារួម ស្តីពីសកម្មភាពជាអាទិភាពចាំបាច់ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ នៅមូលដ្ឋានប្រកបដោយគុណភាព និងប្រសិទ្ធភាព**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន១ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ២.២.១.កិច្ចប្រជុំរួម**

**សកម្មភាពជាចម្បងៗ**

- ក្នុងកិច្ចប្រជុំរួម បង្ហាញអំពីព័ត៌មានថវិកា កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និង ពិភាក្សា ស្តីពីការរៀបចំថវិកា និងការប្រើប្រាស់មូលនិធិរបស់អង្គភាពផ្តល់សេវា ដើម្បីឆ្លើយ តបនឹងសកម្មភាពអាទិភាពក្នុង ផ.ស.រ.គ។
- រៀបចំកិច្ចប្រជុំរួម និងបង្កើត ផ.ស.រ.គ ក្នុងតំបន់គោលដៅអនុវត្ត និងសេវានីមួយៗ
- បង្កើតគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ក្នុងតំបន់អនុវត្តនីមួយៗ

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយមន្ត្រី និងអង្គភាពផ្តល់សេវា ក្នុងតំបន់គោលដៅអនុវត្ត យល់ស្របថាសកម្មភាពអាទិភាពដែលបានកំណត់ក្នុង ផ.ស.រ.គ ឆ្លើយតបក្នុងការរួមចំណែកកែលម្អគុណភាព ប្រសិទ្ធភាពក្នុងការផ្តល់សេវាមូលដ្ឋាន។ | ៥០% | ៥៥% | ៦០% | ៦៥% | ៧០% |
| ភាគរយប្រជាពលរដ្ឋ ក្នុងតំបន់គោលដៅ អនុវត្តយល់ស្របថាសកម្មភាពអាទិភាពដែលបានកំណត់ក្នុងផ.ស.រ.គ ឆ្លើយតបក្នុងការរួមចំណែកកែលម្អគុណភាព | ៥០% | ៥៥% | ៦០% | ៦៥% | ៧០% |

| | | | | | |
|---|---|---|---|---|---|
| ប្រសិទ្ធភាពក្នុងការផ្តល់សេវាមូលដ្ឋាន។ | | | | | |
| ផ.ស.រ.គ ត្រូវបានបង្កើតក្នុងតំបន់គោលដៅអនុវត្តនីមួយៗ | ✓ | ✓ | ✓ | ✓ | ✓ |
| គណៈកម្មាធិការ ផ.ស.រ.គ ត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នភាពក្នុងតំបន់គោលដៅអនុវត្តនីមួយៗ | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាពាក់ព័ន្ធនានាជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ដោយមានការចូលរួមចំណែកពីប្រជាពលរដ្ឋ។

## ឃ. ថវិកាប៉ាន់ស្មាន

| សមាសភាគទី ២ | អ្នកអនុវត្ត | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|
| ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ | ផ្នែកផ្គត់ផ្គង់ | 41,000$ | 60,000$ | 100,000$ | 80,000$ | 66,076$ | 347,076$ |
| | ផ្នែកតម្រូវការ | 633,711$ | 722,189$ | 850,526$ | 890,799$ | 888,114$ | 3,985,338$ |
| | សរុប | 674,711$ | 782,189$ | 950,526$ | 970,799$ | 954,190$ | 4,332,414$ |

# សមាសភាគទី៣

# ការអនុវត្តផែនការសកម្មភាពរួមស្តីពីការធានាគណនេយ្យភាពសង្គម

## ក. សេចក្តីផ្តើម

**សមាសភាគទី៣** សហគមន៍ អង្គភាពផ្តល់សេវាសាធារណៈ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលរួមសហការដើម្បីអនុវត្ត ផ.ស.រ.គ។ នៅតាមរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌគោលដៅអនុវត្តនីមួយៗ គណៈកម្មាធិការ ផ.ស.រ.គ មួយ ដែលរួមមានមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកផ្តល់សេវា និងសមាជិកសហគមន៍ ត្រូវបានបង្កើតឡើងក្នុងកិច្ចប្រជុំរួមដើម្បីគាំទ្រ ពិនិត្យតាមដាន និងរាយការណ៍យ៉ាងហោចណាស់៤ដងក្នុងឆ្នាំជាសាធារណៈស្តីពីវឌ្ឍនភាពនៃការអនុវត្ត ផ.ស.រ.គ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍សហការជាមួយមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា ដោយមានការគាំទ្របច្ចេកទេសពីអង្គការដៃគូអនុវត្ត ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពី ផ.ស.រ.គ ដល់សហគមន៍ ព្រមទាំងជួយដល់ដំណើរការអនុវត្តការងាររបស់គណៈកម្មាធិការ ផ.ស.រ.គ។

សកម្មភាពមួយចំនួនដែលមានក្នុងសមាសភាគទី៣នេះ ត្រូវបានអនុវត្តចាប់ពីខែសីហា រហូតដល់ខែធ្នូ នៃឆ្នាំនីមួយៗ ហើយសកម្មភាពមួយចំនួន នៃផ.ស.រ.គ ត្រូវបានអនុវត្តជាប្រចាំ។

## ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ

ការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ (២០១៦-២០១៨) ទាក់ទងទៅនឹងការអនុវត្ត ផ.ស.រ.គ បានទទួលនូវលទ្ធផលល្អប្រសើរជាវិជ្ជមានសំខាន់ៗមានដូចខាងក្រោម៖

- ជារួម សកម្មភាពអាទិភាពប្រមាណជាង៦០% នៃសកម្មភាពទាំងអស់ត្រូវបានអនុវត្តដោយក្នុងនោះមានសកម្មភាពអាទិភាពប្រមាណ៤៤% នៃសកម្មភាពដែលត្រូវការជំនួយការគាំទ្រពីខាងក្រៅ ហើយសកម្មភាពអាទិភាពប្រមាណ៧១% នៃសកម្មភាពដែលមិនត្រូវការជំនួយពីខាងក្រៅ។

- ការអនុវត្ត ផ.ស.រ.គ បានរួមចំណែកធ្វើឱ្យមានការប្រែប្រួល និងផ្លាស់ប្តូរជាច្រើនដូចជា៖ អាកប្បកិរិយា និងម៉ោងប្រចាំការរបស់បុគ្គលិកមណ្ឌលសុខភាព ពេលម៉ោងបង្រៀន សៀវភៅសិក្សាគោល ព្រមទាំងការកែលម្អនូវសោភ័ណ្ឌភាពបរិវេណ អនាម័យ បរិស្ថាននៃទីតាំងសេវានីមួយៗ ហើយលទ្ធផលនៃការបំពេញការងារតាមសេវានីមួយៗធៀប នឹងស្តង់ដា (សូចនាករ) ក៏មានការកើនឡើងបើប្រៀបធៀបរវាងមុនពេល និងក្រោយពេលអនុវត្តការងារគណនេយ្យភាពសង្គម។

ទន្ទឹមនឹងទទួលបានលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- សកម្មភាពអាទិភាពមួយចំនួននៅក្នុង ផ.ស.រ.គ ជាពិសេសសកម្មភាពអាទិភាពដែលត្រូវការជំនួយគាំទ្រពីខាងក្រៅ ពុំត្រូវបានអនុវត្តដោយសារកង្វះថវិកា និងមិនបានដាក់បញ្ចូលនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ក៏ដូចជាផែនការសកម្មភាព និងថវិកាតាមវិស័យនីមួយៗ
- កង្វះការគាំទ្របច្ចេកទេសពីក្រសួង ស្ថាប័ន និងអង្គភាពសាមីក្នុងការអនុវត្ត ផ.ស.រ.គ។

ផ្អែកតាមមេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនៃការអនុវត្ត ផ.អ.គ.ស នៅដំណាក់កាលទី ១ ដូចបានរៀបរាប់ខាងលើ បានជួយកំណត់រកចំណុចកែលម្អនានា ហើយការកែសម្រួល និងចំណុចថ្មីៗសម្រាប់សមាសភាគទី៣ ក្នុង ផ.អ.គ.ស ដំណាក់កាលទី ២ នឹងរួមបញ្ចូលចំណុចសំខាន់ៗមានដូចខាងក្រោម៖

- ***បង្កើនការគាំទ្ររបស់ក្រសួង ស្ថាប័ន អង្គភាពសាមី និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការអនុវត្ត និងពិនិត្យតាមដានសកម្មភាព ផ.ស.រ.គ៖*** ការបង្កើនការឆ្លើយតបចំពោះ ផ.ស.រ.គ មិនត្រឹមតែការរួមបញ្ចូលសកម្មភាព ផ.ស.រ.គ ក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ និងគ្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងផែនការសកម្មភាព និងថវិកាតាមវិស័យនីមួយៗប៉ុណ្ណោះទេ ថែមទាំងការបែងចែកធនធានសម្រាប់ការអនុវត្តសកម្មភាពនេះផងដែរ។ ដើម្បីបង្កើនការគាំទ្រ និងឆ្លើយតបបញ្ហានេះត្រូវ៖
  ១) ចេញគោលការណ៍ណែនាំក្នុងការប្រើប្រាស់មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គាំទ្រការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម។
  ២) ក្រសួង ស្ថាប័ន និងអង្គភាពសាមីគ្រោងកញ្ចប់ថវិកាសម្រាប់ការអនុវត្ត ផ.ស.រ.គ
  ៣) បង្កើនការចូលរួម និងគាំទ្រពីគណៈកម្មាធិការនានានៅថ្នាក់មូលដ្ឋាន (ឧ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ គណៈកម្មាធិការកសាងផែនការ និងថវិកា គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការទ្រទ្រង់សាលារៀន និងក្រុមទ្រទ្រង់សុខភាពភូមិ ) ក្នុងការអនុវត្ត និងតាមដានការអនុវត្ត ផ.ស.រ.គ។
- ***ធានាការបញ្ចូលសកម្មភាព ផ.ស.រ.គ ទៅក្នុងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អង្គភាពតាមវិស័យ៖*** ការដាក់បញ្ចូលសកម្មភាព ផ.ស.រ.គ ក្នុងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបាននឹងកំពុងអនុវត្ត ប៉ុន្តែត្រូវកែលម្អបន្ថែម ដោយផ្តោតសំខាន់លើការបង្កើតប្រព័ន្ធ និងនីតិវិធីដើម្បីធានាថា៖
  ១) សកម្មភាព ផ.ស.រ.គ ពាក់ព័ន្ធត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពតាមវិស័យ។
  ២) សកម្មភាពដែលទាមទារនូវការគាំទ្រកម្រិតខ្ពស់ត្រូវបានបញ្ជូនទៅថ្នាក់លើ (ថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ)។

៣) វឌ្ឍនភាពក្នុងការអនុវត្តសកម្មភាព ផ.ស.រ.គ ត្រូវពិនិត្យតាមដានដោយក្រសួង និងអង្គភាពសាមី។

- ***កៀរគរធនធានក្នុងមូលដ្ឋាន ៖*** ដើម្បីកៀរគរធនធានក្នុងមូលដ្ឋាន កាន់តែច្រើនក្នុងការគាំទ្រដល់ការអនុវត្តសកម្មភាព ផ.ស.រ.គ ត្រូវ៖
 ១) ពង្រឹងទំនាក់ទំនងរវាងគណៈកម្មាធិការ ផ.ស.រ.គ និងគណៈកម្មាធិការនានានៅថ្នាក់មូលដ្ឋាន (ឧ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ គណៈកម្មាធិការកសាងផែនការ និងថវិកា គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការទ្រទ្រង់សាលារៀន និងក្រុមទ្រទ្រង់សុខភាពភូមិ)
 ២) អញ្ជើញឱ្យសមាជិកគណៈកម្មាធិការ ផ.ស.រ.គ ចូលរួមក្នុងដំណើរការកសាងផែនការសកម្មភាព និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពតាមវិស័យ។
- ***ចងក្រងឯកសារ ធ្វើការវិភាគ និងរាយការណ៍ពីការអនុវត្ត ផ.ស.រ.គ ៖*** ការធ្វើបច្ចុប្បន្នភាពជាប្រចាំនៃប្រព័ន្ធទិន្នន័យរបស់ ផ.ស.រ.គ ដែលអាចចូលមើលជាសាធារណៈ ហើយការចងក្រងឯកសារ ការវិភាគ និងការរាយការណ៍ពីការអនុវត្ត ផ.ស.រ.គ មានសារៈសំខាន់ក្នុងការតាមដានការអនុវត្ត ផ.ស.រ.គ។ ដើម្បីសម្រេចកិច្ចការនេះបានត្រូវ៖
 ១) រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្ម (online) ដើម្បីបញ្ចូលទិន្នន័យ ផ.ស.រ.គ ជាប្រចាំ
 ២) វិភាគទិន្នន័យ ផ.ស.រ.គ រៀងរាល់ឆ្នាំ និងរៀបចំរបាយការណ៍សម្រាប់ដាក់ជូន គ.ជ.អ.ប. គ.គ.អ.ស ក្រសួង ស្ថាប័ន និងអង្គភាពសាមី ដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាត។
- ***អនុវត្តគោលការណ៍ ផ.អ.គ.ស ឱ្យបានកាន់តែទូលំទូលាយ ក្នុងដំណើរការរៀបចំផែនការសកម្មភាព និងថវិកាថ្នាក់មូលដ្ឋាន ៖*** ដើម្បីឆ្ពោះទៅរកការអនុវត្តគោលការណ៍ ផ.អ.គ.ស ក្នុងដំណើរការរៀបចំផែនការសកម្មភាព និងថវិកាថ្នាក់មូលដ្ឋាន ឱ្យបានកាន់តែទូលំទូលាយ ផ.អ.គ.ស ដំណាក់កាលទី ២ នឹងសាកល្បងដំណើរការដែលមានការចូលរួមពីប្រជាពលរដ្ឋក្នុងការពិនិត្យឡើងវិញ និងកំណត់សកម្មភាពអាទិភាពក្នុងខ្លឹមសារកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឧ. ការបោះឆ្នោតកំណត់រកអាទិភាពសហគមន៍តាមរយៈសារទូរស័ព្ទ)។

- ***រៀបចំ និងអនុវត្ត "ធនធានចូលរួមបដិភាគ" (Matching Fund) ដែលមានភាពប្រកួតប្រជែងសម្រាប់សកម្មភាព ផ.ស.រ.គ ៖*** ដើម្បីជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តមូលនិធិរបស់ខ្លួនដើម្បីឆ្លើយតបនឹងសកម្មភាព ផ.ស.រ.គ រួមទាំងធនធានចូលរួមបដិភាគ ក្នុងការគាំទ្រសកម្មភាពអាទិភាពដែលលើកឡើងនៅក្នុង ផ.ស.រ.គ។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបចំពោះចំណុចដែលត្រូវកែលម្អឆ្លងតាមមេរៀនបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមកក្នុងដំណាក់កាលទី១ សមិទ្ធផល និងលទ្ធផលរំពឹងទុកពាក់ព័ន្ធទៅនឹងសមាសភាគទី៣ត្រូវបានកំណត់ និងបរិយាយមានដូចខាងក្រោម៖

**សមិទ្ធផលរំពឹងទុក ៣.១÷ ការអនុវត្ត និងការតាមដានផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីកែលម្អគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន២ មានដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៣.១.១. ការអនុវត្តផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម**

**សកម្មភាពជាចម្បងៗ**

- អនុវត្តសកម្មភាព ផ.ស.រ.គ នៅតាមតំបន់គោលដៅអនុវត្តនីមួយៗ។
- គណៈកម្មាធិការ ផ.ស.រ.គ នៅតាមតំបន់គោលដៅអនុវត្តនីមួយៗគាំទ្រ ត្រួតពិនិត្យ និងតាមដានការអនុវត្ត ផ.ស.រ.គ។
- បង្ហាញ ផ.ស.រ.គ សម្រាប់តំបន់គោលដៅអនុវត្តនីមួយៗ ជារៀងរាល់ឆ្នាំក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។
- រៀបចំសេចក្តីណែនាំពីការប្រើប្រាស់មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រការអនុវត្ត ផ.អ.គ.ស។
- បង្កើតប្រព័ន្ធ និងនីតិវិធីសម្រាប់គាំទ្រដោយក្រសួង ស្ថាប័ន និងអង្គភាពសាមី ដើម្បីផ្តល់មូលនិធិ និងពិនិត្យតាមដានការអនុវត្តសកម្មភាព ផ.ស.រ.គ។
- បង្កើតឡើង និងអនុវត្តនូវធនធានចូលរួមបដិភាគ ដើម្បីជួយគាំទ្រដល់ការអនុវត្តសកម្មភាពអាទិភាពក្នុង ផ.ស.រ.គ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយសកម្មភាព ផ.ស.រ.គ របស់សាលាបឋមសិក្សាដែលបានអនុវត្ត ឬកំពុងអនុវត្ត | ៥០% | ៦០% | ៧០% | ៧៥% | ៨០% |
| ភាគរយសកម្មភាព ផ.ស.រ.គ របស់មណ្ឌលសុខភាពដែលបានអនុវត្ត ឬកំពុងអនុវត្ត | ៥០% | ៦០% | ៧០% | ៧៥% | ៨០% |

| | | | | | |
|---|---|---|---|---|---|
| ភាគរយសកម្មភាព ផ.ស.រ.គ របស់រដ្ឋបាលឃុំ សង្កាត់ដែលបានអនុវត្ត ឬកំពុងអនុវត្ត | ៥០% | ៦០% | ៧០% | ៧៥% | ៨០% |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.ជ.អ.ប. និង គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រ និងសម្របសម្រួលរបស់ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល និងក្រុមការងារមូលនិធិបរធនបាលកិច្ច។

**លទ្ធផលរំពឹងទុក ៣.១.២. ការតាមដានការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម**

**សកម្មភាពជាចម្បងៗ**

- សមាជិកគណៈកម្មាធិការ ផ.ស.រ.គ ចូលរួមប្រជុំដោយទៀងទាត់ ក្នុងដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- ផ្សព្វផ្សាយជាសាធារណៈនូវ ផ.ស.រ.គ តាមរយៈការបិទផ្សាយជាសាធារណៈ ប្រព័ន្ធផ្សព្វផ្សាយ និងវេទិកានានា។
- រាយការណ៍ជាសាធារណៈដោយគណៈកម្មាធិការ ផ.ស.រ.គ ស្តីពីវឌ្ឍនភាព នៃការអនុវត្ត ផ.ស.រ.គ រៀងរាល់ខែ តាមប្រព័ន្ធអេឡិចត្រូនិក និងក្នុងកិច្ចប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយនៃតំបន់គោលដៅ ដែលគណៈកម្មាធិការ ផ.ស.រ.គ បានផ្សព្វផ្សាយស្តីពីវឌ្ឍនភាព នៃការអនុវត្ត ផ.ស.រ.គ យ៉ាងតិច២ដងក្នុងមួយឆ្នាំ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងវេទិកានានា | ៥០% | ៦០% | ៧០% | ៨០% | ៩០% |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាអ្នកអនុវត្តនូវ

លទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.ជ.អ.ប. និង គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រ និងសម្របសម្រួលរបស់ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល។

**សមិទ្ធផលរំពឹងទុក ៣.២ ÷ ទិន្នន័យស្តីពីសកម្មភាពជាអាទិភាពសម្រាប់កែលម្អក្នុងវិស័យនីមួយៗ ត្រូវបានធ្វើការវិភាគ និងប្រើប្រាស់ដើម្បីតាក់តែងគោលនយោបាយ**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ១ មានដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៣.២.១.ទិន្នន័យផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គមត្រូវបានវិភាគ និងប្រើប្រាស់យ៉ាងទូលំទូលាយ**

**សកម្មភាពជាចម្បងៗ**

- កែសម្រួល និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ ដើម្បីធានាថាទិន្នន័យ ផ.ស.រ.គ ត្រូវបានប្រើប្រាស់ និងវិភាគនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ប្រព័ន្ធទិន្នន័យ ត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីធានាថាទិន្នន័យ ផ.ស.រ.គ ត្រូវបានប្រើប្រាស់ និងវិភាគ នៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.ជ.អ.ប. និង គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រ និងសម្របសម្រួលរបស់ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល។

## ឃ. ថវិការប៉ាន់ស្មាន

| សមាសភាគទី៣ | អ្នកអនុវត្ត | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|
| ការអនុវត្ត ផ.ស.រ.គ | ផ្នែកផ្គត់ផ្គង់ | 697,400$ | 635,400$ | 558,180$ | 400,014$ | 120,000 $ | 2,410,994$ |
| | ផ្នែកតម្រូវការ | 291,575$ | 294,621$ | 180,111$ | 173,549$ | 292,148$ | 1,232,004$ |
| | សរុប | 988,987$ | 930,021$ | 738,291$ | 573,563$ | 412,148$ | 3,643,998$ |

# សមាសភាគទី៤
# ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង

## ក. សេចក្តីផ្តើម

**សមាសភាគទី៤**នេះ មានគោលបំណងបង្កើនសមត្ថភាព និងពង្រឹងសិទ្ធិអំណាចរបស់អ្នកពាក់ព័ន្ធទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ដើម្បីអនុវត្តដោយជោគជ័យនូវសកម្មភាពដែលបានកំណត់ក្នុងសមាសភាគទី១ សមាសភាគទី២ និងសមាសភាគទី៣ របស់ ផ.អ.គ.ស។ សមាសភាគនេះផ្តល់ការបណ្តុះបណ្តាល ការណែនាំហ្វឹកហ្វឺន និងការរៀនសូត្រពីការអនុវត្តផ្ទាល់ សម្រាប់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ផ្តោតការយកចិត្តទុកដាក់ជាសំខាន់ៗដូចជា៖

១) បណ្តុះបណ្តាលមន្ត្រី និងអ្នកផ្តល់សេវានៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត អំពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុង ផ.អ.គ.ស។

២) ជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅមូលដ្ឋាន និងបណ្តុះបណ្តាល

៣) ផ្តល់ការណែនាំ និងការហ្វឹកហ្វឺនជាប្រចាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅពេលអនុវត្តវដ្តប្រចាំឆ្នាំនៃសកម្មភាព ផ.អ.គ.ស និង

៤) បណ្តុះបណ្តាលដល់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ ដើម្បីជួយដល់ការអនុវត្ត ផ.ស.រ.គ

សកម្មភាពនានាដែលមានក្នុងសមាសភាគទី៤នេះ ត្រូវបានអនុវត្តជាប្រចាំដើម្បីគាំទ្រដល់ដំណើរការអនុវត្តសកម្មភាពក្នុងសមាសភាគទី១ សមាសភាគទី២ និងសមាសភាគទី៣។

## ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ

ការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ (២០១៦-២០១៨) ក្នុងក្របខ័ណ្ឌនៃសមាសភាគទី៤ ទាក់ទងនឹងការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនងនេះបានទទួលនូវលទ្ធផលល្អប្រសើរជាវិជ្ជមានសំខាន់ៗដូចខាងក្រោម៖

- ឯកសារនៃការបណ្តុះបណ្តាលទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការត្រូវបានបង្កើតឡើង អនុវត្តសាកល្បង និងកែសម្រួល។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍សរុបចំនួន ៣.៧០០ នាក់ (ស្ត្រីចំនួន៦៣%) និងមន្ត្រីមូលដ្ឋានចំនួន ៧.២០០ នាក់ត្រូវបានបណ្តុះបណ្តាលពី ផ.អ.គ.ស។
- ឯកសារបណ្តុះបណ្តាលបឋមសម្រាប់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ ត្រូវបានរៀបចំឡើង ហើយមានសមាជិកគណៈកម្មាធិការ ផ.ស.រ.គ សរុបចំនួន ១.៤១០ នាក់ មកពីរដ្ឋបាលឃុំចំនួន ១០៥ ត្រូវបានបណ្តុះបណ្តាល។

ទន្ទឹមនឹងទទួលបានលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការបណ្តុះបណ្តាលតួអង្គផ្នែកផ្គត់ផ្គង់ក្នុងដំណាក់កាលទី១ លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំឯកសារបណ្តុះបណ្តាលហើយ តែពុំទាន់បានបញ្ចូលតាមស្ថាប័នដែលពាក់ព័ន្ធទេ។
- មានការផ្លាស់ប្តូរមន្ត្រីបង្គោលទទួលបន្ទុកការងារគណនេយ្យភាពសង្គម នៅរដ្ឋបាលខេត្ត ស្រុក ឃុំមួយចំនួន បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលរួចហើយ។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មួយចំនួន មានការលាឈប់ពីការងារ បន្ទាប់ពីទទួលបាននូវការបណ្តុះបណ្តាលរួចហើយ។

ផ្អែកតាមមេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនៃការអនុវត្ត ផ.អ.គ.ស នៅដំណាក់កាលទី ១ ដូចបានរៀបរាប់ខាងលើ បានជួយកំណត់រកចំណុចកែលម្អនានា ហើយការកែសម្រួល និងចំណុចថ្មីៗសម្រាប់សមាសភាគទី៤ ក្នុង ផ.អ.គ.ស ដំណាក់កាលទី ២ នឹងរួមបញ្ចូលចំណុចសំខាន់ៗមានដូចខាងក្រោម៖

- ***ការបណ្តុះបណ្តាលស្តីពី ផ.អ.គ.ស និងការហ្វឹកហ្វឺនដល់រដ្ឋបាលថ្នាក់ក្រោមជាតិតាមស្ថាប័ន និងអង្គភាពសាមី ៖*** ដើម្បីធានានូវគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពរយៈពេលវែងនៃការបណ្តុះបណ្តាលផ្នែកផ្គត់ផ្គង់ក្នុង ផ.អ.គ.ស ចាំបាច់ត្រូវបញ្ជ្រាបតួនាទីទាំងនេះក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាមីដូចជា៖

  ១) ការបញ្ចូលប្រធានបទ ផ.អ.គ.ស ក្នុងការបណ្តុះបណ្តាលសំខាន់ៗសម្រាប់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧ. វគ្គជាកាតព្វកិច្ចរបស់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសាលាអភិបាលកិច្ច ឬនាយកដ្ឋានបណ្តុះបណ្តាលរបស់ក្រសួងមហាផ្ទៃ ឬដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន)

  ២) ការបញ្ជ្រាបក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាមីនូវឯកសារបណ្តុះបណ្តាលបច្ចេកទេសស្តីពី ការបំពេញទម្រង់ ការប្រមូល ការបញ្ចូលទិន្នន័យ និងបិទផ្សព្វផ្សាយទិន្នន័យI4Cs

  ៣) រៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាល ស្តីពី "ផែនការអនុវត្តគណនេយ្យភាពសង្គម" សម្រាប់សមាជិកក្រុមការងារ ផ.អ.គ.ស ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- ***ការបញ្ជ្រាបតាមស្ថាប័ននូវការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ផ្នែកតម្រូវការ៖*** ដើម្បីធានានូវគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពក្នុងដំណាក់កាលទី២នេះ ត្រូវមានការបញ្ជ្រាបតាមអង្គការសង្គមស៊ីវិល នូវការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ផ្នែកតម្រូវការ។ ចំណុចនេះនឹងរួមបញ្ចូល៖

  ១) ការកំណត់ និងការជ្រើសរើសស្ថាប័នជំនាញបណ្តុះបណ្តាលរបស់សង្គមស៊ីវិល

  ២) ការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័ន ដែលបានជ្រើសរើសដើម្បីផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ផ.អ.គ.ស ដល់អង្គការដៃគូអនុវត្តជាប្រចាំ និង

  ៣) ការបង្កើតភាពជាដៃគូសហការរវាងស្ថាប័នបណ្តុះបណ្តាលសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។

- ***ការអភិវឌ្ឍសមត្ថភាពរបស់តួអង្គថ្នាក់មូលដ្ឋានដើម្បីមានការទទួលខុសត្រូវកាន់តែច្រើនលើការអនុវត្ត ផ.អ.គ.ស ក្នុងសហគមន៍៖*** ក្នុងដំណាក់កាលទី២ រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ដែលបានអនុវត្ត ផ.អ.គ.ស បានពី៣ឆ្នាំទៅ៤ឆ្នាំ នឹងផ្លាស់ប្តូរទៅជាប្រព័ន្ធបន្តការអនុវត្ត នៅនឹងមូលដ្ឋានដែលអាចធានាបាននូវនិរន្តរភាពដោយខ្លួនឯង (**ឧបសម្ព័ន្ធ៤**)។ ដើម្បីបន្តនិរន្តរភាពអនុវត្តដោយខ្លួនឯងនេះរួមមាន៖

  ១) ការរៀបចំ និងសាកល្បងអនុវត្តផែនការផ្លាស់ប្តូរបន្តសម្រាប់តំបន់គោលដៅដែលបានអនុវត្ត ផ.អ.គ.ស បានពី៣ឆ្នាំទៅ៤ឆ្នាំ

  ២) ការបង្កើតលក្ខខណ្ឌការងារសម្រាប់ "អ្នកសម្របសម្រួលគណនេយ្យសហគមន៍" ដែលកំណត់ច្បាស់ពីការទទួលខុសត្រូវជាក់លាក់របស់ពួកគេ ដើម្បីបន្តការទទួលខុសត្រូវមួយចំនួនពីអង្គការដៃគូអនុវត្ត

  ៣) ការកំណត់ជ្រើសរើស និងបណ្តុះបណ្តាល "អ្នកសម្របសម្រួលគណនេយ្យសហគមន៍"

  ៤) ការរៀបចំ និងផ្តល់ការបណ្តុះបណ្តាលដល់អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន ដើម្បីឱ្យពួកគេអាចបំពេញការទទួលខុសត្រូវថ្មីៗបានពេញលេញ

  ៥) អ្នកផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលរួម និងជួយសម្របសម្រួល ក្នុងការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

- ***ការអភិវឌ្ឍសមត្ថភាពរបស់គណៈកម្មាធិការ ផ.ស.រ.គ ៖*** ដើម្បីពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការ ផ.ស.រ.គ នៃការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ នឹងពិនិត្យឡើងវិញកែសម្រួលឯកសារបណ្តុះបណ្តាលនៃ ផ.ស.រ.គ និងធានានូវការបណ្តុះបណ្តាលជាប្រព័ន្ធសម្រាប់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបចំពោះចំណុចដែលត្រូវកែលម្អឆ្លងតាមមេរៀនបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមកក្នុងដំណាក់កាលទី១ សមិទ្ធផល និងលទ្ធផលរំពឹងទុក៣ក់ព័ន្ធ ទៅនឹងសមាសភាគទី៤ត្រូវបានកំណត់ និងបរិយាយមានដូចខាងក្រោម៖

**សមិទ្ធផលរំពឹងទុកទី៤.១៖ សមត្ថភាពរបស់ផ្នែកតម្រូវការ (អង្គការសង្គមស៊ីវិល) ក្នុងការចូលរួមយ៉ាងសកម្មដើម្បីរួមចំណែកពង្រឹងគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាព ត្រូវបានលើកកម្ពស់**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ១ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៤.១.១ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាពអង្គការសង្គមស៊ីវិលសកម្មភាពជាចម្បងៗ ៖**

- ជ្រើសរើស និងបណ្តុះបណ្តាលវិទ្យាស្ថានបណ្តុះបណ្តាលឯកទេសផ្នែកតម្រូវការ

- រៀបចំ និងបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់អង្គការដៃគូអនុវត្តថ្មីៗ
- កែសម្រួលឯកសារបណ្តុះបណ្តាល ផ្អែកតាមយុទ្ធសាស្ត្របរិយាប័ន្ន និងសមធម៌សង្គម ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលដល់ដៃគូអនុវត្ត និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ជ្រើសរើសស្ថាប័នបណ្តុះបណ្តាល | ✓ | ✓ | ✓ | ✓ | ✓ |
| ធ្វើបច្ចុប្បន្នភាព ឯកសារបណ្តុះបណ្តាលផ្អែកតាមយុទ្ធសាស្ត្របរិយាប័ន្ននិងសមធម៌សង្គម | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល អង្គការសង្គមស៊ីវិល និងក្រុមមូលនិធិបរធនបាលកិច្ច (Trust Fund) ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ។

## សមិទ្ធផលរំពឹងទុកទី៤.២៖ សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មជាមួយប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាពត្រូវបានពង្រឹង

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ២ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៤.២.១.ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាពរបស់អង្គភាពផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**សកម្មភាពជាចម្បងៗ**

- បង្កើនការយល់ដឹង និងអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវាក្នុងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងបច្ចេកទេសស្តីពីការបំពេញទម្រង់ ការប្រមូល ការបញ្ចូលទិន្នន័យ និងបិទផ្សព្វផ្សាយទិន្នន័យ I4Cs ក្នុងផ.អ.គ.ស ដែលត្រូវធ្វើឡើងដោយក្រសួងស្ថាប័ន ឬអង្គភាពសាមី។
- ដាក់បញ្ចូលប្រធានបទសំខាន់ៗនៅក្នុងឯកសារបណ្តុះបណ្តាល ស្តីពី ផ.អ.គ.ស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសាលាអភិបាលកិច្ច ឬនាយកដ្ឋានបណ្តុះបណ្តាលរបស់ក្រសួងមហាផ្ទៃ ឬសាលាជាតិរដ្ឋបាលមូលដ្ឋាន។
- រៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់សមាជិកក្រុមការងារ ផ.អ.គ.ស ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយនៃអង្គភាពផ្តល់សេវាដែលបានបង្ហាញពីកំណើននៃសមត្ថភាព និងប្រសិទ្ធភាព ក្នុងការបំពេញការងារធៀបនឹងស្តង់ដារដែលបានកំណត់ | ៥០% | ៦០% | ៧០% | ៨០% | ៩០% |
| ការបញ្ចូលប្រធានបទស្តីពីផ.អ.គ.ស ក្នុងវគ្គជាកាតព្វកិច្ចរបស់ថ្នាក់ដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយសាលាអភិបាលកិច្ច ឬនាយកដ្ឋានបណ្តុះបណ្តាលរបស់ក្រសួងមហាផ្ទៃ ឬដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ |
| ការបញ្ជ្រាបក្នុងស្ថាប័ន និងអង្គភាពសាមី ស្តីពី ផ.អ.គ.ស | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និង គ.គ.អ.ស។

**លទ្ធផលរំពឹងទុក ៤.២.២ ការបណ្តុះបណ្តាលដល់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ**

**សកម្មភាពជាចម្បងៗ**

- ពិនិត្យឡើងវិញ និងកែសម្រួលគោលការណ៍ណែនាំ និងធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលសម្រាប់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ។
- បណ្តុះបណ្តាលសមាជិកគណៈកម្មាធិការ ផ.ស.រ.គ

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ភាគរយនៃគណៈកម្មាធិការ ផ.ស.រ.គ ដែលបានទទួលការបណ្តុះបណ្តាល | ៦០% | ៧០% | ៨០% | ៨៥% | ៩០% |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវានានា និងអង្គការសង្គមស៊ីវិល ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ។

**សមិទ្ធផលរំពឹងទុកទី៤.៣÷ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មានឆន្ទៈ និងអាចដឹកនាំដំណើរការផ្សព្វផ្សាយព័ត៌មាននានា ពិនិត្យតាមដាន និងជំរុញការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធទៅនឹងគណនេយ្យភាពសង្គមប្រកបដោយគុណភាព ប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ២ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៤.៣.១. ការបណ្តុះបណ្តាល ណែនាំ និងហ្វឹកហ្វឺនអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍**

**សកម្មភាពជាចម្បងៗ**

- ជ្រើសរើស និងបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល។
- ធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលសម្រាប់ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ណែនាំ និងហ្វឹកហ្វឺនបន្ថែមដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅតាមសហគមន៍ ដោយរៀនសូត្របណ្តើរ អនុវត្តបណ្តើរ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

អង្គការសង្គមស៊ីវិល អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដោយមានការចូលរួមពីអង្គភាពផ្តល់សេវានៅមូលដ្ឋានជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ។

**លទ្ធផលរំពឹងទុក ៤.៣.២. តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ត្រូវបានបង្កើត និងដំណើរការ**

**សកម្មភាពជាចម្បងៗ**

- រៀបចំបង្កើតលក្ខខណ្ឌការងារ និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

- បណ្តុះបណ្តាលដល់តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់អ្នកសម្របសម្រួលគណនេយ្យសហគមន៍ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានបង្កើតបណ្តុះបណ្តាល និងដំណើរការ | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

អង្គការសង្គមស៊ីវិល តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ។

**សមិទ្ធផលរំពឹងទុកទី ៤.៤ ការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ ស្តីពី ផ.អ.គ.ស**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន១ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៤.៤.១. ផែនការអនុវត្តគណនេយ្យភាពសង្គម ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងក្រសួង ស្ថាប័ន អង្គភាពសាមី និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**សកម្មភាពជាចម្បងៗ**

- ផ្តល់កិច្ចសន្យាការងាររយៈពេលខ្លីដល់អ្នកជំនាញផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (ICT) ដើម្បីជួយបង្កើត ឧបករណ៍ផ្សព្វផ្សាយ ផ.អ.គ.ស (ឧ. ការប្រមូល និងផ្សព្វផ្សាយទិន្នន័យ I4Cs និងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋតាមអេឡិចត្រូនិក)។
- រៀបចំសម្ភារៈ និងឧបករណ៍សម្រាប់ផ្សព្វផ្សាយ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្តីពី ផ.អ.គ.ស។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ឧបករណ៍សម្រាប់ផ្សព្វផ្សាយ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្តីពី ផ.អ.គ.ស ត្រូវបានបង្កើតឡើង និងធ្វើបច្ចុប្បន្នភាព | ✓ | ✓ | ✓ | ✓ | ✓ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ដោយមានការចូលរួមពីក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល ក្រោមការសម្របសម្រួលដឹកនាំរបស់ លេខាធិការដ្ឋាន គ.ជ.អ.ប. និង គ.គ.អ.ស។

## ឃ. ថវិកាប៉ាន់ស្មាន

| សមាសភាគទី៤ | អ្នកអនុវត្ត | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|
| ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព និងទំនាក់ទំនង | ផ្នែកផ្គត់ផ្គង់ | 605,000$ | 740,000$ | 840,000$ | 606,398$ | 490,000$ | 3,281,398$ |
| | ផ្នែកតម្រូវការ | 1,194,248$ | 1,018,410$ | 976,316$ | 786,215$ | 746,015$ | 4,721,204$ |
| | សរុប | 1,799,248$ | 1,758,410$ | 1,816,316$ | 1,392,613$ | 1,236,015$ | 8,002,602$ |

# សមាសភាគទី៥
# ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ក. សេចក្តីផ្តើម

**សមាសភាគទី៥** មានគោលបំណងធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការអនុវត្ត ផ.អ.គ.ស និងបង្កើតគោលការណ៍ និងយន្តការសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត មេរៀនជាប្រចាំ ខណៈដែលបទពិសោធន៍ត្រូវបានចងក្រង និងធ្វើការវិភាគជាបន្តបន្ទាប់ ដើម្បីកែសម្រួល និងកែលម្អការអនុវត្ត និងដំណើរការអនុវត្តនានា។

សកម្មភាពនានាដែលមានក្នុងសមាសភាគទី៥នេះ គឺត្រូវបានអនុវត្តជាប្រចាំដើម្បីគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃដល់ដំណើរការអនុវត្តសកម្មភាពក្នុងសមាសភាគទី១-ទី៤ ក៏ដូចជាការប្រមូលចងក្រងមេរៀនបទពិសោធន៍ពីការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងសមាសភាគទាំងនោះ។

## ខ.វឌ្ឍនភាព បញ្ហាប្រឈម និងចំណុចកែលម្អ

ការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ ដែលទាក់ទងនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះបានទទួលនូវលទ្ធផលល្អប្រសើរជាវិជ្ជមានសំខាន់ៗមានដូចខាងក្រោម៖

- យន្តការសម្របសម្រួលរួមរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ត្រូវបានបង្កើតឡើង (គ.គ.អ.ស) នឹងកំពុងបន្តអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។
- ការសិក្សាវាយតម្លៃផលប៉ះពាល់ដើមគ្រា នៃផ.អ.គ.ស ត្រូវបានបញ្ចប់ (ការប្រមូលទិន្នន័យ និងការវិភាគចុងគ្រា នឹងត្រូវធ្វើឡើងក្នុងត្រីមាសទី២នៅឆ្នាំ ២០១៩) ដោយស្ថាប័នឯករាជ្យមួយ។
- សកម្មភាពសិក្សារៀនសូត្រ ការឆ្លុះបញ្ចាំង កិច្ចប្រតិបត្តិការ និងសវនកម្មដំណើរការអនុវត្តសកម្មភាព ផ.ស.រ.គ ត្រូវបានធ្វើឡើង និងចងក្រងទុកជាឯកសារ។
- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។
- សេចក្តីណែនាំប្រតិបត្តិការ គោលការណ៍អនុវត្ត ផ.អ.គ.ស ត្រូវបានពិនិត្យឡើងវិញ និងកែសម្រួលជាញឹកញាប់ ដោយផ្អែកតាមមេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តជាក់ស្តែង។

ទន្ទឹមនឹងទទួលបានលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី១ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ហិរញ្ញប្បទានសម្រាប់សកម្មភាពរបស់ផ្នែកតម្រូវការ ដែលទទួលបានការគាំទ្រហិរញ្ញវត្ថុតាមរយៈកិច្ចព្រមព្រៀងគ្នារវាងដៃគូអភិវឌ្ឍន៍ផ្សេងៗ និងអង្គការដៃគូចម្រុះ មានភាពសាំញ៉ាំ

ពិបាកគ្រប់គ្រង និងរៀបចំផែនការសកម្មភាពក្នុងការអនុវត្តពុំបានរលូន ដោយដៃគូអភិវឌ្ឍន៍មួយចំនួនបានកាត់បន្ថយ ឬបញ្ឈប់ផ្តល់មូលនិធិរបស់ខ្លួនមុនផែនការកំណត់។

- ទំនាក់ទំនង និងការសម្របសម្រួលនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក របស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនពុំទាន់បានប្រព្រឹត្តទៅដោយរលូននៅឡើយ ទោះបីជាបានបង្កើតមន្ត្រីបង្គោលនៅតាមគ្រប់ខេត្ត ស្រុកគោលដៅនិងក្រុមការងារ ផ.អ.គ.ស នៅថ្នាក់ស្រុកនិងខេត្តគោលដៅមួយចំនួនក៏ដោយ។
- ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិលដៃគូអនុវត្ត ផ.អ.គ.ស និងអង្គការដែលបំពេញការងារពាក់ព័ន្ធតាមវិស័យនីមួយៗ ដែលអាចជួយគាំទ្រការងារគ្នាទៅវិញទៅមក ជាពិសេសនៅថ្នាក់ក្រោមជាតិ នៅមានកម្រិតនៅឡើយ។

ផ្អែកតាមមេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនៃការអនុវត្ត ផ.អ.គ.ស នៅដំណាក់កាលទី១ ដូចបានរៀបរាប់ខាងលើ បានជួយកំណត់រកចំណុចកែលម្អនានា ហើយការកែសម្រួល និងចំណុចថ្មីៗសម្រាប់សមាសភាគទី៥ ក្នុង ផ.អ.គ.ស ដំណាក់កាលទី២ នឹងរួមបញ្ចូលចំណុចសំខាន់ៗមានដូចខាងក្រោម៖

- ***បង្កើតមូលនិធិបរធនបាលកិច្ច (Trust Fund) ពីដៃគូអភិវឌ្ឍន៍ ចម្រុះសម្រាប់ ផ.អ.គ.ស៖*** មូលនិធិបរធនបាលកិច្ច ពីដៃគូអភិវឌ្ឍន៍ចម្រុះ នឹងត្រូវបានបង្កើតឡើងដើម្បីផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តសកម្មភាព ផ.អ.គ.ស ក្នុងលក្ខណៈដែលមានការសម្របសម្រួល។ មូលនិធិនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តសកម្មភាពផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ក្នុង ផ.អ.គ.ស។ កិច្ចប្រជុំបច្ចេកទេស ឬសម្របសម្រួលត្រីភាគីប្រចាំត្រីមាស រវាងក្រុមមូលនិធិបរធនបាលកិច្ច លេខាធិការដ្ឋាន គ.ជ.អ.ប. និងអ្នកសម្របសម្រួលផ្នែកតម្រូវការ នឹងត្រូវបានរៀបចំឡើងដើម្បីធ្វើបច្ចុប្បន្នភាពស្តីពីវឌ្ឍនភាព និងពិភាក្សាពីបញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធទៅនឹងដំណើរការអនុវត្ត ផ.អ.គ.ស។
- ***បន្តលើកកម្ពស់តួនាទី ភារកិច្ចសម្របសម្រួលផ្នែកផ្គត់ផ្គង់របស់ លេខាធិការដ្ឋាន គ.ជ.អ.ប.៖*** ក្នុងដំណាក់កាលទី២ ក្រសួង ស្ថាប័នសាមីនឹងមានការទទួលខុសត្រូវកាន់តែច្រើនក្នុងការអនុវត្ត ផ.អ.គ.ស ដោយនឹងបញ្ជ្រាប ផ.អ.គ.ស ទៅក្នុងផែនការសកម្មភាព និងថវិការបស់ខ្លួន ប៉ុន្តែ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងផ្តល់ប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដែលអនុវត្ត ផ.អ.គ.ស។
- ***ធានានូវការសម្របសម្រួលជាប្រចាំផ្នែកតម្រូវការ៖*** នៅដំណាក់កាលទី២ ត្រូវធានាការសម្របសម្រួលប្រកដោយប្រសិទ្ធភាពក្នុងចំណោមអង្គការដៃគូអនុវត្ត រវាងតួអង្គផ្នែកតម្រូវការ និងតួអង្គផ្នែកផ្គង់ផ្គង់។ ចំណុចនេះពាក់ព័ន្ធទៅនឹង៖

  ១) ការរៀបចំលក្ខខណ្ឌការងារសម្រាប់អ្នកសម្របសម្រួលផ្នែកតម្រូវការក្នុង ផ.អ.គ.ស

២) ការជ្រើសរើសអ្នកសម្របសម្រួលផ្នែកតម្រូវការក្នុងការអនុវត្ត ផ.អ.គ.ស និង
៣) ការជ្រើសរើស (តាមរយៈដំណើរការប្រកួតប្រជែង) ស្ថាប័ន ឬក្រុមបណ្តុះបណ្តាលអ្នកសម្របសម្រួលផ្នែកតម្រូវការដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងនិរន្តរភាពមុខងារនេះ។

- ***គាំទ្រ និងរក្សាតួនាទី គ.គ.អ.ស៖*** ក្នុងដំណាក់កាលទី២ តួនាទី និងដំណើរការរបស់ គ.គ.អ.ស នឹងត្រូវពង្រឹងបន្ថែមដើម្បីចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្ត និងកិច្ចខិតខំប្រឹងប្រែងបង្កើតយន្តការ និងប្រព័ន្ធការងារជាគំរូដែលមាននិរន្តរភាពសម្រាប់ការអនុវត្ត ផ.អ.គ.ស ព្រមទាំងបង្កើនកិច្ចប្រជុំជាប្រចាំ និងការចុះតាមមូលដ្ឋានបន្ថែមទៀត។ គណៈកម្មាធិការ គ.គ.អ.ស នៅតែមានតួនាទីសំខាន់ ចាំបាច់ក្នុងការសម្របសម្រួលរួម និងធានានូវទំនាក់ទំនង និងកិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងតួអង្គផ្នែកតម្រូវការ និងតួអង្គផ្នែកផ្គត់ផ្គង់។
- ***បង្កើនទំនាក់ទំនង និងការសម្របសម្រួលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖*** ដើម្បីបង្កើនទំនាក់ទំនង និងការសម្របសម្រួលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ នឹងត្រូវបានជំរុញ និងគាំទ្រឱ្យបង្កើតក្រុមការងារ ផ.អ.គ.ស ចម្រុះនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានសមាសភាពរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវានីមួយៗ ព្រមទាំងតំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ និងគួររួមបញ្ចូលទាំងមន្ត្រីការិយាល័យប្រជាពលរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរៀបចំផែនការ និងថវិកា។ ក្រុមការងារនេះ គួរជួបប្រជុំប្រចាំត្រីមាស និងរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ដើម្បីពិនិត្យឡើងវិញលើ ផ.អ.គ.ស។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបចំពោះចំណុចដែលត្រូវកែលម្អឆ្លងតាមមេរៀនបទពិសោធន៍ដែលបានអនុវត្តនាដំណាក់កាលទី១ សមិទ្ធផល និងលទ្ធផលរំពឹងទុកពាក់ព័ន្ធទៅនឹងសមាសភាគទី៥ត្រូវបានកំណត់ និងបរិយាយមានដូចខាងក្រោម៖

**សមិទ្ធផលរំពឹងទុកទី ៥.១ ៖ ធានាការអនុវត្ត ផ.អ.គ.ស ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ១ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៥.១.១. ការគ្រប់គ្រង និងគាំទ្រការអនុវត្ត ផ.អ.គ.ស នឹងត្រូវបានរៀបចំឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីធានាការអនុវត្តប្រកបដោយលទ្ធផលល្អប្រសើរ**

**សកម្មភាពជាចម្បងៗ**

- បង្កើតឡើងនូវមូលនិធិបរធនបាលកិច្ច ពីដៃគូអភិវឌ្ឍន៍ចម្រុះ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ដំណើរការអនុវត្តសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី ២។

- លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រុមសម្របសម្រួលអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ផ្តល់សេវាប្រឹក្សាយោបល់ និងគាំទ្របច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗដែលមានបំណងអនុវត្ត ផ.អ.គ.ស ក្នុងវិស័យរបស់ខ្លួន។
- ជ្រើសរើស និងផ្តល់ហិរញ្ញវត្ថុដល់អ្នកសម្របសម្រួលសម្រាប់ផ្នែកតម្រូវការ ដោយមូលនិធិបរធនបាលកិច្ច
- បង្កើតក្រុមការងារ ផ.អ.គ.ស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកគំរូលក្ខខណ្ឌការងារនៃក្រុមការងារនេះដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប.
- យុទ្ធសាស្ត្រលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមសម្រាប់បង្កើនការចូលរួមរបស់ក្រុមជនងាយរងគ្រោះដូចជា៖ ជនជាតិដើមភាគតិច មនុស្សចាស់ជរា ជនពិការ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ស្រឡាញ់ទាំង២ភេទ ក្រុមប្តូរយេនឌ័រ ត្រូវបានបង្កើតឡើង និងអនុវត្ត។

### ចំណុចដៅ

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការបង្កើតមូលនិធិបរធនបាលកិច្ច ពីដៃគូអភិវឌ្ឍន៍ចម្រុះដើម្បីផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី ២ | ✓ | | | | |
| ភាគរយនៃតំបន់គោលដៅដែលបានបង្កើតក្រុមការងារ ផ.អ.គ.ស របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ៥០% | ៦០% | ៧០% | ៨០% | ៨៥% |

### ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រ និងសម្របសម្រួលរបស់ក្រុមការងារមូលនិធិបរធនបាលកិច្ច និងក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល។

## សមិទ្ធផលរំពឹងទុកទី៥.២ ៖ ការកែសម្រួលមួយចំនួនលើគោលនយោបាយ គោលការណ៍ណែនាំ ដោយផ្អែកលើមេរៀនបទពិសោធន៍ នៃការអនុវត្តសកម្មភាព ផ.អ.គ.ស

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន ២ ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ៥.២.១. ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់**

**សកម្មភាពជាចម្បងៗ**

- កែសម្រួល សៀវភៅណែនាំស្តីពីប្រតិបត្តិការ ផ.អ.គ.ស សម្រាប់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ
- រៀបចំធ្វើទស្សនកិច្ចសិក្សាស្វែងយល់របស់ គ.គ.អ.ស នៅតាមតំបន់គោលដៅអនុវត្ត ផ.អ.គ.ស

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| សៀវភៅណែនាំស្តីពីប្រតិបត្តិការ ផ.អ.គ.ស សម្រាប់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការត្រូវបានកែសម្រួល | ✓ | | | | |
| ចំនួនខេត្តគោលដៅដែលបានអនុវត្ត ផ.អ.គ.ស ត្រូវបានធ្វើទស្សនកិច្ចសិក្សារបស់ គ.គ.អ.ស | ៣ | ៣ | ៣ | ៣ | ៣ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រសម្របសម្រួល របស់ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។

**លទ្ធផលរំពឹងទុក ៥.២.២. ការតាមដាន ត្រួតពិនិត្យ និងការចងក្រងមេរៀនបទពិសោធន៍**

**សកម្មភាពជាចម្បងៗ**

- កែសម្រួលនូវផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលបានរៀបចំ និងអនុវត្ត ផ.អ.គ.ស ក្នុងដំណាក់កាលទី១។
- រៀបចំធ្វើការអង្កេតលើការសិក្សាវាយតម្លៃផលប៉ះពាល់ដើមគ្រា ពាក់កណ្តាលគ្រា និងចុងគ្រាក្នុងដំណើការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២។
- បង្កើត និងរៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាសនូវក្រុមការងារ ផ.អ.គ.ស ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- រៀបចំកិច្ចប្រជុំប្រចាំឆមាស ឬកិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំតាមការចាំបាច់របស់ គ.គ.អ.ស
- រៀបចំកិច្ចប្រជុំបច្ចេកទេសប្រចាំឆមាស ឬកិច្ចប្រជុំតាមការចាំបាច់ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រុមអ្នកសម្របសម្រួលផ្នែកអង្គការសង្គមស៊ីវិល និងក្រុមការងារមូលនិធិបរធនបាលកិច្ចដើម្បីពិនិត្យពីវឌ្ឍនភាព ព្រមទាំងរៀបចំ ចងក្រង និងកែសម្រួលនូវឯកសារពាក់ព័ន្ធទៅនឹងការអនុវត្ត ផ.អ.គ.ស។
- រៀបចំកិច្ចប្រជុំជាប្រចាំរវាងអង្គការសង្គមស៊ីវិលដែលអនុវត្ត ផ.អ.គ.ស និងអង្គការដៃគូអនុវត្តដែលប្រតិបត្តិការនៅមូលដ្ឋានក្នុងវិស័យពាក់ព័ន្ធ។

**ចំណុចដៅ**

| ចំណុចដៅ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ផែនការតាមដានពិនិត្យ និងវាយតម្លៃដែលបាន រៀបចំ និងអនុវត្តក្នុង ដំណាក់កាលទី១ ត្រូវបាន ធ្វើបច្ចុប្បន្នភាព | ✓ | | | | |
| កិច្ចប្រជុំប្រចាំឆមាស ឬ ប្រចាំឆ្នាំ និងតាមការ ចាំបាច់ របស់ គ.គ.អ.ស ត្រូវបានរៀបចំ | ✓ | ✓ | ✓ | ✓ | ✓ |
| កិច្ចប្រជុំបច្ចេកទេសប្រចាំ ឆមាស ឬតាមការចាំបាច់ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រុមអ្នកសម្រប សម្រួលផ្នែកអង្គការ សង្គមស៊ីវិល និងក្រុម ការងារមូលនិធិបរធនបាល កិច្ចត្រូវបានរៀបចំ | ✓ | ✓ | ✓ | ✓ | ✓ |
| ភាគរយនៃតំបន់គោលដៅ ដែលបានរៀបចំកិច្ចប្រជុំ រៀងរាល់ត្រីមាសរបស់ ក្រុមការងារ ផ.អ.គ.ស ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ៣០% | ៥០% | ៦០% | ៧០% | ៨០% |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

លេខាធិការដ្ឋាន គ.ជ.អ.ប. រួមជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលជាអ្នកអនុវត្តនូវលទ្ធផលរំពឹងទុកនេះ ក្រោមការសម្របសម្រួលដឹកនាំរបស់ គ.គ.អ.ស ព្រមទាំងមានការចូលរួមគាំទ្រ និងសម្របសម្រួលរបស់ក្រុមសម្របសម្រួលផ្នែកសង្គមស៊ីវិល និងក្រុមការងារមូលនិធិបរធនបាលកិច្ច។

## ឃ. ថវិកាប៉ាន់ស្មាន

| សមាសភាគទី៥ | អ្នកអនុវត្ត | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|
| ការគ្រប់គ្រងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ផ្នែកផ្គត់ផ្គង់ | 1,034,600$ | 1,187,600$ | 1,204,600$ | 1,184,600$ | 1,163,565$ | 5,774,965$ |
| | ផ្នែកតម្រូវការ | 692,572$ | 829,767$ | 761,470$ | 844,829$ | 942,677$ | 4,071,315$ |
| | សរុប | 1,727,172$ | 2,017,367$ | 1,966,070$ | 2,029,429$ | 2,106,242$ | 9,846,280$ |

# ជំពូកទី៣

# ការគ្រប់គ្រងផែនការអនុវត្ត

# គណនេយ្យភាពសង្គមដំណាក់កាលទី២

## ជំពូកទី៣ ៖ ការគ្រប់គ្រងផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២

### ១. ការរៀបចំស្ថាប័ន

ការរៀបចំស្ថាប័ន ដើម្បីអនុវត្តការងារគណនេយ្យភាពសង្គមនឹងត្រូវដំណើរការជាមួយរចនាសម្ព័ន្ធដែលមានស្រាប់ដោយសារតែ ផ.អ.គ.ស គឺជាសកម្មភាពនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តទូទាំងប្រទេស ដើម្បីជួយគាំទ្រ និងពង្រឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ សកម្មភាពទាំងឡាយនឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ឬដោយតួអង្គទាំងពីរ(ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ) រួមគ្នា។ ក្នុងការអនុវត្តជាក់ស្តែង សកម្មភាពមួយចំនួនដែលបានរៀបរាប់នៅក្នុងសមាសភាគទាំង៥របស់ ផ.អ.គ.ស នឹងត្រូវអនុវត្តដោយផ្នែកផ្គត់ផ្គង់ សកម្មភាពខ្លះទៀតត្រូវអនុវត្តដោយផ្នែកតម្រូវការ ហើយសកម្មភាពខ្លះទៀតនឹងត្រូវអនុវត្តរួមគ្នាដើម្បីបង្កើនគុណភាព ប្រសិទ្ធភាពឱ្យកាន់តែប្រសើរឡើង។ សកម្មភាពមួយចំនួននៃការងារគណនេយ្យភាពសង្គមត្រូវដឹកនាំដោយស្ថាប័នរាជរដ្ឋាភិបាលដូចជា ការចេញគោលការណ៍ណែនាំនានាដើម្បីឱ្យមានការបិទផ្សព្វផ្សាយព័ត៌មាន ចំណែកសកម្មភាពមួយចំនួនទៀត រួមមានការត្រួតពិនិត្យតាមដាន និងការវាយតម្លៃរបស់ប្រជាពលរដ្ឋ ត្រូវអនុវត្តដោយតម្លាភាព និងមានការគាំទ្រពីអង្គការដៃគូអនុវត្ត ហើយចំណេះដឹងនេះ ត្រូវប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តថា អ្នកណាត្រូវធ្វើអ្វី និងត្រូវរៀបចំដោយរបៀបណា។ ជាការសំខាន់ណាស់ដែលត្រូវធ្វើការកត់សម្គាល់ថា បើទោះបីជាមានសកម្មភាពខ្លះត្រូវអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាលក៏ដោយ ក៏អង្គការសង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការសហការ និងគាំទ្រគ្នាទៅវិញទៅមកដែរ។ ដើម្បីធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការកសាងទំនាក់ទំនងការងារឱ្យទទួលបានលទ្ធផលល្អប្រសើររវាងស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិលនៅគ្រប់កម្រិត គឺជាកត្តាចម្បងដែលធ្វើឱ្យការអនុវត្ត ផ.អ.គ.ស ទទួលបានលទ្ធផលជោគជ័យ។

គោលបំណងដ៏សំខាន់មួយនៃ ផ.អ.គ.ស ដំណាក់កាលទី២ គឺការបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ច និងគ្រប់គ្រងការងារឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ និងការសម្របសម្រួលរវាងផ្នែកទាំងពីរនេះ។ ផ.អ.គ.ស ដំណាក់កាលទី ២ នឹងមាន៖

១) រួមបញ្ចូលតួនាទីក្រុមការងារបច្ចេកទេសសម្របសម្រួលផ្នែកផ្គត់ផ្គង់ របស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

២) លើកកម្ពស់តួនាទីរបស់ក្រសួង ស្ថាប័នសាមីឱ្យមានលក្ខណៈជាផ្លូវការក្នុងការអនុវត្តសកម្ម ភាពក្នុងវិស័យរបស់ខ្លួន

៣) បង្កើតក្រុមសម្របសម្រួលផ្នែកតម្រូវការ និងក្រុមមូលនិធិបរធនបាលកិច្ច

៤) ពង្រឹងតួនាទី ភារកិច្ចរបស់ គ.គ.អ.ស

៥) បង្កើនទំនាក់ទំនង និងការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើតក្រុមការងារ ផ.អ.គ.ស នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង

៦) បង្កើតមូលនិធិបរធនបាលកិច្ច ពីដៃគូអភិវឌ្ឍន៍ ដែលគ្រប់គ្រងដោយធនាគារពិភពលោក ដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាព ផ.អ.គ.ស ដំណាក់កាលទី ២ ឬផ្តល់ហិរញ្ញប្បទានដើម្បីគាំទ្រការអនុវត្តសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី ២ ដោយដៃគូអភិវឌ្ឍន៍នានា។

## ២. តួអង្គ និងការទទួលខុសត្រូវក្នុង ផ.អ.គ.ស

ដើម្បីអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ ប្រកបដោយគុណភាព ប្រសិទ្ធភាព ត្រូវមានការចូលរួមយ៉ាងសកម្មទាំងតួអង្គផ្នែកផ្គត់ផ្គង់ និងតួអង្គផ្នែកតម្រូវការ។ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់តួអង្គផ្សេងៗក្នុងរចនាសម្ព័ន្ធ នៃការរៀបចំស្ថាប័នអនុវត្ត ផ.អ.គ.ស មានបរិយាយដូចខាងក្រោម៖

**រូបភាពទី២៖ រចនាសម្ព័ន្ធ នៃការរៀបចំផ្នែកស្ថាប័នអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២**



**គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស) ៖**

គ.គ.អ.ស គឺជាយន្តការមួយដើម្បីគាំទ្របច្ចេកទេស សម្របសម្រួល និងផ្តល់កិច្ចសហការ រវាងតួអង្គផ្នែកផ្គត់ផ្គង់ ផ្នែកតម្រូវការ និងអ្នកពាក់ព័ន្ធនានា នៃការអនុវត្ត ផ.អ.គ.ស និងផ្តល់វេទិការួមសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល ដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ក្នុងនាមជាអ្នកសង្កេតការណ៍ ដើម្បីផ្តល់យោបល់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងធានានូវការត្រួតពិនិត្យលើការអនុវត្ត ផ.អ.គ.ស មានដូចជា៖ គោលនយោបាយ ការរៀបចំកម្មវិធី ការរៀបចំហិរញ្ញប្បទាន តំបន់គោលដៅអនុវត្ត ការពង្រីកសេវា និងដំណើការអនុវត្ត ផ.អ.គ.ស។ ក្នុងដំណាក់កាលទី ២ នៃ ផ.អ.គ.សនេះ គ.គ.អ.ស នៅតែមានតួនាទី ភារកិច្ចសំខាន់ក្នុងបរិបទនេះ។ គណៈកម្មាធិការនេះគួរជួបប្រជុំប្រចាំឆមាស ឬប្រចាំឆ្នាំ ឬកិច្ចប្រជុំតាមការចាំបាច់របស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្ត កិច្ចខិតខំប្រឹងប្រែងអនុវត្តជាយន្តការ នៃការអនុវត្ត ផ.អ.គ.ស ដែលមានលក្ខណៈអចិន្ត្រៃយ៍ និងនិរន្តរភាព។ បន្ទាប់ពីការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ គណៈកម្មាធិការនេះ នៅតែមានតួនាទី ភារកិច្ចចាំបាច់ក្នុងការរៀបចំកម្មវិធី ផែនការអនុវត្តគណនេយ្យភាពសង្គម និងធានានូវទំនាក់ទំនង និងកិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងតួអង្គផ្នែកផ្គត់ផ្គង់ និងតួអង្គផ្នែកតម្រូវការ ព្រមទាំងផ្តល់ការណែនាំជាគន្លឹះ និងត្រួតពិនិត្យលើផ្នែកទាំងអស់នៃដំណើរការអនុវត្ត ផ.អ.គ.ស។

**លេខាធិការដ្ឋាន គ.ជ.អ.ប.៖** ក្នុងដំណាក់កាលទី២ ទោះបីក្រសួង ស្ថាប័នសាមី នឹងមានការទទួលខុសត្រូវកាន់តែច្រើនលើសកម្មភាព ផ.អ.គ.ស ក្នុងវិស័យរបស់ខ្លួនក៏ដោយ លេខាធិការដ្ឋាន គ.ជ.អ.ប. នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលសកម្មភាពផ្នែកផ្គត់ផ្គង់ និងការទំនាក់ទំនងជាក្រុមសម្របសម្រួលផ្នែកតម្រូវការ ដើម្បីត្រួតពិនិត្យការផលិតកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) ប្រចាំឆ្នាំ គ្រប់គ្រងប្រព័ន្ធទិន្នន័យត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ផ្តល់គោលការណ៍ណែនាំពាក់ព័ន្ធនឹង ផ.អ.គ.ស និងធានាថារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសដើម្បីចូលរួមក្នុងសកម្មភាព ផ.អ.គ.ស ប្រកបដោយគុណភាព ប្រសិទ្ធភាព។ ក្រៅពីនេះ លេខាធិកាដ្ឋាន គ.ជ.អ.ប. នឹងគាំទ្រក្រសួង ស្ថាប័នសាមីទាំងអស់ដែលចង់បញ្ជ្រាប ផ.អ.គ.ស ក្នុងរចនាសម្ព័ន្ធ ការរៀបចំកម្មវិធី គោលនយោបាយ និងការរៀបចំផែនការសកម្មភាព និងថវិការបស់ខ្លួន។

**អ្នកសម្របសម្រួលផ្នែកតម្រូវការនៃការអនុវត្ត ផ.អ.គ.ស៖** ក្នុងដំណាក់កាលទី២ អ្នកសម្របសម្រួលផ្នែកតម្រូវការនៃការអនុវត្ត ផ.អ.គ.ស នឹងសម្របសម្រួលសកម្មភាពរបស់ផ្នែកតម្រូវការក្នុងការអនុវត្ត ផ.អ.គ.ស ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទំនាក់ទំនងជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រុមមូលនិធិបរធនបាលកិច្ច ព្រមទាំងគាំទ្រ និងសម្របសម្រួលសកម្មភាពរបស់អង្គការសង្គមស៊ីវិល ដៃគូអនុវត្តនានា។

**ស្ថាប័ន ឬដៃគូបណ្តុះបណ្តាលនៅថ្នាក់ជាតិ៖** ស្ថាប័ន ឬដៃគូបណ្តុះបណ្តាលថ្នាក់ជាតិ (ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ) ពិគ្រោះយោបល់ជាមួយដៃគូអនុវត្ត ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលដែលពាក់ព័ន្ធ ផ.អ.គ.ស និងផ្តល់ការបណ្តុះបណ្តាលដល់គ្រូឧទ្ទេសទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ និងគាំទ្រការរៀបចំវេទិកាសិក្សារៀនសូត្រ ផ.អ.គ.ស ប្រចាំឆ្នាំ។ ស្ថាប័ននេះក៏នឹងគាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ផងដែរ។

**ក្រសួង ស្ថាប័នអនុវត្តនៅថ្នាក់ជាតិ៖** ក្នុងដំណាក់កាលទី២ ក្រសួង ស្ថាប័នសាមីនឹងមានការទទួលខុសត្រូវកាន់តែច្រើនលើសកម្មភាព ផ.អ.គ.ស ក្នុងវិស័យរបស់ខ្លួន ដូចជា៖ ផ្តល់គោលការណ៍ណែនាំដល់មន្ត្រីក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីចូលរួមគាំទ្រ ផ.អ.គ.ស ដោយបង្កើនការយល់ដឹង និងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រី និងបុគ្គលិកក្រសួង ស្ថាប័ន អង្គភាពទៅតាមការចាំបាច់ បែងចែកមូលនិធិសម្រាប់ការអនុវត្តសកម្មភាព ផ.អ.គ.ស ប្រចាំឆ្នាំ (ដូចជាការផលិតផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងបិទផ្សព្វផ្សាយ I4Cs សម្រាប់វិស័យនោះ និងចំណាយពាក់ព័ន្ធនឹងកិច្ចប្រជុំវាយតម្លៃដោយខ្លួនឯង និងកិច្ចប្រជុំរួម) និងអនុវត្តនីតិវិធីនានាដើម្បីពង្រឹងការឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញក្នុង I4Cs និងការអនុវត្តសកម្មភាព ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)។

**ក្រុមការងារផែនការអនុវត្តគណនេយ្យភាពសង្គមថ្នាក់រដ្ឋបាលរាជធានី ខេត្ត៖** ក្រុមការងារនេះមាន មន្ត្រីថ្នាក់រដ្ឋបាលរាជធានី ខេត្ត (អភិបាល ឬអភិបាលរង) ធ្វើជាប្រធាន និងរួមមានតំណាងរបស់មន្ទីរ អង្គភាពពាក់ព័ន្ធតាមវិស័យនីមួយៗ និងអង្គការសង្គមស៊ីវិល។ សមាជិកក្រុមការងារ នឹងត្រូវទទួលបានការបណ្តុះបណ្តាលយ៉ាងតិចរយៈពេលចំនួន១ថ្ងៃស្តីពី "ទិដ្ឋភាពទូទៅនៃ ផ.អ.គ.ស"។ ក្រុមការងារ ផ.អ.គ.ស ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំប្រចាំត្រីមាសដើម្បីពិនិត្យមើលវឌ្ឍនភាព បញ្ហាប្រឈម នៃការអនុវត្តការងារ សម្របសម្រួល គាំទ្របច្ចេកទេសនៃការអនុវត្តសកម្មភាព ផ្សព្វផ្សាយ ផ.អ.គ.ស នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងធានាបាននូវទំនាក់ទំនង និងកិច្ចសហការដោយប្រសិទ្ធភាពនៃអ្នកពាក់ព័ន្ធក្នុងការអនុវត្តការងារឱ្យស្របទៅតាមវដ្តនៃសកម្មភាព ផ.អ.គ.ស ប្រចាំឆ្នាំ។

**ក្រុមការងារផែនការអនុវត្តគណនេយ្យភាពសង្គមថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ៖** ក្រុមការងារនេះ មន្ត្រីថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល ឬអភិបាលរង) ធ្វើជាប្រធាន និងរួមមានការិយាល័យចំណុះពាក់ព័ន្ធតាមវិស័យនីមួយៗ ការិយាល័យប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល។ សមាជិកក្រុមការងារនឹងត្រូវបានទទួលការបណ្តុះបណ្តាលយ៉ាងតិចរយៈពេលចំនួន ១ថ្ងៃស្តីពី "ទិដ្ឋភាពទូទៅនៃ ផ.អ.គ.ស"។ ក្រុមការងារ ផ.អ.គ.ស ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីពិនិត្យមើលវឌ្ឍនភាព បញ្ហាប្រឈមនៃការអនុវត្តការងារ សម្របសម្រួល គាំទ្រសកម្មភាព ផ.អ.គ.ស ផ្សព្វផ្សាយពិភាក្សានិងឆ្លើយតបនឹងលទ្ធផលដែលបានរកឃើញក្នុង ផ.ស.រ.គ និង I4Cs ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រួតពិនិត្យតាមដានដំណើរការអនុវត្ត ផ.ស.រ.គ ព្រមទាំងធានាបាននូវទំនាក់ទំនង និងកិច្ច

សហការប្រកបដោយប្រសិទ្ធភាព នៃអ្នកពាក់ព័ន្ធក្នុងការអនុវត្តការងារឱ្យស្របទៅតាមវដ្តនៃសកម្មភាព ផ.អ.គ.ស ប្រចាំឆ្នាំ។

**អង្គភាពផ្តល់សេវាសាធារណៈ៖** ផ្តល់ព័ត៌មានពីទិន្នន័យលទ្ធផលបំពេញការងារ ថវិកាចំណូលចំណាយ និងផ្សព្វផ្សាយព័ត៌មានទិន្នន័យលទ្ធផលការងារ (Post-on) ចូលរួមកិច្ចប្រជុំវាយតម្លៃដោយខ្លួនឯង និងកិច្ចប្រជុំរួម រាយការណ៍ពីតម្រូវការនានាដែលទាមទារនូវការគាំទ្រពីថ្នាក់លើ ចូលរួមជាសមាជិកគណៈកម្មាធិការ ផ.ស.រ.គ និងគាំទ្រការអនុវត្ត ផ.ស.រ.គ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ៖** រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទទួលខុសត្រូវលើការបំពេញប្រមូល ពិនិត្យផ្ទៀងផ្ទាត់ បញ្ចូល និងផ្សព្វផ្សាយព័ត៌មានទិន្នន័យលទ្ធផលការងារ ដែលពាក់ព័ន្ធនឹងរដ្ឋបាលរបស់ខ្លួន ចូលរួមកិច្ចប្រជុំវាយតម្លៃដោយខ្លួនឯង និងកិច្ចប្រជុំរួម រាយការណ៍ពីតម្រូវការនានាដែលទាមទារនូវការគាំទ្រពីថ្នាក់លើ។ ប្រធានគណៈកម្មាធិការ ផ.ស.រ.គ ត្រូវធានាថា ផ.ស.រ.គ ត្រូវបានដាក់បញ្ចូលក្នុងដំណើរការកសាងកម្មវិធីវិនិយោគ និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់អភិបាលកិច្ច និងសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**មន្ត្រីបង្គោលគណនេយ្យភាពសង្គម៖** មន្ត្រីបង្គោលគណនេយ្យភាពសង្គម (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) សម្របសម្រួលការងារទូទៅជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ចូលរួមផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ផ.អ.គ.ស សម្របសម្រួលបណ្តុះបណ្តាល គាំទ្រការអនុវត្ត ផ.អ.គ.ស និង ផ.ស.រ.គ ព្រមទាំងរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព បញ្ហាប្រឈមនៃការអនុវត្ត ផ.អ.គ.ស ជូនថ្នាក់ដឹកនាំ គាំទ្រដំណើរការបំពេញទម្រង់ការប្រមូល ការពិនិត្យផ្ទៀងផ្ទាត់ ការបញ្ចូលទិន្នន័យ ការផលិត និងការចែកចាយទិន្នន័យលទ្ធផលការងារ (Post-on) និងផ្តល់កិច្ចសហការជាមួយផ្នែកតម្រូវការ។

**អង្គការសង្គមស៊ីវិល និងអង្គការដៃគូអនុវត្ត៖** អង្គការសង្គមស៊ីវិល និងអង្គការដៃគូអនុវត្តនៅមូលដ្ឋានមួយចំនួននឹងទទួលខុសត្រូវលើការអនុវត្តសកម្មភាពផ្នែកតម្រូវការរបស់ ផ.អ.គ.ស រួមមាន៖ ជ្រើសរើសបណ្តុះបណ្តាល គាំទ្របច្ចេកទេស និងណែនាំហ្វឹកហ្វឺនដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងជួយសម្របសម្រួលកិច្ចប្រជុំប័ណ្ណដាក់ពិន្ទុសហគមន៍ កិច្ចប្រជុំរួម និងសហការជាមួយផ្នែកផ្គត់ផ្គង់ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់គណៈកម្មាធិការ ផ.ស.រ.គ រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ផ.អ.គ.ស។

**អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍៖** អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយផ្សព្វផ្សាយ I4Cs ដល់ប្រជាពលរដ្ឋឱ្យទទួលបានការយល់ដឹងអំពីព័ត៌មាននានាពីសិទ្ធិ ស្តង់ដាការផ្តល់សេវាសាធារណៈ ការបំពេញតួនាទី ភារកិច្ច និងព័ត៌មានអំពីថវិការបស់អង្គភាពផ្តល់សេវា កំណត់រកសកម្មភាពកែលម្អសេវាសាធារណៈ សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ដើម្បីអនុវត្តសកម្មភាពទាំងនោះសំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ ប្រកបដោយ

គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ទទួលបានការបណ្តុះបណ្តាល អំពីការអនុវត្តការងារគណនេយ្យភាពសង្គមចំនួន៤ម៉ូឌុល និងចូលរួមក្នុងការសិក្សារៀនសូត្រពីការអនុវត្តផ្ទាល់នៅសហគមន៍ដែលផ្តោតលើការបង្កើនការយល់ដឹងពីខ្លឹមសារព័ត៌មានរបស់ I4Cs សម្របសម្រួលកិច្ចប្រជុំប័ណ្ណដាក់ពិន្ទុដោយសហគមន៍ កិច្ចប្រជុំរួម និងមានតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ចូលរួមជាសមាជិកគណៈកម្មាធិការ ផ.ស.រ.គ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានជ្រើសរើសឱ្យបំពេញការងារដោយអង្គការសង្គមស៊ីវិល ឬអង្គការដៃគូអនុវត្តថ្នាក់មូលដ្ឋាន និងមានការឯកភាពយល់ព្រមពីអាជ្ញាធរមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**គណៈកម្មាធិការ ផ.ស.រ.គ៖** គណៈកម្មាធិការ ផ.ស.រ.គ មានតួនាទី និងភារកិច្ច ដើម្បីត្រួតពិនិត្យតាមដាន ពីវឌ្ឍនភាព បញ្ហាប្រឈម នៃដំណើរការអនុវត្ត ផ.ស.រ.គ។ គណៈកម្មាធិការនេះ មានសមាសភាពអាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា តំណាងប្រជាពលរដ្ឋ និងតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ជាពិសេសក្រុមតំណាងឱ្យស្ត្រី និងតំណាងក្រុមជនងាយរងគ្រោះ។ សមាជិកគណៈកម្មាធិការ ផ.ស.រ.គ ត្រូវបានជ្រើសរើសនៅក្នុងកិច្ចប្រជុំរួម និងទទួលបានការបណ្តុះបណ្តាលដើម្បីបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព។ សមាជិកគណៈកម្មាធិការនេះទទួលខុសត្រូវលើការអនុវត្ត និងផ្សព្វផ្សាយ ផ.ស.រ.គ ជាសាធារណៈ រៀបចំផែនការសកម្មភាពលម្អិត កៀរគរធនធាន សម្របសម្រួល និងគាំទ្រការអនុវត្ត ផ.ស.រ.គ ដែលបានព្រមព្រៀង ពិនិត្យតាមដានការអនុវត្ត ផ.ស.រ.គ និងរាយការណ៍ពីវឌ្ឍនភាពបញ្ហាប្រឈមជាសាធារណៈ។

**ប្រជាពលរដ្ឋ៖** ប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំដើម្បីរៀនសូត្រពីសិទ្ធិ ស្តង់ដា ការបំពេញការងារ និងថវិការបស់អង្គភាពផ្តល់សេវា ចូលរួមក្នុងកិច្ចប្រជុំប័ណ្ណដាក់ពិន្ទុសហគមន៍ និងកិច្ចប្រជុំរួម ដើម្បីលើកឡើងពីតម្រូវការជាអាទិភាពនានារបស់ខ្លួន និងពិភាក្សាពីការកែលម្អការផ្តល់សេវាសាធារណៈជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា ព្រមទាំងចូលរួមក្នុងការអនុវត្ត ផ.ស.រ.គ។

**ប្រព័ន្ធផ្សព្វផ្សាយ៖** ស្ថាប័នអនុវត្ត ផ.អ.គ.ស សហការជាមួយស្ថាប័ន ប្រព័ន្ធផ្សព្វផ្សាយ នៅថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិដើម្បីផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីពី ផ.អ.គ.ស I4Cs និងលទ្ធផល ផ.ស.រ.គ និងមេរៀនបទពិសោធន៍ការអនុវត្តជោគជ័យ នៃដំណើរការអនុវត្ត ផ.អ.គ.ស និងកៀរគរការចូលរួមអនុវត្ត ផ.ស.រ.គ។

**វិស័យឯកជន៖** ផ.អ.គ.ស ដំណាក់កាលទី២ នឹងខិតខំបង្កើនទំនាក់ទំនង និងកិច្ចសហការជាមួយវិស័យឯកជន ដើម្បីកៀរគរធនធាន គាំទ្រការអនុវត្ត ផ.ស.រ.គ។ ប្រសិនបើ ផ.អ.គ.ស ត្រូវគ្របដណ្តប់លើសេវាសាធារណៈកាន់តែច្រើនថែមទៀត ដូចជាការការពារធនធានធម្មជាតិ កសិកម្ម ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការគ្រប់គ្រងសំរាម និងកាកសំណល់រឹងទីប្រជុំជន កិច្ចគាំពារសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជាដើម។ អន្តរកម្មរវាងសេវាសាធារណៈទាំងនោះជាមួយវិស័យឯកជនពាក់ព័ន្ធពិតជាមានសារៈសំខាន់ណាស់នៅគ្រប់ដំណាក់កាលនៃដំណើរការអនុវត្ត ផ.អ.គ.ស។

**ដៃគូអភិវឌ្ឍន៍ មូលនិធិបរធនបាលកិច្ច៖** តាមរយៈមូលនិធិបរធនបាលកិច្ច ដៃគូអភិវឌ្ឍន៍ ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់ដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២។ មូលនិធិបរធនបាលកិច្ចនេះនឹងធានានូវការគ្រប់គ្រង និងរាយការណ៍ពីហិរញ្ញវត្ថុ ផ្តល់ជំនួយផ្នែកប្រតិបត្តិការ និងបច្ចេកទេសទៅតាមភាពចាំបាច់ដល់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ធ្វើការសិក្សា វិភាគទិន្នន័យ សម្របសម្រួល ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងរៀបចំកិច្ចប្រជុំបច្ចេកទេសជាប្រចាំ រវាងដៃគូអភិវឌ្ឍន៍ ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។

## ៣. និរន្តរភាព

គោលដៅចម្បង ផ.អ.គ.ស ដំណាក់កាលទី២ គឺការបង្កើតយន្តការអចិន្ត្រៃយ៍ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ដើម្បីធានាថាសកម្មភាពគណនេយ្យភាពសង្គមអាចអនុវត្តប្រកបដោយនិរន្តរភាពក្នុងរយៈពេលវែងដោយថវិកាពីរាជរដ្ឋាភិបាល និងត្រូវការជំនួយហិរញ្ញវត្ថុពីគ្រប់ភាគីពាក់ព័ន្ធ។ យុទ្ធសាស្ត្រអនុវត្តដើម្បីធានានិរន្តរភាព ផ.អ.គ.ស ត្រូវបានដាក់បញ្ចូលក្នុងផែនការអនុវត្តដូចខាងក្រោម៖

**និរន្តរភាព នៃការអនុវត្តផ្នែកផ្គត់ផ្គង់៖** សមាសធាតុដ៏សំខាន់មួយនៃនិរន្តរភាព ផ.អ.គ.ស គឺការបន្តបញ្ជ្រាបសកម្មភាពផ្នែកផ្គត់ផ្គង់ក្នុងគោលការណ៍ណែនាំ ផែនការសកម្មភាព និងថវិកាសំខាន់ៗរបស់ គ.ជ.អ.ប. ក្រសួង ស្ថាប័នតាមវិស័យ (នៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ)។ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរួម ហើយក្រសួង ស្ថាប័នសាមីនឹងមានការទទួលខុសត្រូវកាន់តែច្រើនតាមរយៈការដាក់បញ្ចូលការអនុវត្ត ផ.អ.គ.ស ក្នុងផែនការសកម្មភាព និងថវិការបស់ខ្លួន។ យុទ្ធសាស្ត្រជាក់លាក់ ដើម្បីសម្រេចបាននិរន្តរភាពផ្នែកផ្គត់ផ្គង់រួមមាន៖

១) ការចេញគោលការណ៍ណែនាំច្បាស់លាស់សម្រាប់តួអង្គផ្នែកផ្គត់ផ្គង់ (ដូចជា មន្ត្រីបង្គោលទទួលបន្ទុកការងារគណនេយ្យភាពសង្គម ក្រុមការងារ ផ.អ.គ.ស អ្នកផ្តល់សេវា និងគណៈកម្មាធិការ ផ.ស.រ.គ)។

២) ការដាក់បញ្ចូលការបណ្តុះបណ្តាល និងការហ្វឹកហ្វឺននៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ

៣) ក្រសួង ស្ថាប័នសាមី អង្គភាពផ្តល់សេវា ត្រូវទទួលខុសត្រូវលើការបំពេញទម្រង់ ការប្រមូល ការបញ្ចូលទិន្នន័យ ការចងក្រង និងបិទផ្សព្វផ្សាយទិន្នន័យ I4Cs ជាប្រចាំ។

៤) ការពង្រឹងប្រព័ន្ធទិន្នន័យឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងត្រូវបានប្រើប្រាស់សម្រាប់វិភាគលទ្ធផល បញ្ហាប្រឈម រៀបចំផែនការដោះស្រាយ និងកែលម្អ ដើម្បីឆ្លើយតបនឹងសកម្មភាពអាទិភាពនៃផ.ស.រ.គ។

៥) ការដាក់បញ្ចូលចំណាយ ផ.អ.គ.ស ដូចជាការបណ្តុះបណ្តាលតួអង្គផ្នែកផ្គត់ផ្គង់ ការផលិត និងការបិទផ្សព្វផ្សាយ I4Cs ការធ្វើបច្ចុប្បន្នប្រព័ន្ធទិន្នន័យ ការកែសម្រួល I4Cs និងចំណាយពាក់ព័ន្ធនឹងការអនុវត្ត និងត្រួតពិនិត្យតាមដាន ផ.ស.រ.គ ទៅក្នុងផែនការសកម្មភាព និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**និរន្តរភាព នៃការអនុវត្តផ្នែកតម្រូវការ៖** គោលបំណងសំខាន់មួយនៃ ផ.អ.គ.ស ដំណាក់កាលទី២ គឺការបង្កើនស្ថិរភាព និរន្តរភាព លើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តផ្នែកតម្រូវការ។ យុទ្ធសាស្ត្រជាក់លាក់ ដើម្បីសម្រេចបាននិរន្តរភាពផ្នែកតម្រូវការរួមមាន៖

១) ការជ្រើសរើស និងបណ្តុះបណ្តាលតំណាង និងក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍

២) ការទទួលស្គាល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ពីអ្នកពាក់ព័ន្ធជាពិសេសអាជ្ញាធរមូលដ្ឋាន

៣) ការពង្រឹងតួនាទី និងការចូលរួមរបស់ផ្នែកផ្គត់ផ្គង់ឱ្យកាន់តែច្រើនលើសកម្មភាពផ្នែកតម្រូវការ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី៦)។

**យុទ្ធសាស្ត្រនិរន្តរភាព៖** ការសម្រេចបាននិរន្តរភាព ផ.អ.គ.ស មួយផ្នែកធំគឺអាស្រ័យលើការចំណាយថវិកាមានប្រសិទ្ធភាព។ គោលដៅមួយនៃ ផ.អ.គ.ស ដំណាក់កាលទី ២ គឺការបញ្ជ្រាបការអនុវត្ត ផ.អ.គ.ស និងការធានាស័ក្តិសិទ្ធភាព ក៏ដូចជាធានាសុចរិតភាព និងប្រសិទ្ធភាពនៃគោលការណ៍ និងវិធីសាស្ត្រ ផ.អ.គ.ស ជាពិសេសភាពជាម្ចាស់របស់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការក្នុងការគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ធ្វើការឱ្យមានគុណភាព ប្រសិទ្ធភាព និងសហការយ៉ាងជិតស្និទជាមួយនឹងការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រនិរន្តរភាពក្នុងការអនុវត្ត ផ.អ.គ.ស និងអនុវត្តជាបណ្តើរៗ នៅលើតំបន់គោលដៅទាំងឡាយណា ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព និងយន្តការគាំទ្រកាន់តែប្រសើរឡើង។ ផ.អ.គ.ស ដំណាក់កាលទី២ នឹងជួយរៀបចំគោលការណ៍ណែនាំ និងអនុវត្តសាកល្បងជាគំរូនៅក្នុងមូលដ្ឋាន នៅតាមរដ្ឋបាលឃុំ សង្កាត់ ដែលបានអនុវត្ត ផ.អ.គ.ស រយៈពេលលើសពី៣ឆ្នាំ។ យុទ្ធសាស្ត្រនេះរួមមាន៖ ១) រិះរកមធ្យោបាយបង្កើន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងការអនុវត្តវិធីសាស្ត្រ ផ.អ.គ.ស បច្ចុប្បន្ន និង ២) អនុវត្តសាកល្បង ផ្លាស់ប្តូរវិធីសាស្ត្រ ផ.អ.គ.ស ដើម្បីកាត់បន្ថយចំណាយ ប៉ុន្តែរក្សាបាននូវប្រសិទ្ធភាព។ ប៉ុន្តែចាំបាច់ត្រូវទទួលស្គាល់ថា កម្រិតមួយចំនួននៃការផ្តល់ជំនួយហិរញ្ញវត្ថុជាបន្តបន្ទាប់ពិតជាសំខាន់ណាស់ សម្រាប់បន្តនិរន្តរភាពសកម្មភាពទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ នៃការអនុវត្ត ផ.អ.គ.ស។

## ៤. ការផ្តល់ហិរញ្ញប្បទាន

### ១) លំហូរថវិកា និងហិរញ្ញប្បទាន

នៅដំណាក់កាលទី១ នៃដំណើការអនុវត្តសកម្មភាពផ្នែកផ្គត់ផ្គង់ត្រូវបានគាំទ្រដោយមូលនិធិពីអង្គការ UNICEF ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍប្រទេសស្វីស (SDC) និងសហភាពអឺរ៉ុប (EU) តាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប.។ សកម្មភាពផ្នែកតម្រូវការត្រូវបានគាំទ្រដោយមូលនិធិពីសហភាពអឺរ៉ុប (EU) គាំទ្រដល់អង្គការ CARE ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) គាំទ្រដល់អង្គការ RACHA ធនាគារពិភពលោក (World Bank) គាំទ្រដល់អង្គការ Save the Children និង

អង្គការ World Vision និងអង្គការអុកស្វាមកម្ពុជា (OXFAM) គាំទ្រដល់អង្គការស្តារកម្ពុជា (Star Kampuchea)។ យន្តការនៃការផ្តល់ថវិកាគាំទ្រនេះបានដំណើរការប្រកបដោយលទ្ធផលល្អប្រសើរ ប៉ុន្តែការអនុវត្តជាក់ស្តែងបានជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា៖ ការផ្តល់ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ជាច្រើនដល់អង្គការសង្គមស៊ីវិលដៃគូអនុវត្តន៍ ក្នុងក្របខ័ណ្ឌពេលវេលា និងតាមទម្រង់បែបបទខុសៗគ្នា ព្រមទាំងមានការកាត់បន្ថយហិរញ្ញវត្ថុយ៉ាងច្រើនមុនការបញ្ចប់ដំណើការអនុវត្ត ផ.អ.គ.ស នៅចុង ដំណាក់កាលទី១ (ឧ. អង្គការ CARE និងអង្គការ RACHA) ដែលជាហេតុធ្វើឱ្យការអនុវត្តសកម្មភាព មួយចំនួននៃវដ្ត ផ.អ.គ.ស ប្រចាំឆ្នាំ២០១៨ ភាគច្រើនមិនបានអនុវត្តចប់តាមអនុស្សារណៈយោគយល់ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនិងអង្គការសង្គមស៊ីវិលដៃគូអនុវត្តទាំងនោះ។

ការគាំទ្រហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ មានសារៈសំខាន់សម្រាប់ដំណើរការអនុវត្ត នៃ ផ.អ.គ.ស ដំណាក់កាលទី២ នៅពេលដែលវិសាលភាពតំបន់គោលដៅអនុវត្តត្រូវបានពង្រីក ដោយគ្របដណ្តប់ លើរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេស និងសេវាផ្សេងៗទៀតត្រូវបានអនុវត្ត បន្ថែម។

ការបង្កើតមូលនិធិបរធនបាលកិច្ច (Trust Fund) ពីដៃគូអភិវឌ្ឍន៍ចម្រុះដែលគ្រប់គ្រងដោយ ធនាគារពិភពលោក សម្រាប់គាំទ្រដល់ដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ ទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ នឹងអាចជួយជំរុញដល់ការអនុវត្តទៅតាមផែនការសកម្មភាពឱ្យទទួលបាននូវលទ្ធផល ល្អប្រសើរ។

ការបង្កើតមូលនិធិបរធនបាលកិច្ច (Trust Fund) តែមួយនឹងជួយគាំទ្រការអនុវត្តសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី២ ទទួលហិរញ្ញប្បទានតាមរបៀបដែលមានការសម្របសម្រួល មានលក្ខណៈ ល្អប្រសើរ និងប្រសិទ្ធភាពជាងមុន។ មូលនិធិបរធនបាលកិច្ច នឹងជួយដល់ដៃគូបណ្តុះបណ្តាលឯកទេស ដែលអាចឱ្យគេកំណត់យក និងអនុវត្តតួនាទីនេះក្នុងរបៀបស្តង់ដាទូទាំងប្រទេស។ មូលនិធិនេះក៏នឹង ជួយគាំទ្រដល់ការអនុវត្តសកម្មភាពផ្នែកតម្រូវការ (អង្គការសង្គមស៊ីវិល) និងផ្នែកផ្គត់ផ្គង់ (លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ) ទោះបីជានៅពេលដែលសកម្មភាពផ្នែកផ្គត់ផ្គង់ត្រូវបានបញ្ជ្រាប កាន់តែច្រើនក្នុងផែនការសកម្មភាព និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង និងស្ថាប័នសាមី។

**សហភាពអឺរ៉ុប** (EU) បានផ្តល់ជំនួយថវិកាដល់អង្គការទស្សនៈពិភពលោក សម្រាប់អនុវត្ត សកម្មភាពផ្នែកតម្រូវការរបស់ ផ.អ.គ.ស ដោយគ្របដណ្តប់លើស្រុកគោលដៅចំនួន៣០ រដ្ឋបាលឃុំ គោលដៅចំនួន២៨៧ នៃខេត្តចំនួន៥ គឺខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង និងខេត្ត ពោធិ៍សាត់ សម្រាប់អនុវត្តក្នុងអំឡុងឆ្នាំ ២០១៩-២០២០។

**អង្គការអុកស្វាមកម្ពុជា** (OXFAM) បានកំណត់ការអនុវត្តការងារគណនេយ្យភាពសង្គមជាអាទិភាព នឹងផ្តល់ការគាំទ្រថវិកាដល់អង្គការស្តារកម្ពុជា សម្រាប់អនុវត្តសកម្មភាពផ្នែកតម្រូវការរបស់ ផ.អ.គ.ស ដោយគ្របដណ្តប់លើរដ្ឋបាលឃុំចំនួន២២ ក្នុងស្រុកគោលដៅចំនួន២ (ស្រុកចន្ទ្រា និងស្រុករមាសហែក) នៃខេត្តស្វាយរៀង។ ជាមួយគ្នានេះដែរ អង្គការអុកស្វាមកម្ពុជា បានគាំទ្រថវិកាដល់វិទ្យាស្ថានតស៊ូមតិ

និងគោលនយោបាយ (API) ដើម្បីគាំទ្រការអនុវត្តសកម្មភាព ផ.អ.គ.ស រដ្ឋបាលសង្កាត់ចំនួន៣ (សង្កាត់គោកឃ្លាង សង្កាត់ទឹកថ្លា និងសង្កាត់ឃ្មួញ) និងរដ្ឋបាលខណ្ឌសែនសុខចំនួន១ នៃរាជធានីភ្នំពេញ។

**ធនាគារពិភពលោក (World Bank)** នឹងផ្តល់ហិរញ្ញប្បទានក្នុងការអនុវត្តសាកល្បង ផ.អ.គ.ស នៃគម្រោងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅក្រុងគោលដៅចំនួន៣ (ក្រុងសៀមរាប ក្រុងស្ទឹងសែន និងក្រុងសែនមនោរម្យ នៃខេត្តចំនួន៣ រួមមានៈ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តមណ្ឌលគីរី។

**មូលនិធិបរធនបាលកិច្ច (Trust Fund)** ពីដៃគូអភិវឌ្ឍន៍ និងការកៀរគរហិរញ្ញប្បទានបន្ថែម កំពុងនឹងបានរៀបចំឡើងជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងវិភាជន៍មូលនិធិសម្រាប់ការអនុវត្តសកម្មភាពផ្នែកផ្គត់ផ្គង់ផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាលរាជធានី ខេត្តមួយចំនួនក៏បានគ្រោងថវិកា ដើម្បីគាំទ្រការអនុវត្តសកម្មភាព ផ.អ.គ.ស របស់ខ្លួន ប៉ុន្តែរដ្ឋបាលក្រុង ស្រុកនៅពុំទាន់មានថវិកាសម្រាប់អនុវត្តសកម្មភាពរបស់ខ្លួននៅឡើយ។

**២) ការចំណាយថវិកា**

ក្នុងរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ថវិកាដែលនឹងគ្រោងចំណាយក្នុងការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២ មានចំនួនប្រមាណ ៣២.៥២២.៦២៣ ដុល្លារអាមេរិកដែលក្នុងនោះថវិកាចំនួន ១២.៣៦០.៨៨១ ដុល្លារអាមេរិក (៤១%) សម្រាប់ផ្នែកផ្គត់ផ្គង់ និងថវិកាចំនួន ១៧.៦១៣.០៤៦ ដុល្លារអាមេរិក (៥៩%) សម្រាប់ផ្នែកតម្រូវការ រីឯថវិកាចំនួន ១.០០០.០០០ដុល្លារអាមេរិកទៀតសម្រាប់ការងាររដ្ឋបាលក្នុងការប្រតិបត្តិការមូលនិធិបរធនបាលកិច្ច (Trust Fund) និងថវិកាចំនួន ១.៥៤៨.៦៩៥ ដុល្លារអាមេរិក សម្រាប់ការចំណាយផ្សេងៗទៀតលើប្រតិបត្តិការមូលនិធិបរធនបាលកិច្ច។

**តារាងទី៤៖ ថវិកាប៉ាន់ស្មានសម្រាប់ ផ.អ.គ.ស ដំណាក់កាលទី២ (គិតជាដុល្លារអាមេរិក)**

| សមាសភាគ | អ្នកអនុវត្ត | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|
| សមាសភាគទី១៖ តម្លាភាព និងភាពងាយទទួលបានព័ត៌មាននានា | ផ្នែកផ្គត់ផ្គង់ | 121,449$ | 95,000 $ | 130,000 $ | 100,000 $ | 100,000 $ | 546,449 $ |
| | ផ្នែកតម្រូវការ | 612,379$ | 601,211$ | 682,574 $ | 796,527 $ | 910,495 $ | 3,603,185 $ |
| | សរុប | 733,828$ | 696,211$ | 812,574$ | 896,527$ | 1,010,495$ | 4,149,634$ |
| សមាសភាគទី២៖ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ | ផ្នែកផ្គត់ផ្គង់ | 41,000$ | 60,000$ | 100,000$ | 80,000$ | 66,076$ | 347,076$ |
| | ផ្នែកតម្រូវការ | 633,711$ | 722,189$ | 850,526$ | 890,799$ | 888,114$ | 3,985,338$ |
| | សរុប | 674,711$ | 782,189$ | 950,526$ | 970,799$ | 954,190$ | 4,332,414$ |
| សមាសភាគទី៣៖ ការអនុវត្តផ.ស.រ.គ | ផ្នែកផ្គត់ផ្គង់ | 697,400$ | 635,400$ | 558,180$ | 400,014$ | 120,000 $ | 2,410,994$ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ផ្នែកតម្រូវការ | 291,575$ | 294,621$ | 180,111$ | 173,549$ | 292,148$ | 1,232,004$ |
| | សរុប | 988,987$ | 930,021$ | 738,291$ | 573,563$ | 412,148$ | 3,643,998$ |
| សមាសភាគទី៤៖ ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព និងទំនាក់ទំនង | ផ្នែកផ្គត់ផ្គង់ | 605,000$ | 740,000$ | 840,000$ | 606,398$ | 490,000$ | 3,281,398$ |
| | ផ្នែកតម្រូវការ | 1,194,248$ | 1,018,410$ | 976,316$ | 786,215$ | 746,015$ | 4,721,204$ |
| | សរុប | 1,799,248$ | 1,758,410$ | 1,816,316$ | 1,392,613$ | 1,236,015$ | 8,002,602$ |
| សមាសភាគទី៥៖ ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ* | ផ្នែកផ្គត់ផ្គង់ | 1,034,600$ | 1,187,600$ | 1,204,600$ | 1,184,600$ | 1,163,565$ | 5,774,965$ |
| | ផ្នែកតម្រូវការ | 692,572$ | 829,767$ | 761,470$ | 844,829$ | 942,677$ | 4,071,315$ |
| | សរុប | 1,727,172$ | 2,017,367$ | 1,966,070$ | 2,029,429$ | 2,106,242$ | 9,846,280$ |
| សរុប | - | 5,923,934$ | 6,184,198$ | 6,283,777$ | 5,862,930$ | 5,719,090$ | 29,973,927$ |
| សរុបរងសម្រាប់ផ្នែកតម្រូវការ | - | 3,424,485$ | 3,466,197$ | 3,450,997$ | 3,491,918$ | 3,779,449$ | 17,613,046$ |
| សរុបរងសម្រាប់ផ្នែកផ្គត់ផ្គង់ | - | 2,499,449$ | 2,718,000$ | 2,832,780$ | 2,371,012$ | 1,939,641$ | 12,360,881$ |
| រដ្ឋបាលការសម្របសម្រួល និងជំនួយបច្ចេកទេស នៃមូលនិធិបរធនបាលកិច្ច | - | 140,000$ | 140,000$ | 290,000$ | 140,000$ | 290,000$ | 1,000,000$ |
| ថវិកាចំណាយផ្សេងៗ៥% | - | 303,196$ | 316,210$ | 328,689$ | 300,146$ | 300,454$ | 1,548,695$ |
| ថវិកាគ្រោងសរុប | - | 6,367,130$ | 6,640,407$ | 6,902,465$ | 6,303,077$ | 6,309,544$ | 32,522,623$ |
| ជំនួយហិរញ្ញវត្ថុ (ដោយសហភាពអឺរ៉ុប EU)** | - | 1,000,000 | 1,000,000 | - | - | - | 2,000,000 |
| ថវិកាគ្រោងដែលត្រូវការ | - | 6,367,130$ | 6,640,407$ | 6,902,465$ | 6,303,077$ | 6,309,544$ | 32,522,623$ |

*ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ភាគច្រើនរួមបញ្ចូលសកម្មភាពផ្នែកផ្គត់ផ្គង់ដែលពាក់ព័ន្ធនឹងការសម្របសម្រួល និងការគាំទ្រដំណើរការអនុវត្ត ផ.អ.គ.ស (ឧ. កិច្ចប្រជុំ គ.គ.អ.ស ដំណើរ

ទស្សនកិច្ចសិក្សាស្វែងយល់របស់ គ.គ.អ.ស វគ្គបណ្តុះបណ្តាលនានា កិច្ចប្រជុំសម្របសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចប្រជុំឆ្លុះបញ្ចាំង ការត្រួតពិនិត្យតាមដាន និងគាំទ្របច្ចេកទេសនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា។ល។) ។

**អត្រាប្តូរប្រាក់ (ដុល្លាអាមេរិក និងអឺរ៉ូ) មិនទាន់ត្រូវបានគិតបញ្ចូលនៅឡើយ ព្រោះសហភាពអឺរ៉ុបបានផ្តល់ជំនួយថវិកាជាលុយអឺរ៉ូ (២ លានអឺរ៉ូ)។

## ៥. ការគ្រប់គ្រង និងវិធានការកាត់បន្ថយហានិភ័យ

ផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ គឺជាកម្មវិធីជាតិដែលមានគោលបំណងចង់សម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុក និងលទ្ធផលរំពឹងទុក ប៉ុន្តែដំណើរការអនុវត្ត នៃផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ នេះក៏នៅមានហានិភ័យផងដែរ។ វិធានការមួយចំនួនអាចកាត់បន្ថយបាននូវហានិភ័យចម្បងៗដូចបានបង្ហាញខាងក្រោមនេះ ៖

| ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|
| ១. សមត្ថភាព (ភ្នាក់ងារអនុវត្ត) | ទាប-មធ្យម | • សមត្ថភាព និងការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាហាក់នៅមានកម្រិតដែលទាមទារឱ្យមានការប្រជុំផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្ថែមរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាមី និងលេខាធិការដ្ឋាន គ.ជ.អ.ប.។<br>• ហានិភ័យទាក់ទងនឹងសមត្ថភាព អាចនឹងកើតមានចំពោះអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន នៅពេលអង្គការដៃគូអនុវត្តផ្តល់ហិរញ្ញប្បទានបន្តដើម្បីអនុវត្តការងារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ហានិភ័យនេះអាចកាត់បន្ថយបាន តាមរយៈការជ្រើសរើសអង្គការដៃគូអនុវត្ត ដែលធ្លាប់មានប្រវត្តិការងារល្អក្នុងការកសាងសមត្ថភាព និងមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរឹងមាំ។<br>• សមត្ថភាពសម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលនឹងត្រូវជ្រើសរើសតាមមូលដ្ឋាន អាចនឹងនៅមានកម្រិត។ កត្តានេះអាចកាត់បន្ថយបានតាមរយៈការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជាប្រចាំព្រមទាំងការណែនាំ ចុះអនុវត្តបណ្តើរ រៀនបណ្តើរ។ |
| ២.នយោបាយ | ទាប | • ការផ្សព្វផ្សាយពីផែនការអនុវត្តគណនេយ្យភាពសង្គម តាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងតាមបែបទំនើប សិក្ខាសាលា កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា និងវេទិកាសាធារណៈនានា ព្រមទាំងមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកផ្តល់សេវា ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធអាចនឹងជួយកាត់បន្ថយការភាន់ច្រឡំថា ផ.អ.គ.ស ជាសកម្មភាពរបស់អង្គការសង្គមស៊ីវិល ហើយការជំរុញឱ្យមានការបើកចំហព័ត៌មាននានា ព័ត៌មានថវិកា និងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ជាសកម្មភាពរបស់គណបក្សនយោបាយ។ |

| | | |
|---|---|---|
| **៣.ការសម្របសម្រួល** | មធ្យម | • សកម្មភាពនានា ត្រូវអនុវត្តដោយក្រសួង ស្ថាប័ន (ផ្នែកផ្គត់ផ្គង់) និងអង្គការសង្គមស៊ីវិល (ផ្នែកតម្រូវការ) ដែលសកម្មភាពទាំងនោះ ត្រូវអនុវត្តស្របគ្នាជាមួយវដ្តនៃសកម្មភាពផែនការអនុវត្តគណនេយ្យភាពសង្គម ដើម្បីរួមចំណែកដល់ដំណើរការអនុវត្តក្នុងការសម្រេចបានលទ្ធផល និងគោលបំណងនានា។ កិច្ចសហការ និងការសម្របសម្រួលរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ អាចជាកត្តាប្រឈមមួយដោយសារតែការអនុវត្ត ផ.អ.គ.ស ពាក់ព័ន្ធនឹងតួអង្គអនុវត្តជាច្រើន។ គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ ដែលរួមមានក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួល និងគ្រប់គ្រងការអនុវត្ត ផ.អ.គ.ស ។ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏មានតួនាទីសម្របសម្រួលផ្នែកផ្គត់ផ្គង់ ហើយអ្នកសម្របសម្រួលរបស់អង្គការសង្គមស៊ីវិល ក៏ត្រូវជ្រើសរើសដើម្បីសម្របសម្រួលផ្នែកតម្រូវការផងដែរ។ |
| **៤.ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល** | មធ្យម | • ដំណើរការរៀបចំផែនការសកម្មភាព និងថវិកា និងការចូលរួមផ្សេងៗនៃផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលអាចធ្វើឱ្យការអនុវត្ត ផ.អ.គ.ស នៅមូលដ្ឋានមានភាពយឺតយ៉ាវ ដូចនេះត្រូវមានការណែនាំ គាំទ្រពីថ្នាក់ជាតិ។ |
| **៥. ការតាមដានត្រួតពិនិត្យ និងនិរន្តរភាព** | មធ្យម-បង្គួរ | • រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាមួយចំនួនអាចនៅមានចំណុចខ្វះខាត ក្នុងការអនុវត្តការងារទាំងឡាយទៅតាមវដ្ត នៃសកម្មភាព ផ.អ.គ.ស ប្រចាំឆ្នាំ។ ការងារជាអាទិភាព គឺបង្កើតយន្តការក្រុមការងារ ផ.អ.គ.ស ជាក់លាក់មួយដើម្បីធានានូវការត្រួតពិនិត្យ និងការសិក្សាស្វែងយល់ប្រកបដោយប្រសិទ្ធភាព ដោយមានការចុះគាំទ្របច្ចេកទេសព្រមទាំងអភិបាលការងារពីថ្នាក់ជាតិ នៃក្រសួង ស្ថាប័ន និងអង្គភាពសាមី។<br>• ហានិភ័យនៃនិរន្តរភាព គឺមានកម្រិតមធ្យមសម្រាប់សកម្មភាពផ្នែកផ្គត់ផ្គង់ ដោយសារការងារនេះត្រូវបានបញ្ចូលក្នុងផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែមានកម្រិតបង្គួរសម្រាប់សកម្មភាពរបស់ផ្នែកតម្រូវការ ដោយសារសកម្មភាពទាំងនោះតម្រូវឱ្យមានការផ្តល់ហិរញ្ញវត្ថុ ដោយមូលនិធិបរធនបាលកិច្ច (Trust Fund) ដែលអាចនឹងមានភាពយឺតយាវក្នុងការអនុវត្ត។ |
| **៦.ថវិកាមិនគ្រប់គ្រាន់ និងវិសាលភាពមានទំហំធំ** | មធ្យម-ខ្ពស់ | • ផ.អ.គ.ស បានរៀបចំឡើងដោយមានលក្ខណៈ ងាយស្រួលក្នុងការពង្រីកវិសាលភាពតំបន់គោលដៅ និងសេវាថ្មីៗ ប្រសិនបើមានថវិកាគ្រប់គ្រាន់។ ការអនុវត្ត ផ.អ.គ.ស នឹងមិនអាចអនុវត្ត ឬពង្រីកវិសាលភាពតំបន់គោលដៅ និងសេវាថ្មីៗតាមផែនការឡើយ ប្រសិនបើថវិកាមិនត្រូវបានផ្តល់គ្រប់គ្រាន់។ រាជរដ្ឋាភិបាលនឹងគៀរករថវិកាពីដៃគូអភិវឌ្ឍន៍បន្ថែម ហើយមូលនិធិបរធនបាលកិច្ចមួយនឹងត្រូវបង្កើតឡើងដើម្បីអនុវត្ត ផ.អ.គ.ស នេះ។ |

# ឧបសម្ព័ន្ធទី១៖ ឯកសារយោង

១. រាជរដ្ឋាភិបាលកម្ពុជា កំណែទម្រង់វិស័យសុខាភិបាល នាយកដ្ឋានផែនការ និងព័ត៌មានសុខភាព ខែកុម្ភៈ ឆ្នាំ២០០៣៖ *គោលនយោបាយស្តីពីការចូលរួមរបស់សហគមន៍ក្នុងសេវាសុខាភិបាល។*

២. រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ខែកុម្ភៈ ឆ្នាំ២០១៣៖ *សេចក្តីព្រាងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ។*

៣. រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ខែកក្កដា ឆ្នាំ២០១៣៖ *ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។*

៤. មូលនិធិអាស៊ី និងធនាគារពិភពលោក ឆ្នាំ២០១៣៖ *សំឡេង ជម្រើស និងការធ្វើសេចក្តីសម្រេចចិត្តស្តីពីការសិក្សាពីការផ្តល់សេវាមូលដ្ឋាននៅកម្ពុជា។*

៥. ផ.អ.គ.ស ឆ្នាំ២០១៤៖ *ផ.អ.គ.ស សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការផ្នែកតម្រូវការសម្រាប់អង្គការដៃគូអនុវត្ត ផ.អ.គ.ស ឆ្នាំ ២០១៥។*

៦. ផ.អ.គ.ស ខែកក្កដា ឆ្នាំ២០១៤៖ *លទ្ធផលវាយតម្លៃវគ្គបណ្តុះបណ្តាលសាកល្បងទី១ និងទី២*

៧. មូលនិធិអាស៊ី ឆ្នាំ២០១៤៖ *តួនាទីរបស់សង្គមស៊ីវិលក្នុងអភិបាលកិច្ចមូលដ្ឋាន ផែនការអនុវត្តគណនេយ្យភាពសង្គម* កំណត់សម្គាល់កម្មវិធីសិក្សារបស់គម្រោងតម្រូវការសម្រាប់អភិបាលកិច្ចល្អ (Demand For Good Governance – DFGG)។

៨. ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៤៖ *ផែនការសម្រាប់ការអនុវត្ត ផ.អ.គ.ស ឆ្នាំ ២០១៤-២០១៧។*

៩. ធនាគារពិភពលោក ខែតុលា ឆ្នាំ២០១៤៖ កំណត់សម្គាល់គោលនយោបាយទី៣ ស្តីពី ផ.អ.គ.ស *ទិដ្ឋភាពយេនឌ័រក្នុងផែនការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា។*

១០. លេខាធិការដ្ឋាន គ.ជ.អ.ប. ឆ្នាំ២០១៥ ៖ *ផ.អ.គ.ស សៀវភៅណែនាំវគ្គបណ្តុះបណ្តាល និងឯកសារសម្រាប់ផ្នែកផ្គត់ផ្គង់។*

១១. ផ.អ.គ.ស ឆ្នាំ២០១៥៖ *សម្ភារៈបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងការបណ្តុះបណ្តាលគ្រូឧទ្ទេសសម្រាប់ផ្នែកតម្រូវការក្នុង ផ.អ.គ.ស។*

១២. ផ.អ.គ.ស ឆ្នាំ២០១៥៖ *សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់ផ្នែកតម្រូវការក្នុង ផ.អ.គ.ស*

១៣. គណៈប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៥៖ ការគាំទ្ររបស់សហភាពអឺរ៉ុប សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (SNDD) សមាសភាគរង ២.១៖ *ការគាំទ្ររបស់សហភាពអឺរ៉ុបចំពោះសង្គមស៊ីវិល គោលការណ៍ណែនាំសម្រាប់អង្គការសង្គមស៊ីវិលដែលស្នើសុំជំនួយថវិកា។*

១៤. ធនាគារពិភពលោក ខែកុម្ភៈ ឆ្នាំ២០១៥៖ កំណត់សម្គាល់គោលនយោបាយទី៤ ស្តីពី ផ.អ.គ.ស *តួនាទីនៃការសម្របសម្រួលផែនការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា។*

១៥. លេខាធិការដ្ឋាន គ.ជ.អ.ប. ឆ្នាំ២០១៥៖ *ផ.អ.គ.ស សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការផ្នែកផ្គត់ផ្គង់*

១៦. ផ.អ.គ.ស ខែមករា ឆ្នាំ២០១៦៖ *សេចក្តីសង្ខេបមេរៀនបទពិសោធន៍ពាក់ព័ន្ធនឹងសកម្មភាពបណ្តុះបណ្តាល ហ្វឹកហ្វឺន និងណែនាំដោយអង្គការដៃគូអនុវត្ត ផ.អ.គ.ស ។*

១៧. ផ.អ.គ.ស ខែមីនា ឆ្នាំ២០១៦៖ *ផ.អ.គ.ស លទ្ធផលវាយតម្លៃការបណ្តុះបណ្តាលគ្រូឧទ្ទេស*

១៨. លេខាធិការដ្ឋាន គ.ជ.អ.ប. ឆ្នាំ២០១៦៖ *ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (២០១៦-២០១៨)។*

១៩. ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៦៖ *ឯកសារជំនួយស្មារតីបេសកកម្មត្រួតពិនិត្យលើកទី១ នៃគម្រោងសំឡេង និងសកម្មភាព គាំទ្រដោយមូលនិធិអភិវឌ្ឍន៍សង្គមរបស់ជប៉ុន* (Japanese Social Development Fund – *JSDF)*។

២០. ធនាគារពិភពលោក ខែតុលា ឆ្នាំ២០១៦៖ *ឯកសារជំនួយស្មារតីបេសកកម្មត្រួតពិនិត្យលើកទី២ នៃគម្រោងសំឡេង និងសកម្មភាព គាំទ្រដោយមូលនិធិអភិវឌ្ឍន៍សង្គមរបស់ជប៉ុន* (Japanese Social Development Fund – *JSDF)*។

២១. ធនាគារពិភពលោក ខែសីហា ឆ្នាំ២០១៧៖ *ឯកសារជំនួយស្មារតីវាយតម្លៃពាក់កណ្តាលគ្រា នៃគម្រោងសំឡេង និងសកម្មភាព គាំទ្រដោយមូលនិធិអភិវឌ្ឍន៍សង្គមរបស់ជប៉ុន* (Japanese Social Development Fund – *JSDF)*។

២២. អង្គការទស្សនៈពិភពលោក ខែកក្កដា ឆ្នាំ២០១៧៖ *សំឡេង និងសកម្មភាពគម្រោងគណនេយ្យភាពសង្គមសម្រាប់ការកែលម្អការផ្តល់សេវា របាយការណ៍វឌ្ឍនភាពពាក់កណ្តាលឆ្នាំ ខែមករា-មិថុនា ឆ្នាំ២០១៧។*

២៣. ធនាគារពិភពលោក ឆ្នាំ២០១៧ ៖ *កំណត់សម្គាល់ទស្សនទានការវាយតម្លៃផលប៉ះពាល់នៃ ផ.អ.គ.ស*

២៤. ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ប្រចាំនៅកម្ពុជា ឆ្នាំ២០១៧៖ *កម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យអំពាវនាវឱ្យមានការដាក់សំណើ។*

២៥. មូលនិធិអាស៊ី ឆ្នាំ២០១៧៖ កំណត់សម្គាល់ការសិក្សារៀនសូត្រទី១ *ស្តីពីមេរៀនបទពិសោធន៍តាមមូលដ្ឋាន នៃផែនការអនុវត្តគណនេយ្យភាពសង្គម។*

២៦. មូលនិធិអាស៊ី ឆ្នាំ២០១៧៖ កំណត់សម្គាល់រៀនសូត្រទី២ ស្តីពី ផ.អ.គ.ស *ការពង្រឹងការផ្តល់សេវាតាមរយៈការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ មេរៀនបទពិសោធន៍តាមមូលដ្ឋាន។*

២៧. មូលនិធិអាស៊ី ឆ្នាំ២០១៧៖ កំណត់សម្គាល់ការសិក្សារៀនសូត្រទី៣ ស្តីពី ផ.អ.គ.ស *ភាពជាដៃគូក្នុងការផ្តល់សេវា ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម និងមេរៀនបទពិសោធន៍តាមមូលដ្ឋាន។*

២៨. មូលនិធិអាស៊ី ឆ្នាំ២០១៧៖ កំណត់សម្គាល់រៀនសូត្រទី៤ ស្តីពី ផ.អ.គ.ស *ការយកចិត្តទុកដាក់លើនិរន្តរភាពនៃការអនុវត្ត ផ.អ.គ.ស មេរៀនបទពិសោធន៍តាមមូលដ្ឋាន។*
២៩. អង្គការសង្គ្រោះកុមារ ខេមរកម្ពុជា ឆ្នាំ២០១៧៖ *សំឡេង និងសកម្មភាពគម្រោងគណនេយ្យភាពសង្គមសម្រាប់ការកែលម្អការផ្តល់សេវា របាយការណ៍វឌ្ឍនភាពពាក់កណ្តាលឆ្នាំ ខែមករា-មិថុនា ឆ្នាំ២០១៧។*
៣០. មូលនិធិអាស៊ី ឆ្នាំ២០១៨៖ *ផ.អ.គ.ស ការពិនិត្យឡើងវិញលើដំណើរការ។*
៣១. ធនាគារពិភពលោក ឆ្នាំ២០១៨៖ *របាយការណ៍វាយតម្លៃផលប៉ះពាល់ដើមគ្រានៃ ផ.អ.គ.ស ។*
៣២. ធនាគារពិភពលោក ខែមីនា ឆ្នាំ២០១៨៖ *ឯកសារជំនួយស្មារតីបេសកកម្មត្រួតពិនិត្យលើកទី៤ នៃគម្រោងសំឡេង និងសកម្មភាព គាំទ្រដោយមូលនិធិអភិវឌ្ឍន៍សង្គមរបស់ជប៉ុន* (Japanese Social Development Fund – *JSDF)*។
៣៣. រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៨៖ *អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃ០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។*
៣៤. អង្គការយែរ៖ របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ផ.អ.គ.ស របាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃ ការប៉ាន់ស្មាន អត្ថបទ និងករណីសិក្សារៀនសូត្រ។
៣៥. គ.គ.អ.ស.៖ របាយការណ៍ទស្សនកិច្ចសិក្សាស្វែងយល់ (ឆ្នាំ ២០១៦-២០១៨)។
៣៦. គ.គ.អ.ស.៖ កំណត់ហេតុកិច្ចប្រជុំ (ឆ្នាំ ២០១៦-២០១៨)។
៣៧. លេខាធិការដ្ឋាន គ.ជ.អ.ប.៖ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។
៣៨. លេខាធិការដ្ឋាន គ.ជ.អ.ប.៖ របាយការណ៍អភិបាលកិច្ច (លទ្ធផលការអង្កេតបែបគុណភាព)
៣៩. លេខាធិការដ្ឋាន គ.ជ.អ.ប.៖ របាយការណ៍វឌ្ឍនភាពពាក់កណ្តាលឆ្នាំ ផ.អ.៣ ទី២
៤០. លេខាធិការដ្ឋាន គ.ជ.អ.ប.៖ ប្រព័ន្ធត្រួតពិនិត្យតាមដានការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម (I-SAF Database)។
៤១. អង្គការផេកកម្ពុជា (PACT)៖ របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ផ.អ.គ.ស របាយការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការប៉ាន់ស្មាន អត្ថបទ និងករណីសិក្សារៀនសូត្រ។
៤២. អង្គការរ៉ាឆា (RACHA) ៖ របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ផ.អ.គ.ស របាយការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការប៉ាន់ស្មាន អត្ថបទ និងករណីសិក្សារៀនសូត្រ។
៤៣. អង្គការសង្គ្រោះកុមារ៖ របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ផ.អ.គ.ស របាយការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការប៉ាន់ស្មាន អត្ថបទ និងករណីសិក្សារៀនសូត្រ។
៤៤. អង្គការស្តារកម្ពុជា៖ របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ផ.អ.គ.ស របាយការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការប៉ាន់ស្មាន អត្ថបទ និងករណីសិក្សារៀនសូត្រ។
៤៥. អង្គការទស្សនៈពិភពលោក៖ របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ផ.អ.គ.ស របាយការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការប៉ាន់ស្មាន អត្ថបទ និងកំណត់សម្គាល់រៀនសូត្រ។

# ឧបសម្ព័ន្ធទី២៖ ឈ្មោះអ្នកពាក់ព័ន្ធដែលបានជួបសម្ភាសន៍ និងពិគ្រោះយោបល់

| | | |
|---|---|---|
| ១ | ឯកឧត្តម **ទី ចំរុន្ធផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងប្រធាន គ.គ.អ.ស. |
| ២ | ឯកឧត្តម **ថ៉ាន់ ចំរើន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៣ | លោកជំទាវ **យុន រចនា** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាសមាជិក គ.គ.អ.ស. |
| ៤ | ឯកឧត្តម **ជាម ប៉េអា** | ប្រធានអង្គភាព ត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងជាសមាជិក គ.គ.អ.ស. |
| ៥ | លោក **ហុក ខៀវ** | ប្រធាននាយកដ្ឋាន នីតិកម្ម ក្រសួងសុខាភិបាល និងជាសមាជិក គ.គ.អ.ស. |
| ៦ | លោក **ឡាយ ប៊ុនថា** | ប្រធាននាយកដ្ឋាន រដ្ឋបាល និងបច្ចេកទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិក គ.គ.អ.ស. |
| ៧ | លោក **ជេដ្ឋ គឹមដុង** | អនុប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៨ | លោក **ខោល យុទ្ធលី** | អនុប្រធានអង្គភាព វិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៩ | លោក **សង់ ពលរិទ្ធ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ |
| ១០ | លោក **អឿង សារ៉ុម** | ទីប្រឹក្សាធនធានមនុស្ស នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១១ | លោក **គួង ធុត្ថា** | ទីប្រឹក្សាជាន់ខ្ពស់ព័ត៌មានវិទ្យា នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១២ | លោក **លី យ៉ាសក្តិ** | នាយករងសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ |
| ១៣ | លោក **កែវ ឈូរិន** | ប្រធានការិយាល័យ នៃនាយកដ្ឋានបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា |
| ១៤ | លោក **អ៊ុក សុខ** | មន្ត្រី នៃនាយកដ្ឋានបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា |
| ១៥ | លោក **ជី ធេរិទ្ធិ** | អនុប្រធាន គ.គ.អ.ស. |
| ១៦ | លោក **ថាច់ លីខាន់** | នាយកតំបន់ទី១ នៃអង្គការវ៉ាឆា និងជាសមាជិក គ.គ.អ.ស. |
| ១៧ | លោក **ឡេង ធីរៈ** | នាយកប្រតិបត្តិ អង្គការទស្សនៈពិភពលោកអន្តរជាតិ និងជាសមាជិក គ.គ.អ.ស. |

| | | |
|---|---|---|
| ១៨ | លោក **ម៉ូត សារណា** | នាយកប្រតិបត្តិផ្នែកកម្មវិធី អង្គការសង្គ្រោះកុមារ និងជាសមាជិក គ.គ.អ.ស. |
| ១៩ | លោក Jan Noorlander | នាយករងប្រទេសផ្នែកកម្មវិធី អង្គការយែរ និងជាសមាជិក គ.គ.អ.ស. |
| ២០ | លោកស្រី **អែល សុផារី** | អង្គការគណៈកម្មាធិការសហប្រតិបត្តិការសម្រាប់កម្ពុជា (CCC) និងជាសមាជិក គ.គ.អ.ស. |
| ២១ | លោកស្រី **ស៊ីវ ស៊ីណេ** | អង្គការ RACHA |
| ២២ | លោក **ឧន យុហៀង** | អង្គការសង្គ្រោះកុមារ |
| ២៣ | លោក **រី សុថារិទ្ធ** | អង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ២៤ | លោកស្រី **ចាន់ សេដ្ឋា** | អង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ២៥ | លោក **តឿង សុខចាន់** | អង្គការយែរ |
| ២៦ | លោកស្រី **សឿង ឆារ៉ា** | អង្គការយែរ |
| ២៧ | លោកស្រី **ជ័យ ជាសុវណ្ណា** | អង្គការស្តារកម្ពុជា |
| ២៨ | លោកស្រី **សុខ ហៀង** | អង្គការស្តារកម្ពុជា |
| ២៩ | លោក **ឈុំ ម៉ៅ** | បុគ្គលិកខេត្ត អង្គការ RACHA |
| ៣០ | លោក **ថេត សានធី** | បុគ្គលិកខេត្ត អង្គការ RACHA |
| ៣១ | លោក **ព្រុំ ថៅនីន** | បុគ្គលិកខេត្ត អង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ៣២ | លោក **សំ សុភ័ក្ត្រ** | AFD, ដៃគូអង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ៣៣ | លោកស្រី **ចាន់ ថន** | AFD, ដៃគូអង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ៣៤ | លោក **សាន ជ័យ** | ANSA ដៃគូអង្គការយែរ |
| ៣៥ | លោកស្រី **ស្រី សុធាវី** | ACT ដៃគូអង្គការយែរ |
| ៣៦ | លោកស្រី **ហានីហ្វីយ៉ា** | នាយិការ PSOD ដៃគូអង្គការ SCI |
| ៣៧ | លោក **ឈឹម ពៅឡូត** | PSOD ដៃគូអង្គការ SCI |
| ៣៨ | លោកស្រី **អ៊ុំ សុខន** | WOMEN ដៃគូអង្គការ SCI |
| ៣៩ | លោក **ម៉ុក សុគន្ធជារ៉ា** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៤០ | លោកស្រី **ទឹម ចាន់គី** | CAF អង្គការ RACHA |
| ៤១ | លោក **សូ ជា** | CAF អង្គការទស្សនៈពិភពលោកអន្តរជាតិ |
| ៤២ | លោកស្រី **ស៊ិន  ឈុនណា** | CAF អង្គការទស្សនៈពិភពលោកអន្តរជាតិ |

៤៣ លោក **ឡេង ឡូន** CAF អង្គការ SCI

៤៤ លោក **អែម ហ៊ុយ** CAF អង្គការ SCI

៤៥ លោកស្រី **ស្រ៊ុន ស្រីដឹង** CAF អង្គការយែរ

៤៦ លោក **ស៊ន ប៊ុរី** CAF អង្គការយែរ

៤៧ លោកស្រី **ដួង យី** CAF អង្គការស្តារកម្ពុជា

៤៨ មន្ត្រី ១៨ នាក់ មកពីថ្នាក់ខេត្ត (មន្ត្រីបង្គោល ផ.អ.គ.ស មន្ទីរអប់រំ យុវជន និងកីឡា និង មន្ទីរសុខាភិបាល)

៤៩ មន្ត្រី ១២ នាក់មកពីថ្នាក់ស្រុក (មន្ត្រីបង្គោល ផ.អ.គ.ស ការិយាល័យអប់រំ យុវជន និង កីឡា ការិយាល័យសុខាភិបាល)

៥០ មនុស្ស ៨ នាក់ មកពីថ្នាក់ឃុំ (ប្រធានគណៈកម្មាធិការ ផ.ស.រ.គ មន្ត្រីបង្គោល ផ.អ.គ.ស នាយកសាលាបឋមសិក្សា និងប្រធានមណ្ឌលសុខភាព)

# ឧបសម្ព័ន្ធទី៣៖ ក្របខ័ណ្ឌលទ្ធផលក្នុងការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២

**គោលបំណងអភិវឌ្ឍន៍កម្មវិធី** (PDO) នៃ ផ.អ.គ.ស ដំណាក់កាលទី២ គឺការបង្កើនការអនុវត្តការងាររបស់អ្នកផ្តល់សេវាសាធារណៈ (រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) តាមរយៈការបង្កើនតម្លាភាព គណនេយ្យភាព គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងសកម្មភាពឆ្លើយតបយ៉ាងសកម្ម។ គោលបំណងនេះនឹងសម្រេចបានតាមរយៈមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាដែលចូលរួមដោយសមាជិកសហគមន៍ (រួមទាំងក្រុមជនងាយរងគ្រោះ) ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ។

**លទ្ធផល៖ PDO**

| លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅឆ្នាំទី១ | ចំណុចដៅឆ្នាំទី២ | ចំណុចដៅឆ្នាំទី៣ | ចំណុចដៅឆ្នាំទី៤ | ចំណុចដៅឆ្នាំទី៥ |
|---|---|---|---|---|---|---|---|
| PDO1.ការអនុវត្តការងាររបស់អង្គភាពផ្តល់សេវាសាធារណៈ (រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) ឱ្យកាន់តែល្អប្រសើរឡើង | PDO1a: % សាលាបឋមសិក្សាគោលដៅដែលមានការអនុវត្តការងារកាន់តែល្អប្រសើរឡើង (យោងតាមសូចនាករចម្រុះដែលផ្អែកតាមសំណួរអង្កេតស្តីពីផលប៉ះពាល់) | 0 | 50% | 60% | 70% | 80% | 80% |
| | PDO1b: % មណ្ឌលសុខភាពគោលដៅដែលមានការអនុវត្តការងារកាន់តែល្អប្រសើរឡើង(យោងតាមសូចនាករចម្រុះដែលផ្អែកតាមសំណួរអង្កេត ស្តីពីផលប៉ះពាល់) | 0 | 50% | 60% | 70% | 80% | 80% |
| | PDO1c: % ឃុំ សង្កាត់គោលដៅដែលមានការអនុវត្តការងារ កាន់តែប្រសើរឡើង(យោង តាមសូចនាករចម្រុះដែលផ្អែកតាមសំណួរអង្កេតស្តីពីផលប៉ះពាល់) | 0 | 50% | 60% | 70% | 80% | 80% |
| PDO2. ការឆ្លើយតបរបស់អ្នកផ្តល់សេវាសាធារណៈ (រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌល | PDO2a: % សកម្មភាព ផ.សរ.គ ពាក់ព័ន្ធនឹងសាលាបឋមសិក្សាដែលត្រូវបានអនុវត្ត ឬកំពុងអនុវត្ត | 0 | 50% | 60% | 70% | 80% | 80% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សុខភាព)កាន់តែល្អប្រសើរឡើង។ | PDO2b: % សកម្មភាព ផ.ស.រ.គ ពាក់ព័ន្ធនឹងមណ្ឌលសុខភាពដែលត្រូវបានអនុវត្ត ឬកំពុងអនុវត្ត | 0 | 50% | 60% | 70% | 80% | 80% |
| | PDO2c: % សកម្មភាព ផ.ស.រ.គ ពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ដែលត្រូវបានអនុវត្ត ឬកំពុងអនុវត្ត | 0 | 50% | 60% | 70% | 80% | 80% |
| PDO3. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យតាមដានអ្នកផ្តល់សេវាសាធារណៈ និងការចូលរួមក្នុងសកម្មភាពកែលម្អ កាន់តែល្អប្រសើរឡើង | PDO3a: % ឃុំ សង្កាត់ដែលបញ្ចប់ ដំណើរការ ផ.អ.គ.ស ប្រចាំឆ្នាំពេញលេញ | 55% | 65% | 80% | 90% | 90% | 90% |
| | PDO3b: % សង្កាត់ដែលបញ្ចប់ដំណើរការ ផ.អ.គ.ស ប្រចាំឆ្នាំពេញលេញ | 0 | 0 | 15% | 40% | 65% | 90% |
| PDO4. សំឡេងរបស់ប្រជាពលរដ្ឋក្នុងការចូលរួមជាមួយអ្នកផ្តល់សេវាសាធារណៈក្នុងមូលដ្ឋានកាន់តែល្អប្រសើរឡើង | PDO4. % ប្រជាពលរដ្ឋ (បុរស ស្ត្រី) ដែលចូលរួមក្នុងដំណើរការ ផ.អ.គ.ស ដែលរាយការណ៍ថា សំឡេងរបស់ខ្លួនក្នុងការផ្តល់សេវាតាមមូលដ្ឋានកាន់តែប្រសើរឡើង | 0 | 30% | 40% | 50% | 60% | 70% |

| លទ្ធផលរយៈពេលមធ្យម | | | | | | | |
|---|---|---|---|---|---|---|---|
| **លទ្ធផល** | **សូចនាករ** | **ដើមគ្រា** | **ចំណុចដៅឆ្នាំទី១** | **ចំណុចដៅឆ្នាំទី២** | **ចំណុចដៅឆ្នាំទី៣** | **ចំណុចដៅឆ្នាំទី៤** | **ចំណុចដៅឆ្នាំទី៥** |
| **សមាសភាគទី ១ ៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា** | | | | | | | |
| | IR1a. % សាលាបឋមសិក្សាជនបទដែលបិទផ្សាយ និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំ ពីព័ត៌មាន I4Cs ពេញលេញ (ដូចជាសិទ្ធិស្តង់ដា ទិន្នន័យអនុវត្តការងារ និងព័ត៌មានថវិកា) | 50% | 50% | 60% | 70% | 75% | 80% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| IR1. តម្លាភាពរបស់អ្នកផ្តល់សេវាសាធារណៈ (រដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) កាន់តែល្អប្រសើរឡើង | IR1b. % មណ្ឌលសុខភាពជនបទ ដែលបិទផ្សាយ និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំ ពីព័ត៌មាន I4Cs ពេញលេញ (ដូចជាសិទ្ធិស្តង់ដា ទិន្នន័យអនុវត្តការងារ និងព័ត៌មានថវិកា) | 50% | 50% | 60% | 70% | 75% | 80% |
| | IR1c. % ឃុំ សង្កាត់ដែលបិទផ្សាយ និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំ ពីព័ត៌មាន I4Cs ពេញលេញ (ដូចជាសិទ្ធិ ស្តង់ដារ ទិន្នន័យអនុវត្តការងារ និងព័ត៌មានថវិកា) | 50% | 65% | 75% | 80% | 85% | 90% |
| IR2. ប្រជាពលរដ្ឋយល់កាន់តែច្បាស់ពី សិទ្ធិ ស្តង់ដា ការផ្តល់សេវា និងថវិកា | IR2a. % ប្រជាពលរដ្ឋ (បុរស ស្ត្រី) ដែល ចូលរួមក្នុងដំណើរការ ផ.អ.គ.ស និងអាចលើក ឡើងយ៉ាងតិចស្តង់ដា ២ (ក្នុងចំណោម ៦) សម្រាប់សេវានីមួយៗ (រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌល សុខភាព) | 0 | 50% | 55% | 60% | 65% | 70% |
| | IR2b. % ប្រជាពលរដ្ឋ (បុរស ស្ត្រី) ដែល ចូលរួមក្នុងដំណើរការ ផ.អ.គ.ស ដែលអាចលើកឡើងយ៉ាងតិចការផ្លាស់ប្តូរ/គំរូថវិកាពីមួយឆ្នាំទៅមួយឆ្នាំសម្រាប់សេវាយ៉ាងតិច ២ (ក្នុងចំណោម ៣) | 0 | 50% | 55% | 60% | 65% | 70% |

| | | | | | | |
|---|---|---|---|---|---|---|
| **សមាសភាគទី ២ ៖ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ** | | | | | | |
| IR3. មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា យល់កាន់តែច្បាស់ពីអាទិភាព និងទស្សនៈរបស់ប្រជាពលរដ្ឋពាក់ព័ន្ធ នឹងអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈ | IR3. % មន្ត្រី អង្គភាពផ្តល់សេវាក្នុង ក្រុង ស្រុក ខណ្ឌគោលដៅដែលរាយការណ៍ថាយល់ច្បាស់ជាងមុនពីអាទិភាព និង ក្តីកង្វល់របស់ប្រជាពលរដ្ឋ | 0 | 50% | 55% | 60% | 65% | 70% |
| IR4. មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាមានការយល់ដឹងពីសកម្មភាពអាទិភាពចាំបាច់ ដើម្បីកែលម្អគុណភាព ប្រសិទ្ធភាពក្នុងការផ្តល់សេវាសារធាណៈនៅមូលដ្ឋាន | IR4a. % មន្ត្រីអង្គភាពផ្តល់សេវា ក្នុងក្រុង ស្រុក ខណ្ឌគោលដៅយល់ដឹងថា ផ.ស.រ.គ កំណត់បាននូវសកម្មភាពជាអាទិភាព ដើម្បីកែលម្អការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន | 0 | 50% | 55% | 60% | 65% | 70% |
| | IR4b. % ប្រជាពលរដ្ឋក្នុងក្រុង ស្រុក ខណ្ឌគោលដៅដែលយល់ដឹងថា ផ.ស.រ.គ កំណត់បានល្អនូវសកម្មភាពជាអាទិភាពនានា ដើម្បីកែលម្អការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន | 0 | 50% | 55% | 60% | 65% | 70% |
| **សមាសភាគទី ៣ ៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)** | | | | | | |
| IR5.សកម្មភាពអាទិភាពរួម ដើម្បីបង្កើនគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈត្រូវបានអនុវត្ត | IR5a. % សកម្មភាព ផ.ស.រ.គ ពាក់ព័ន្ធនឹងសាលាបឋមសិក្សាដែលត្រូវបានអនុវត្តឬកំពុងអនុវត្ត | 0 | 50% | 60% | 70% | 80% | 80% |
| | IR5b. % សកម្មភាព ផ.ស.រ.គ ពាក់ព័ន្ធនឹង | 0 | 50% | 60% | 70% | 80% | 80% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | មណ្ឌលសុខភាព ដែលត្រូវបានអនុវត្ត ឬកំពុងអនុវត្ត | | | | | | |
| | IR5c. % សកម្មភាព ផ.ស.រ.គ ពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានអនុវត្ត ឬកំពុងអនុវត្ត។ | 0 | 50% | 60% | 70% | 80% | 80% |
| **សមាសភាគទី ៤ ៖ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង** | | | | | | | |
| IR6. សមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការជំរុញការចូលរួមយ៉ាងសកម្ម របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនសេវា និងពង្រឹងគុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព កាន់តែល្អប្រសើរឡើង | IR6. % ប្រជាពលរដ្ឋ (បុរស ស្ត្រី) ដែលរាយការណ៍ពីសមត្ថភាពប្រសើរជាងមុនក្នុងការជំរុញការចូលរួមយ៉ាងសកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា | TBD | TBD | TBD | TBD | TBD | TBD |
| IR7. សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្ម ជាមួយប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើង | IR7. % មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាដែលរាយការណ៍ពីសមត្ថភាពប្រសើរជាងមុនក្នុងការចូលរួមយ៉ាងសកម្មជាមួយប្រជាពលរដ្ឋ | TBD | TBD | TBD | TBD | TBD | TBD |
| IR8.អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍អាចដឹកនាំដំណើរការផ្សព្វផ្សាយត្រួតពិនិត្យតាមដាន និងជំរុញការចូលរួមពាក់ព័ន្ធនឹងគណនេយ្យភាព | IR8. ចំនួនអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (បុរស ស្ត្រី) ដែលទទួលបានវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ | TBD | TBD | TBD | TBD | TBD | TBD |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សង្គមប្រកបដោយប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន | | | | | | | |
| **សមាសភាគទី ៥ ៖ ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | | | | | |
| IR9. មានការផ្លាស់ប្តូរដែលអាចកំណត់បានលើគោលនយោបាយ គោលការណ៍ណែនាំ និង/ឬការអនុវត្តរបស់តួអង្គរដ្ឋ តួអង្គមិនមែនរដ្ឋ ដោយសារការសិក្សារៀនសូត្រមេរៀនបទពិសោធន៍ នៃការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម | IR9. អាចកំណត់បានឧទាហរណ៍ជាក់លាក់ពីការកែសម្រួល ការកែលម្អលើគោលនយោបាយ គោលការណ៍ណែនាំ និង/ឬការអនុវត្តរបស់តួអង្គរដ្ឋ តួអង្គមិនមែនរដ្ឋដោយសារការសិក្សារៀនសូត្រមេរៀនបទពិសោធន៍ពីការអនុវត្ត ផ.អ.គ.ស | 0 | អាចលើកឡើងពីឧទាហរណ៍ ១ ឬច្រើន | អាចលើកឡើងពីឧទាហរណ៍ ១ ឬច្រើន | អាចលើកឡើងពីឧទាហរណ៍ ១ ឬច្រើន | អាចលើកឡើងពីឧទាហរណ៍ ១ ឬច្រើន | អាចលើកឡើងពីឧទាហរណ៍ ១ ឬច្រើន |

## ឧបសម្ព័ន្ធទី៤៖ វិសាលភាពតំបន់គោលដៅអនុវត្ត នៃផ.អ.គ.ស ដំណាក់កាលទី១ និងទី២

(ការប៉ាន់ស្មានជាក់ស្តែងសម្រាប់ឆ្នាំ ២០១៥-២០១៨, ការប៉ាន់ស្មានសម្រាប់ឆ្នាំ ២០១៩-២០២៣)

| % ឃុំ*ដែល ៖ | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|---|
| មិនមានបទពិសោធន៍ ផ.អ.គ.ស | 90% | 80% | 45% | 45% | 25% | 10% | 0% | 0% | 0% |
| មានបទពិសោធន៍ ផ.អ.គ.ស យ៉ាងតិច ១ ឆ្នាំ | 10% | 20% | 55% | 55% | 70% | 80% | 90% | 100% | 100% |
| មានបទពិសោធន៍ ផ.អ.គ.ស យ៉ាងតិច ២ ឆ្នាំ | 2% | 10% | 20% | 55% | 55% | 70% | 80% | 90% | 100% |
| មានបទពិសោធន៍ ផ.អ.គ.ស យ៉ាងតិច ៣ ឆ្នាំ | 0% | 2% | 10% | 20% | 55% | 55% | 70% | 80% | 90% |

** ចំនួនឃុំសរុប ៖ ១.៤១០។*

| % សង្កាត់*ដែល៖ | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|---|
| មិនមានបទពិសោធន៍ ផ.អ.គ.ស | 100% | 100% | 100% | 100% | 90% | 75% | 50% | 25% | 0% |
| មានបទពិសោធន៍ ផ.អ.គ.ស យ៉ាងតិច ១ ឆ្នាំ | 0% | 0% | 0% | 0% | 10% | 25% | 50% | 75% | 100% |
| មានបទពិសោធន៍ ផ.អ.គ.ស យ៉ាងតិច ២ ឆ្នាំ | 0% | 0% | 0% | 0% | 0% | 10% | 25% | 50% | 75% |
| មានបទពិសោធន៍ ផ.អ.គ.ស យ៉ាងតិច ៣ ឆ្នាំ | 0% | 0% | 0% | 0% | 0% | 0% | 10% | 25% | 50% |

* ចំនួនសង្កាត់សរុបគឺ ២៣៦។ ប្រសិនបើ ផ.អ.គ.ស មិនអាចគ្របដណ្តប់លើសង្កាត់ទាំងអស់បានក្នុងដំណាក់កាលទី២ កម្មវិធីនឹងចាប់ផ្តើមផ្តោតលើសង្កាត់ដែលក្រីក្របំផុត (ផ្អែកតាមទិន្នន័យអត្រាជនក្រីក្រ) និងពង្រីកទៅសង្កាត់ផ្សេងទៀតបន្តិចម្តងៗ។ សង្កាត់ដែលមិនមានទិន្នន័យអត្រាជនក្រីក្រ នឹងត្រូវទុកក្រោយគេ។

# ឧបសម្ព័ន្ធទី៥÷ វិសាលភាពសេវា នៃ ផ.អ.គ.ស ដំណាក់កាលទី១ និងទី២

(ការប៉ាន់ស្មាន/ជាក់ស្តែងសម្រាប់ឆ្នាំ 2016-2018, ការប៉ាន់ស្មានសម្រាប់ឆ្នាំ 2019-2023)

| % សាលាបឋមសិក្សាតំបន់ជនបទ* ដែលមាន ៖ | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|
| សកម្មភាពផ្នែកផ្គត់ផ្គង់ក្នុង ផ.អ.គ.ស ** | 34% | 57% | 57% | 60% | 70% | 80% | 90% | 100% |
| សកម្មភាពផ្នែកតម្រូវការក្នុង ផ.អ.គ.ស *** | 15% | 20% | 20% | 30% | 50% | 70% | 90% | 100% |

** ចំនួនសរុបសាលាបឋមសិក្សាជនបទគឺ ៦.១១០។*

*** ការបិទផ្សព្វផ្សាយទិន្នន័យ I4Cs*

**** ការបង្កើនការយល់ដឹង ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និង ផ.ស.រ.គ*

| % មណ្ឌលសុខភាពជនបទ* ដែលមាន ៖ | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|
| សកម្មភាពផ្នែកផ្គត់ផ្គង់ក្នុង ផ.អ.គ.ស | 30% | 51% | 51% | 60% | 70% | 80% | 90% | 100% |
| សកម្មភាពផ្នែកតម្រូវការក្នុង ផ.អ.គ.ស | 27% | 48% | 48% | 60% | 70% | 80% | 90% | 100% |

** ចំនួនសរុបមណ្ឌលសុខភាពជនបទគឺ xxx,xxx។*

| % រដ្ឋបាលក្រុង ស្រុក ខណ្ឌ* ដែលមាន៖ | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|
| សកម្មភាពផ្នែកផ្គត់ផ្គង់ក្នុង ផ.អ.គ.ស * | 0% | 0% | 1% | 1% | 10% | 35% | 65% | 100% |
| សកម្មភាពផ្នែកតម្រូវការក្នុង ផ.អ.គ.ស | 0% | 0% | 0% | 0% | 10% | 35% | 65% | 100% |

** ចំនួនសរុបរដ្ឋបាលស្រុក រួមទាំងក្រុង និងខណ្ឌគឺ ២០៣។*

## ឧបសម្ព័ន្ធទី៦÷ ការផ្លាស់ប្តូរការទទួលខុសត្រូវក្នុងការអនុវត្ត ផ.អ.គ.ស ក្នុងសហគមន៍ ដែលបានអនុវត្តរយៈពេល៣ឆ្នាំ ឬចាប់ពី៤ឆ្នាំ

| ការទទួលខុសត្រូវរបស់ផ្នែកតម្រូវការក្នុងការអនុវត្ត ផ.អ.គ.ស នៅថ្នាក់មូលដ្ឋាន | ក្នុងសហគមន៍ "ថ្មី" បានការអនុវត្ត ផ.អ.គ.ស រយៈពេល៣ឆ្នាំ | ក្នុងសហគមន៍ បានការអនុវត្ត ផ.អ.គ.ស ចាប់ពីឆ្នាំទី ៤ |
|---|---|---|
| (១) រៀបចំសកម្មភាពផ្សព្វផ្សាយ និងណែនាំអំពីការអនុវត្ត ផ.អ.គ.ស | អង្គការដៃគូអនុវត្ត | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (២) រៀបចំសិក្ខាសាលាផ្សព្វផ្សាយនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | អង្គការដៃគូអនុវត្ត | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (៣) ជ្រើសរើស បណ្តុះបណ្តាល ណែនាំ ហ្វឹកហ្វឺន និងត្រួតពិនិត្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | អង្គការដៃគូអនុវត្ត | "តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍" (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) |
| (៤) ជ្រើសរើស បណ្តុះបណ្តាល និងត្រួតពិនិត្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | អង្គការដៃគូអនុវត្ត | "តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍" (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) |
| (៥) ណែនាំ និងត្រួតពិនិត្យ "តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍" និងផ្តល់វគ្គបណ្តុះបណ្តាលបំប៉នតាមការចាំបាច់ | មិនមាន | អង្គការដៃគូអនុវត្ត |
| (៦) ពិនិត្យឡើងវិញលើ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងធានាឱ្យមានការត្រួតពិនិត្យតាមដានបន្ត ទៅតាមការចាំបាច់ | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (៧) រៀបចំ និងសម្របសម្រួលសកម្មភាព ផ.អ.គ.ស ថ្នាក់រដ្ឋបាលឃុំ សង្កាត់(ឧ.ការលើកកម្ពស់ការយល់ដឹងពី I4Cs ប័ណ្ណដាក់ពិន្ទុសហគមន៍ និងកិច្ចប្រជុំរួម) | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (៨) ធានានូវការសម្របសម្រួល និងការកំណត់បញ្ហានៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ | អង្គការដៃគូអនុវត្ត | "តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍" (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) និងអ្នកផ្តល់សេវាពាក់ព័ន្ធ |

| | | |
|---|---|---|
| (៩) ធានានូវការផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីពី ផ.ស.រ.គ | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពី តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) និងអ្នកផ្តល់សេវាពាក់ព័ន្ធ |
| (១០) ដាក់បញ្ចូល ផ.ស.រ.គ ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងធ្វើបទបង្ហាញនៅសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (១១) បណ្តុះបណ្តាល គាំទ្រសមាជិកគណៈកម្មាធិការ ផ.ស.រ.គ | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | អ្នកសម្របសម្រួលការងារគណនេយ្យភាពសហគមន៍ (ដោយមានជំនួយពី តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (១២) គាំទ្រ និងតាមដានត្រួតពិនិត្យ ការអនុវត្ត ផ.ស.រ.គ | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (១៣) ធានានូវការរាយការណ៍ជាសាធារណៈពីដំណើរការនៃការអនុវត្ត ផ.ស.រ.គ | តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍(ដោយមានជំនួយពីអង្គការដៃគូអនុវត្ត) | គណៈកម្មាធិការ ផ.ស.រ.គ (ដោយមានជំនួយពីតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) |
| (១៤) ការប្រមូលទិន្នន័យសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាបន្តបន្ទាប់ | អង្គការដៃគូអនុវត្ត | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ប្រមូល និងបញ្ជូនទិន្នន័យទៅអង្គការដៃគូអនុវត្តដើម្បីចងក្រង និងវិភាគ |

# ឧបសម្ព័ន្ធទី៧÷ សកម្មភាពលម្អិតទៅតាមសមិទ្ធផល និងលទ្ធផលរំពឹងទុក

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| **សមាសភាគទី១ ÷ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា** | |
| **១.១. តម្លាភាពអំពីថវិកា និងការបំពេញការងាររបស់អង្គភាពផ្តល់សេវាកាន់តែប្រសើរ** | **១.១.១.ការបើកចំហព័ត៌មាននានា និងព័ត៌មានថវិកា**<br>• រៀបចំកិច្ចប្រជុំតម្រង់ទិស ដើម្បីអនុវត្តការងារគណនេយ្យភាពសង្គម<br>• ផលិត និងចែកចាយផ្ទាំង I4Cs ដល់អង្គភាពផ្តល់សេវាដែលពាក់ព័ន្ធ<br>• បោះពុម្ព ចែក បំពេញ ប្រមូល ទម្រង់ទិន្នន័យលទ្ធផលបំពេញការងារ និងថវិកា ព្រមទាំងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្ម (online)<br>• បង្កើតឡើងនូវគោលការណ៍ណែនាំ និងចូលរួមពិនិត្យទិន្នន័យលទ្ធផលបំពេញការងារ និងថវិកាដែលបានបោះពុម្ព ដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការសង្គមស៊ីវិល<br>• បង្កើតឡើង សាកល្បង និងអនុវត្តប្រព័ន្ធសម្រាប់ប្រមូលទិន្នន័យលទ្ធផលបំពេញការងារ ដោយប្រើ បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរស័ព្ទ និងប្រព័ន្ធអេឡិចត្រូនិក<br>• ក្រសួងសាមីប្រើប្រាស់ប្រព័ន្ធនានា និងគោលការណ៍ណែនាំ និងបែងចែកថវិកាសម្រាប់ការផលិត និងចែកចាយផ្ទាំង I4Cs និងការប្រមូល ការបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ និងការបិទផ្សាយទិន្នន័យលទ្ធផលបំពេញការងារជាសាធារណៈ<br>• ក្រសួងសាមី និង គ.គ.អ.ស ពិនិត្យឡើងវិញនូវខ្លឹមសារ និងទម្រង់ថវិកា ហើយកែសម្រួល និងបន្ថែមចំណុចថ្មីៗទៅតាមភាពសមស្រប<br>• បិទផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋនិងទិន្នន័យលទ្ធផលបំពេញការងារ និងថវិកាជាសាធារណៈនៅតាមទីតាំងអង្គភាពផ្តល់សេវាទាំងអស់ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
| --- | --- |
| | • បង្កើតឡើង សាកល្បង និងអនុវត្តប្រព័ន្ធសម្រាប់ផ្សព្វផ្សាយសារ I4Cs សំខាន់ៗតាមអេឡិចត្រូនិក (សារខ្លីៗ អ៊ីម៉ែល អ៊ីនធើណែត រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម)<br><br>**១.១.២.ការប្រើប្រាស់ព័ត៌មានឱ្យបានទូលំទូលាយនិងស៊ីជម្រៅ**<br>• រៀបចំជារៀងរាល់ឆ្នាំសម្រាប់ការពិនិត្យឡើងវិញ ឬពិភាក្សាក្នុងក្រសួង ស្ថាប័នសាមី គ.គ.អ.ស គ.ជ.អ.ប. និងអង្គភាពសាមី នូវរបាយការណ៍វិភាគស្ដីពីបណ្ដុំទិន្នន័យ I4Cs<br>• បង្ហាញ និងពិភាក្សាអំពីលទ្ធផល I4Cs ក្នុងកិច្ចប្រជុំថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងវេទិកាសាធារណៈដោយមានវត្តមានអ្នកឯកទេសតាមវិស័យ |
| **១.២.ប្រជាពលរដ្ឋទទួលបានព័ត៌មានកាន់តែទូលំទូលាយស្ដីពីសិទ្ធិ ស្ដង់ដាការបំពេញការងារ និងថវិកា** | **១.២.១.ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋស្ដីពីសិទ្ធិ ស្ដង់ដាការបំពេញការងារ និងថវិកា**<br>• រៀបចំកិច្ចប្រជុំ និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋស្ដីពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ<br>• លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីទិន្នន័យលទ្ធផលបំពេញការងារ និងថវិការួមបញ្ចូលការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបទំនើប និងប្រពៃណី<br>• បង្កើតឡើង សាកល្បង និងអនុវត្តវិធីសាស្ត្រសម្រាប់ជួយឱ្យប្រជាពលរដ្ឋយល់ដឹង កាន់តែច្រើនអំពីថវិកាសាធារណៈ<br>• រៀបចំលិខិតបទដ្ឋាននានា ដើម្បីធានាដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| **សមាសភាគទី២ ÷ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ** | |
| ២.១. រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា ទទួលបានព័ត៌មានកាន់តែទូលំទូលាយស្តីពីអាទិភាពរបស់ប្រជាពលរដ្ឋ និងទស្សនៈនានាដែលពាក់ព័ន្ធទៅនឹងអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈនានា | **២.១.១.ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ**<br>• បង្កើត អនុវត្តសាកល្បង និងអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (កិច្ចប្រជុំប័ណ្ណដាក់ពិន្ទុដោយសហគមន៍ និងការវាយតម្លៃខ្លួនឯងដោយអ្នកផ្តល់សេវា) ដែលត្រូវបានកែសម្រួល និងប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)<br>• អនុវត្តដំណើរការត្រួតពិនិត្យតាមដាន ដោយប្រជាពលរដ្ឋ (កិច្ចប្រជុំប័ណ្ណដាក់ពិន្ទុដោយសហគមន៍ និងការវាយតម្លៃខ្លួនឯងដោយអ្នកផ្តល់សេវា) ក្នុង ផ.អ.គ.ស ជាប្រចាំឆ្នាំនៅតាមតំបន់គោលដៅអនុវត្ត និងលើសេវានីមួយៗ<br>**២.១.២.ការរៀបចំលិខិតបទដ្ឋាននានា ដើម្បីគាំទ្រការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ**<br>• រៀបចំ និងចេញគោលការណ៍ណែនាំដោយក្រសួង ស្ថាប័នសាមី ដើម្បីគាំទ្រដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងកំណត់ពីការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ<br>• ពិនិត្យតាមដាន និងលើកទឹកចិត្តតាមរយៈប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់ក្រសួង ស្ថាប័នសាមី ក្នុងការអនុវត្តដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋក្នុង ផ.អ.គ.ស |
| ២.២. រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋកំណត់បានជារួម ស្តីពីសកម្មភាពជាអាទិភាពចាំបាច់ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ នៅមូលដ្ឋានប្រកបដោយគុណភាព និងប្រសិទ្ធភាព | **២.២.១.កិច្ចប្រជុំរួម**<br>• ក្នុងកិច្ចប្រជុំរួម បង្ហាញអំពីព័ត៌មានថវិកា កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងពិភាក្សា ស្តីពីការរៀបចំថវិកា និងការប្រើប្រាស់មូលនិធិរបស់អង្គភាពផ្តល់សេវាដើម្បីឆ្លើយតបនឹងសកម្មភាពអាទិភាពក្នុង ផ.ស.រ.គ<br>• រៀបចំកិច្ចប្រជុំរួម និងបង្កើត ផ.ស.រ.គ ក្នុងតំបន់គោលដៅអនុវត្ត និងសេវានីមួយៗ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| | • បង្កើតគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ក្នុងតំបន់អនុវត្តនីមួយៗ |
| **សមាសភាគទី៣ ៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** | |
| **៣.១. ការអនុវត្ត និងការតាមដានផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីកែលម្អគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ** | **៣.១.១.ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម**<br>• អនុវត្តសកម្មភាព ផ.ស.រ.គ នៅតាមតំបន់គោលដៅអនុវត្តនីមួយៗ<br>• គណៈកម្មាធិការ ផ.ស.រ.គ នៅតាមតំបន់គោលដៅអនុវត្តនីមួយៗគាំទ្រ ត្រួតពិនិត្យ និងតាមដានការអនុវត្ត ផ.ស.រ.គ<br>• បង្ហាញ ផ.ស.រ.គ សម្រាប់តំបន់គោលដៅអនុវត្តនីមួយៗ ជារៀងរាល់ឆ្នាំ ក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ<br>• រៀបចំសេចក្តីណែនាំ ពីការប្រើប្រាស់មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រការអនុវត្ត ផ.អ.គ.ស<br>• បង្កើតប្រព័ន្ធ និងនីតិវិធីសម្រាប់គាំទ្រដោយក្រសួង ស្ថាប័ន និងអង្គភាពសាមី ដើម្បីផ្តល់មូលនិធិ និងពិនិត្យតាមដានការអនុវត្តសកម្មភាព ផ.ស.រ.គ<br>• អនុវត្តសាកល្បងនូវការពិនិត្យឡើងវិញ ដោយប្រជាពលរដ្ឋក្នុងការផ្តល់សុពលភាព និងការកំណត់អាទិភាពគម្រោងក្នុងកម្មវិធីវិនិយោគ របស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន<br>• បង្កើតឡើង និងអនុវត្តនូវធនធានចូលរួមបដិភាគ ដើម្បីជួយគាំទ្រដល់ការអនុវត្តសកម្មភាពអាទិភាពក្នុង ផ.ស.រ.គ<br><br>**៣.១.២.ការតាមដានការអនុវត្តផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម** |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| | • សមាជិកគណៈកម្មាធិការ ផ.ស.រ.គ ចូលរួមប្រជុំដោយទៀងទាត់ ក្នុងដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់<br>• ផ្សព្វផ្សាយជាសាធារណៈនូវ ផ.ស.រ.គ តាមរយៈការបិទផ្សាយជាសាធារណៈ ប្រព័ន្ធផ្សព្វផ្សាយ និងវេទិកានានា<br>• រាយការណ៍ជាសាធារណៈ ដោយគណៈកម្មាធិការ ផ.ស.រ.គ ស្តីពីវឌ្ឍនភាពនៃការអនុវត្ត ផ.ស.រ.គ រៀងរាល់ខែ តាមប្រព័ន្ធអេឡិចត្រូនិក និងក្នុងកិច្ចប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| **៣.២.ទិន្នន័យស្តីពីសកម្មភាពជាអាទិភាពសម្រាប់កែលម្អក្នុងវិស័យនីមួយៗ ត្រូវបានធ្វើការវិភាគ និងប្រើប្រាស់ដើម្បីតាក់តែងគោលនយោបាយ** | **៣.២.១.ទិន្នន័យផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមត្រូវបានវិភាគ និងប្រើប្រាស់យ៉ាងទូលំទូលាយ**<br>• កែសម្រួល និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ ដើម្បីធានាថាទិន្នន័យ ផ.ស.រ.គ ត្រូវបានប្រើប្រាស់ និងវិភាគនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| **សមាសភាគទី៤ ÷ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង** | |
| **៤.១.សមត្ថភាពរបស់ផ្នែកតម្រូវការ(អង្គការសង្គមស៊ីវិល) ក្នុងការចូលរួមយ៉ាងសកម្មដើម្បីរួមចំណែកពង្រឹងគុណភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាពត្រូវបានលើកកម្ពស់** | **៤.១.១.ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាពអង្គការសង្គមស៊ីវិល**<br>• ជ្រើសរើស និងបណ្តុះបណ្តាលវិទ្យាស្ថានបណ្តុះបណ្តាលឯកទេសផ្នែកតម្រូវការ<br>• រៀបចំ និងបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់អង្គការដៃគូអនុវត្តថ្មីៗ<br>• កែសម្រួលឯកសារបណ្តុះបណ្តាល ផ្អែកតាមយុទ្ធសាស្ត្របរិយាប័ន្ន និងសមធម៌សង្គម និងផ្តល់វគ្គបណ្តុះបណ្តាលដល់ដៃគូអនុវត្ត និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ |
| **៤.២.សមត្ថភាព របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាក្នុងការចូលរួមយ៉ាងសកម្មជាមួយប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់គុណ** | **៤.២.១.ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាពរបស់អង្គភាពផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិ** |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| ភាព ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ និងបង្កើនគណនេយ្យភាពត្រូវបានពង្រឹង | • បង្កើនការយល់ដឹង និងអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវាក្នុងដំណើរការត្រួតពិនិត្យតាមដាន ដោយប្រជាពលរដ្ឋ និងបច្ចេកទេសស្តីពីការបំពេញទម្រង់ ការប្រមូល ការបញ្ចូល ទិន្នន័យ និងបិទផ្សព្វផ្សាយទិន្នន័យ I4Cs ក្នុងផ.អ.គ.ស ដែលត្រូវធ្វើឡើងដោយក្រសួង ស្ថាប័ន ឬអង្គភាពសាមី<br>• ដាក់បញ្ចូលប្រធានបទសំខាន់ៗ នៅក្នុងឯកសារបណ្តុះបណ្តាល ស្តីពី ផ.អ.គ.ស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសាលាអភិបាលកិច្ច ឬនាយកដ្ឋានបណ្តុះបណ្តាលរបស់ក្រសួងមហាផ្ទៃ ឬសាលាជាតិរដ្ឋបាលមូលដ្ឋាន<br>• រៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់សមាជិកក្រុមការងារ ផ.អ.គ.ស ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br><br>**៤.២.២.ការបណ្តុះបណ្តាល ដល់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ**<br>• ពិនិត្យឡើងវិញ និងកែសម្រួលគោលការណ៍ណែនាំ និងធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលសម្រាប់សមាជិកគណៈកម្មាធិការ ផ.ស.រ.គ<br>• បណ្តុះបណ្តាលសមាជិកគណៈកម្មាធិការ ផ.ស.រ.គ |
| **៤.៣.អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មានឆន្ទៈ និងអាចដឹកនាំដំណើរការផ្សព្វផ្សាយព័ត៌មាននានា ពិនិត្យតាមដាន និងជំរុញការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធទៅនឹងគណនេយ្យភាពសង្គមប្រកប ដោយគុណភាព ប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន** | **៤.៣.១.ការបណ្តុះបណ្តាល ណែនាំ និងហ្វឹកហ្វឺនអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍**<br>• ជ្រើសរើស និងបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍<br>• ផ្តល់លិខិតបញ្ជាក់ការសិក្សា ដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល<br>• ធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាល សម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| | • ណែនាំ និងហ្វឹកហ្វឺនបន្ថែមដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅតាមសហគមន៍ ដោយរៀនសូត្របណ្ដើរ អនុវត្តបណ្ដើរ<br><br>**៤.៣.២.តំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានបង្កើត និងដំណើរការ**<br>• រៀបចំបង្កើតលក្ខខណ្ឌការងារ និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសតំណាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍<br>• បណ្ដុះបណ្ដាល ដល់តំណាងអ្នកសម្របសម្រួលគណនេយ្យ ភាពសហគមន៍<br>• ផ្ដល់លិខិតបញ្ជាក់ការសិក្សា ដល់អ្នកសម្របសម្រួលគណនេយ្យសហគមន៍ ដែលបានបញ្ចប់វគ្គបណ្ដុះបណ្ដាលដោយជោគជ័យ |
| **៤.៤.ការផ្សព្វផ្សាយជាសាធារណៈ ឱ្យបានទូលំទូលាយ ស្ដីពី ផ.អ.គ.ស** | **៤.៤.១.ផែនការអនុវត្តគណនេយ្យភាពសង្គម ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងក្រសួង ស្ថាប័ន អង្គភាពសាមី និងរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>• ផ្ដល់កិច្ចសន្យាការងាររយៈពេលខ្លី ដល់អ្នកជំនាញផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (ICT) ដើម្បីជួយបង្កើត ឧបករណ៍ផ្សព្វផ្សាយ ផ.អ.គ.ស (ឧ. ការប្រមូល និងផ្សព្វផ្សាយទិន្នន័យ I4Cs និងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋតាមអេឡិចត្រូនិក)<br>• រៀបចំសម្ភារៈ និងឧបករណ៍សម្រាប់ផ្សព្វផ្សាយ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្ដីពី ផ.អ.គ.ស |
| **សមាសភាគទី៥ ÷ ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | |
| ៥.១. ធានាការអនុវត្ត ផ.អ.គ.ស ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | **៥.១.១.ការគ្រប់គ្រង និងគាំទ្រការអនុវត្ត ផ.អ.គ.ស នឹងត្រូវបានរៀបចំឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីធានាការអនុវត្តប្រកបដោយលទ្ធផលល្អប្រសើរ** |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
|---|---|
| | • បង្កើតឡើងនូវមូលនិធិបរធនបាលកិច្ច ពីដៃគូអភិវឌ្ឍន៍ចម្រុះ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ដំណើរការអនុវត្តសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី ២<br>• លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រុមសម្របសម្រួលអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ផ្តល់សេវាប្រឹក្សាយោបល់ និងគាំទ្របច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗដែលមានបំណងអនុវត្ត ផ.អ.គ.ស ក្នុងវិស័យរបស់ខ្លួន<br>• ជ្រើសរើស និងផ្តល់ហិរញ្ញវត្ថុដល់អ្នកសម្របសម្រួលសម្រាប់ផ្នែកតម្រូវការ ដោយមូលនិធិបរធនបាលកិច្ច<br>• បង្កើតក្រុមការងារ ផ.អ.គ.ស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកគំរូលក្ខខណ្ឌការងារ នៃក្រុមការងារនេះដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. យុទ្ធសាស្ត្រលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្នសម្រាប់បង្កើនការចូលរួម របស់ក្រុមជនងាយរងគ្រោះ ដូចជាៈ ជនជាតិដើមភាគតិច មនុស្សចាស់ជរា ជនពិការ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ស្រឡាញ់ទាំង២ភេទ ក្រុមប្តូរយេនឌ័រ ត្រូវបានបង្កើតឡើង និងអនុវត្ត |
| **៥.២.ការកែសម្រួលមួយចំនួនលើគោលនយោបាយ គោលការណ៍ណែនាំ ដោយផ្អែកលើមេរៀនបទពិសោធន៍នៃការអនុវត្តសកម្មភាពផ.អ.គ.ស** | **៥.២.១.ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់**<br>• កែសម្រួល សៀវភៅណែនាំស្តីពីប្រតិបត្តិការ ផ.អ.គ.ស សម្រាប់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ<br>• រៀបចំធ្វើទស្សនកិច្ចសិក្សាស្វែងយល់របស់ គ.គ.អ.ស នៅតាមតំបន់គោលដៅអនុវត្ត ផ.អ.គ.ស<br>**៥.២.២.ការតាមដាន ត្រួតពិនិត្យ និងការចងក្រងមេរៀនបទពិសោធន៍**<br>• កែសម្រួលនូវផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលបានរៀបចំ និងអនុវត្ត ផ.អ.គ.ស ក្នុងដំណាក់កាលទី១ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ |
| --- | --- |
| | • រៀបចំធ្វើការអង្កេត លើការសិក្សាវាយតម្លៃផលប៉ះពាល់ដើមគ្រា ពាក់កណ្ដាលគ្រា និងចុងគ្រាក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ដំណាក់កាលទី២<br>• បង្កើត និងរៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាសនូវក្រុមការងារ ផ.អ.គ.ស ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>• រៀបចំកិច្ចប្រជុំប្រចាំឆមាស ឬកិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំតាមការចាំបាច់របស់ គ.គ.អ.ស<br>• រៀបចំកិច្ចប្រជុំបច្ចេកទេសប្រចាំឆមាស ឬកិច្ចប្រជុំតាមការចាំបាច់ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រុមអ្នកសម្របសម្រួលផ្នែកអង្គការសង្គមស៊ីវិល និងក្រុមការងារមូលនិធិបរធនបាលកិច្ចដើម្បីពិនិត្យពីវឌ្ឍនភាព ព្រមទាំងរៀបចំចងក្រង និងកែសម្រួលនូវឯកសារពាក់ព័ន្ធទៅនឹងការអនុវត្ត ផ.អ.គ.ស<br>• រៀបចំកិច្ចប្រជុំជាប្រចាំ រវាងអង្គការសង្គមស៊ីវិលដែលអនុវត្ត ផ.អ.គ.ស និងអង្គការដៃគូអនុវត្តដែលប្រតិបត្តិការនៅមូលដ្ឋានក្នុងវិស័យពាក់ព័ន្ធ |

## ឧបសម្ព័ន្ធទី៨÷ វដ្ត នៃសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី១ (២០១៦-២០១៨)



# ឧបសម្ព័ន្ធទី៩៖ វដ្ត នៃសកម្មភាព ផ.អ.គ.ស ដំណាក់កាលទី២ (២០១៩-២០២៣)

## វដ្តនៃសកម្មភាព ផ.អ.គ.ស ប្រចាំឆ្នាំ ដំណាក់កាលទី២



# ឧបសម្ព័ន្ធទី១០ ÷ សទ្ទានុក្រម

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ | គឺជាព័ត៌មានដែលរៀបចំឡើងសម្រាប់លើកកម្ពស់គណនេយ្យភាព។ ព័ត៌មានសម្រាប់ប្រជាពលរដ្ឋនឹងមានជាសម្ភារៈសម្រាប់បង្ហាញសាធារណជន និងខិតប័ណ្ណផ្សព្វផ្សាយ (កញ្ចប់ព័ត៌មាន) ដែលផ្តល់ឱ្យប្រជាពលរដ្ឋនូវព័ត៌មានសំខាន់ៗអំពីសេវាសាធារណៈនៅមូលដ្ឋាន។ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋមានព័ត៌មាន អំពីសេវារដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ព្រមទាំងសេវាផ្សេងៗទៀតស្របតាមការពង្រីកវិសាលភាពវិស័យ ដែលមានព័ត៌មានស្តីពីសិទ្ធិរបស់អ្នកប្រើប្រាស់ ស្តង់ដា ការបំពេញការងារ និងព័ត៌មានថវិកា។ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ត្រូវបានរៀបចំតាក់តែងឡើងដើម្បីជួយដល់អ្នកប្រើប្រាស់ និងងាយទទួលបានព័ត៌មានទោះបីប្រជាពលរដ្ឋដែលចេះអក្សរតិចតួចក៏ដោយ។ |
| ការចូលរួមរបស់ប្រជាពលរដ្ឋ | សំដៅទៅលើដំណើរការនានាដែលប្រជាពលរដ្ឋនៅតាមសហគមន៍រួមគ្នារៀបចំឡើង ដើម្បីចូលរួមផ្តល់យោបល់ ផ្តល់គំនិតនៅក្នុងដំណើរការរៀបចំ និងការធ្វើសេចក្តីសម្រេចចិត្តនានារបស់រដ្ឋបាលពាក់ព័ន្ធនឹងគោលនយោបាយ ដីកា និងលិខិតបទដ្ឋាននានា។ |
| ការចូលរួមរបស់អង្គការសង្គមស៊ីវិល | ជាដំណើរការនៅក្នុងសហគមន៍ដែលប្រជាពលរដ្ឋប្រមូលផ្តុំគ្នាបង្កើតឡើង ដើម្បីសម្រេចគោលដៅរួមនានារបស់ខ្លួននៅមូលដ្ឋាន និងធ្វើការងារជាបុគ្គល ឬរួមគ្នាតាមរយៈអង្គការសហគមន៍មិនមែនរដ្ឋាភិបាលដើម្បីមានឥទ្ធិពលទៅលើដំណើការធ្វើសេចក្តីសម្រេចចិត្ត។ |
| ការទទួលខុសត្រូវ | សំដៅទៅលើតួនាទី និងកាតព្វកិច្ចដែលបានប្រគល់ឱ្យដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តទៅឱ្យបុគ្គល អង្គការចាត់តាំងនៃរដ្ឋបាលណាមួយ ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | សំដៅលើការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈ៖ (១) ភាពជាតំណាងសាធារណៈ (២) ស្វ័យភាពរបស់មូលដ្ឋាន (៣) ការពិគ្រោះយោបល់ និងការចូលរួម (៤) ការឆ្លើយតបនិងគណនេយ្យភាព (៥) ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦) ការលើកស្ទួយសមធម៌ (៧) តម្លាភាព និងសុចរិតភាព និង (៨) វិធានការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច។ |
| ការអភិវឌ្ឍសមត្ថភាព | សំដៅទៅលើការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ផ្តល់ឱកាសសិក្សារៀនសូត្រ និងការផ្តល់ព័ត៌មានទិន្នន័យ ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីចាំបាច់នានា ដែលអនុញ្ញាតឱ្យបុគ្គលនិងស្ថាប័នសម្រេចបាននូវលទ្ធផលរំពឹងទុក និងគោលដៅ។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| **កិច្ចប្រជុំរួម** | បង្កើតឡើងដើម្បីជាការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ។ កិច្ចប្រជុំរួមត្រូវបានសម្របសម្រួលឱ្យមានឡើងតាមកន្លែងដែលអ្នកទទួលសេវា និងប្រជាពលរដ្ឋបានជួបគ្នាជាមួយអ្នកផ្តល់សេវា (ដូចជាមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) ដើម្បីចែករំលែកនូវមតិយោបល់ផ្សេងៗអំពីការបំពេញការងារ គុណភាព និងប្រសិទ្ធភាពផ្តល់សេវា និងដើម្បីរៀបចំនូវផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់កែលម្អសេវផ្សេងៗ។ |
| **គណនេយ្យភាព** | កាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចដើម្បីឆ្លើយតប និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ។ (ដកស្រង់ពីឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ទំព័រ១៦២) |
| **គណនេយ្យភាពសង្គម** | សំដៅទៅលើសកម្មភាព និងយន្តការនានាដែលប្រជាពលរដ្ឋអាចប្រើប្រាស់ ដើម្បីទាមទារឱ្យរដ្ឋបាលមានគណនេយ្យភាពចំពោះខ្លួន ព្រមទាំងសកម្មភាពនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល និងតួអង្គដទៃទៀតក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាព និងយន្តការទាំងនោះ។ |
| **តួអង្គមិនមែនរដ្ឋ** | សំដៅលើប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលដែលជាអង្គការមិនមែនរដ្ឋាភិបាលនានា។ ក្រៅពីនេះ តួអង្គមិនមែនរដ្ឋ ក៏សំដៅលើស្ថាប័នសារព័ត៌មាន ស្ថាប័នបណ្តុះបណ្តាល និងវិស័យឯកជនផ្សេងៗ។ |
| **តួអង្គរដ្ឋ** | សំដៅលើស្ថាប័ន អង្គភាព មន្ទីរ ការិយាល័យជំនាញ មន្ត្រីរបស់រាជរដ្ឋាភិបាល ដូចជាមន្ទីរជំនាញថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រី បុគ្គលិកអង្គភាពផ្តល់សេវា នៅមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ សាលាបឋមសិក្សា មណ្ឌលសុខភាព ជាដើម។ |
| **បរធនបាលកិច្ច** | សំដៅដល់កិច្ចការគ្រប់គ្រង និងចាត់ចែងបរធន (ទ្រព្យសម្បត្តិ ឬមូលនិធិដែលបានផ្ទេរ) ដែលផ្តល់ដោយបរធនបាលទាយក (បុគ្គលដែលបង្កើត កំណត់លក្ខខណ្ឌ និងផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូង) សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ (បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច) ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ |
| **បរិយាប័ន្ន** | សំដៅលើការលើកកម្ពស់ការចូលរួម និងទទួលផលពេញលេញរបស់ប្រជាពលរដ្ឋគ្រប់រូបគ្រប់ក្រុម និងសហគមន៍សកម្មភាពនានារបស់សង្គមដោយគ្មានការរើសអើង។ |
| **ប័ណ្ណដាក់ពិន្ទុសហគមន៍** | គឺជាឧបករណ៍សម្រាប់ត្រួតពិនិត្យតាមដានគណនេយ្យភាពសង្គម ដែលអាចឱ្យប្រជាពលរដ្ឋអ្នកទទួលសេវា និងអ្នកផ្តល់សេវា វាយតម្លៃគុណភាពសេវានៅមូលដ្ឋាន និងដើម្បីពង្រឹងសហ |

| វាក្យស័ព្ទ | និយមន័យ |
| --- | --- |
| | ប្រតិបត្តិការ ជាមួយមន្ត្រី និងអ្នកផ្តល់សេវាក្នុងការរៀបចំ និងអនុវត្តសកម្មភាពនានាសម្រាប់ធ្វើឱ្យមានការផ្លាស់ប្តូរ។ |
| **ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** | គឺជាផែនការសកម្មភាពចម្បងនៃដំណើរការត្រួតពិនិត្យតាមដាន តាមរយៈប័ណ្ណដាក់ពិន្ទុសហគមន៍។ ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនេះ គឺជាបញ្ជីសកម្មភាពដែលប្រជាពលរដ្ឋ អ្នកផ្តល់សេវា និងមន្ត្រី បុគ្គលិកអង្គភាពផ្តល់សេវា រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានឯកភាពជាមួយគ្នាដើម្បីអនុវត្តក្នុងការកែលម្អគុណភាពសេវា និងការបំពេញការងាររបស់រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព។ ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនេះ ត្រូវបានពិភាក្សា និងព្រមព្រៀងគ្នានៅវាល់គ្រប់កិច្ចប្រជុំរួម។ |
| **ផ្នែកតម្រូវការ** | សំដៅលើតួនាទីរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងដំណើរការគណនេយ្យភាពសង្គម។ តួអង្គទាំងអស់នេះ មានការទទួលខុសត្រូវដើម្បីធ្វើឱ្យមានការយល់ដឹងអំពីសិទ្ធិ និងភារកិច្ចរបស់ខ្លួន ដើម្បីស្វែងយល់ពីគោលនយោបាយ និងសេវានានារបស់រាជរដ្ឋាភិបាល ព្រមទាំងដើម្បីធ្វើការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយភាព ស្ថាបនាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវានានាដើម្បីលើកកម្ពស់ការបំពេញមុខងាររបស់ស្ថាប័នទាំងនេះ។ |
| **ផ្នែកផ្គត់ផ្គង់** | សំដៅលើតួនាទីរបស់តួអង្គជាស្ថាប័នរដ្ឋ នៅក្នុងដំណើរការអនុវត្តគណនេយ្យភាពសង្គម។ រាជរដ្ឋាភិបាលមានតួនាទីក្នុងការគាំទ្រគណនេយ្យភាពសង្គមតាមរយៈការបង្កើតនូវដំណើរការគោលការណ៍ ស្តង់ដា និងលិខិតបទដ្ឋាននានា។ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា ត្រូវទទួលខុសត្រូវក្នុងការ ចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងតំណាងរបស់ពួកគាត់នៅថ្នាក់មូលដ្ឋាន។ |
| **យេនឌ័រ** | សំដៅទៅលើផ្នត់គំនិត ឬការប្រព្រឹត្តរបស់គ្រួសារ សហគមន៍ និងសង្គមដែលពាក់ព័ន្ធនឹងការបែងចែកការងារ ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទីដល់កូនស្រីនិងកូនប្រុស ឬស្ត្រីនិងបុរស។ ដូចជាការកំណត់របស់គ្រួសារលើការសិក្សារបស់កូនស្រី កូនប្រុស ការកំណត់ការងារសម្រាប់ក្មេងស្រី ក្មេងប្រុស រួមទាំងការងារផ្ទះសម្បែងជាដើម។ |
| **លទ្ធផលរំពឹងទុក** | ផលិតផល ឧបករណ៍ សម្ភារៈ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍មួយ ហើយវាក៏អាចរួមបញ្ចូលទាំងការផ្លាស់ប្តូរនានា ផ្តើមចេញពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងការសម្រេចនូវសមិទ្ធផលរំពឹងទុកនានា។ ស្ថាប័ននានាត្រូវមានគណនេយ្យភាពក្នុងការសម្រេចលទ្ធផលរំពឹងទុកឱ្យបានទាន់ពេលវេលា មានគុណភាព ប្រសិទ្ធភាព និងបរិមាណសមស្រប។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| **វដ្តនៃគណនេយ្យភាពសង្គម** | សំដៅលើដំណើរការអនុវត្តសកម្មភាពនានាពាក់ព័ន្ធ នឹងផែនការអនុវត្តគណនេយ្យភាពសង្គមប្រចាំឆ្នាំ។ ១). ការអភិវឌ្ឍសមត្ថភាព ២). តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា ៣). ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ៤). ការផ្សព្វផ្សាយ និងការអនុវត្តផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គម និង ៥). ការត្រួតពិនិត្យ វាយតម្លៃប្រមូលចងក្រងមេរៀនបទពិសោធន៍នានា។ |
| **វិមជ្ឈការ** | សំដៅទៅលើដំណើរការ ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។ |
| **វិសហមជ្ឈការ** | សំដៅទៅលើដំណើរការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ |
| **សកម្មភាព** | ទង្វើដែលប្រកាន់យក ឬកិច្ចការដែលបានបំពេញដោយប្រើប្រាស់នូវធាតុចូលនានាដូចជា មូលនិធិ ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានកៀរគរ ដើម្បីបង្កើតចេញជាលទ្ធផលរំពឹងទុកជាក់លាក់នានា។ |
| **ស្តង់ដាសេវា** | សំដៅលើកម្រិត និងគុណភាពសេវាដែលរាជរដ្ឋាភិបាលបានកំណត់តាមរយៈគោលនយោបាយ និងលិខិតបទដ្ឋាននានា ហើយប្រជាពលរដ្ឋអាចរំពឹងទទួលបានពេលស្នើសុំ ឬត្រូវការ។ |
| **សមធម៌សង្គម** | សំដៅទៅលើសិទ្ធិប្រើប្រាស់ និងទទួលបានផលប្រយោជន៍ប្រកបដោយភាពយុត្តិធម៌នៃការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន ស្របតាមស្ថានភាពរូបរាងកាយ ស្ថានភាពសង្គម នយោបាយ ព្រមទាំងសិទ្ធិចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចការនយោបាយ និងវប្បធម៌នៅក្នុងសង្គម។ |
| **សិទ្ធិអំណាច** | សំដៅលើលទ្ធភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តនូវការទទួលខុសត្រូវដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីកំណត់ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| **សូចនាករ** | កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្តល់ជាមួយ មានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់វាស់វែងសមិទ្ធផល ឬឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាដែលកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់តួអង្គអភិវឌ្ឍន៍ណាមួយ។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| **សេវាសាធារណៈ** | សំដៅទៅលើរាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច ក្នុងគោលបំណងបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ច ក្នុងន័យនេះសំដៅលើស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធររដ្ឋគ្រប់ជាន់ថ្នាក់ដែលកំពុងបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច ក្នុងន័យនេះ សំដៅលើផ្នែកឯកជន ឬសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។ |
| **អ្នកទទួលសេវា** | សំដៅលើរូបវន្តបុគ្គល និង/ឬនីតិបុគ្គលប្រជាពលរដ្ឋដែលប្រើប្រាស់សេវាសាធារណៈនៅមូលដ្ឋាន ដូចជាសេវានានា ដែលផ្តល់ដោយរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព។ល។ |
| **អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍** | ជាអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ដែលត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលដោយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយសហគមន៍ឱ្យបានចូលរួមអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅថ្នាក់មូលដ្ឋាន ព្រមទាំងប្រមូលផ្តុំ និងលើកកម្ពស់ឱ្យមានការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការអនុវត្តគណនេយ្យភាពសង្គម។ |
| **អង្គការសង្គមស៊ីវិល** | ជាអង្គការមិនមែនរដ្ឋាភិបាល និងមិនរកប្រាក់ចំណេញដែលមានវត្តមានក្នុងសង្គមដែលតំណាងឱ្យផលប្រយោជន៍ និងគុណតម្លៃរបស់សមាជិកខ្លួន ឬអ្នកដទៃ ដោយផ្អែកលើការយកចិត្តទុកដាក់នានាដែលមានលក្ខណៈជាក្រមសីលធម៌ វប្បធម៌ នយោបាយ វិទ្យាសាស្ត្រ សាសនា ឬសប្បុរសធម៌។ |
| **អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ** | សំដៅលើអង្គការមិនមែនរដ្ឋាភិបាល (ជាតិ ឬអន្តរជាតិ) ដែលបានចុះអនុស្សារណៈយោគយល់គ្នា ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការអនុវត្ត ផ.អ.គ.ស។ |
| **អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ** | សំដៅលើអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះអនុស្សារណៈយោគយល់គ្នា ឬកិច្ចព្រមព្រៀង ជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ ដើម្បីអនុវត្ត ផ.អ.គ.ស នៅថ្នាក់ក្រោមជាតិ។ |
| **អង្គភាពផ្តល់សេវា** | ជាតួអង្គនានាដែលទទួលខុសត្រូវផ្ទាល់សម្រាប់ការផ្តល់សេវាសាធារណៈ។ អង្គភាពផ្តល់សេវារួមមាន រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា មណ្ឌលសុខភាព។ល។ |
| **អភិបាលកិច្ច** | សំដៅទៅលើវិធីសាស្ត្រ ឬដំណើរដែលក្រសួង ស្ថាប័ន អង្គភាព ប្រើប្រាស់នូវសិទ្ធិអំណាច មុខងារ និងធនធានក្នុងការគ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការងារសន្តិសុខសណ្តាប់ធ្នាប់ ដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ |

រៀបចំ និងបោះពុម្ពផ្សាយដោយ៖

www.ncdd.gov.kh

គាំទ្រដោយ៖

បោះពុម្ពផ្សាយលើកទី២